# គម្ពីរព្រះអភិធម្ម

# យមកប្បករណ៍




## មូលយមកៈ និង ខន្ធយមកៈ

រៀបរៀងដោយ

អ្នកគ្រូ អ៊ឹ សុជា និង អ្នកគ្រូ ឈោរ សុមាលី

(វត្ត សុវណ្ណបទុម)

ថ្ងៃ ៩កើត ខែ ភទ្របទ ព.ស. ២៥៥៨

# គម្ពីរព្រះអភិធម្ម
# យមកប្បករណ៍




## មូលយមកៈ និង ខន្ធយមកៈ


រៀបរៀងដោយ

**អ្នកគ្រូ អ៊ុំ ជា និង អ្នកគ្រូ ប៉ោះ សុមាលី**

**(វត្ត សុវណ្ណបទុម)**



ថ្ងៃ ចន្ទ ១៣ រោច ខែ បឋមាសាឍ ឆ្នាំ រោង ចត្វាស័ក ព.ស. ២៥៥៦

# ពាក្យផ្តើម

ក្នុងវស្សាទី ៧ ក្រោយពីព្រះអង្គទ្រង់បានត្រាស់ដឹងមក ចាប់ពីថ្ងៃ ៥ កើត រហូតដល់ថ្ងៃ ៤ រោច ខែ ភទ្របទ ជាថ្ងៃដែលព្រះអង្គបានប្រកាសសម្តែងគម្ពីរយមកៈ អស់រយៈពេល ១៥ ថ្ងៃ បានសម្រេចប្រយោជន៍ដល់ពពួកទេវតាក្នុងកាលណោះ មិនតែប៉ុណ្ណោះ ព្រះអង្គបានសម្តែងដល់ព្រះសារីបុត្រនាព្រៃចន្ទក្រហម ព្រះសារីបុត្រក៏បាននាំយកមកសម្តែងដល់ភិក្ខុ ៥០០ រូប ។ ក្នុងសម័យព្រះអង្គគង់ធរមាននៅ មានរឿងដំណាងថា ព្រះបាទបសេនទិកោសលបានឈ្នះសង្គ្រាម ស្តេចយាងត្រឡប់ចូលមកព្រះនគរវិញ មានសេចក្តីត្រេកអររហូតដល់ផ្ទំមិនលក់អស់រយៈពេលជាច្រើនថ្ងៃ ពួកអាមាត្រមិនអាចរកវិធីដូចម្តេចដើម្បីឲ្យព្រះអង្គផ្ទំលក់ ទើបសម្រេចចិត្តទៅយាងព្រះបាទបសេនទិកោសលដើម្បីចូលទៅគល់ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់បានត្រាស់សម្តែងគម្ពីរយមកៈនេះ ឈ្មោះថា “ ចិត្តយមកៈ ” ធ្វើឲ្យព្រះបាទបសេនទិកោសលបានផ្ទំលក់អស់រយៈពេលបីថ្ងៃក្នុងទីនោះ។ លុះតមកគម្ពីរនេះ ព្រះថេរៈលោកក៏បាននាំមកធ្វើសង្គ្លយនាតាំងពីលើកដំបូងមករហូតដល់សព្វថ្ងៃនេះ បរិស័ទជាច្រើនមានសទ្ធាក្នុងការសិក្សាគម្ពីរយមកៈនេះ ។

ហេតុដូច្នេះហើយ ខ្ញុំព្រះករុណាទាំងពីរបានឃើញនូវសារប្រយោជន៍ក្នុងគម្ពីរនេះ ទើបមានបំណងនឹងធ្វើគម្ពីរនេះឲ្យសម្រេចឡើង ដើម្បីងាយស្រួលនឹងបានជាសារៈប្រយោជន៍ដល់សាធុជនអ្នកមានបំណងក្នុងការសិក្សានូវគម្ពីរយមកៈនេះ ។

ថ្ងៃ ៥ កើត ខែ ភទ្របទ ព.ស. ២៥៥៨

អ៊ុំ សុជា

ប៉ោរ សុមាសី

# ត្រួតពិនិត្យ និងកែសម្រួល

## ភាសាបាលី និង សេចក្ដីប្រែ

## ដោយ

លោកម្ចាស់ៈ សុចិណ្ណ ញ៉ឹប យ័ន្ត

លោកម្ចាស់ៈ ឡុង សាវុឌ្ឍ

## បច្ចេកទេសកុំព្យូទ័រ

## ដោយ

លោកម្ចាស់ៈ ស៊ាន់ គឹមឆួន

# អារម្ភកថា

ខ្ញុំព្រះករុណាទាំងឡាយ ជាសិស្សានុសិស្សព្រះអភិធម្ម បានសិក្សាព្រះអភិធម្មអំពីអ្នកគ្រូ អ៊ុំ ជា និង អ្នកគ្រូប៉ោរ សុម៉ាលី តាមបរិច្ឆេទនៃអភិធម្មត្ថសង្គហៈ រហូតបានសិក្សាគម្ពីរធំៗ ដូចជា គម្ពីរធម្មសង្គណី ធាតុកថា យមកៈ មហាបដ្ឋាន។

បណ្ដាគម្ពីរទាំងនោះ គម្ពីរយមកៈ មានរបៀបរៀនច្រើនជាងគេ លំបាកយល់ តែពេលបានសិក្សាតាមវិធីសាស្ត្ររបស់អ្នកគ្រូ ប៉ោរ សុម៉ាលី តាមគម្ពីរដីកាដែលគាត់នាំមកបង្រៀននោះហើយ ស្រាប់តែយល់ ធ្វើឲ្យខ្ញុំព្រះករុណាទាំងឡាយជាអ្នកសិក្សា មានសេចក្ដីជ្រះថ្លាសប្បាយចិត្ត ដោយបានយល់ពីពុទ្ធវចនៈដ៏មានជម្រៅនេះបាន ម្យ៉ាងទៀត ដោយគម្ពីរដីកានេះ មិនទាន់មានអ្នករចនាជាភាសាខ្មែរនៅឡើយ ទើបខ្ញុំព្រះករុណាទាំងឡាយ ជាសិស្សានុសិស្សព្រះអភិធម្ម បានគិតគ្នាចងក្រងមេរៀនក្នុងគម្ពីរយមកៈនេះទុកកុំឲ្យបាត់បង់ទៅ នឹងជាប្រយោជន៍ដល់ជនានុជនជំនាន់ក្រោយ ដែលប្រាថ្នាចង់ចេះ ចង់ដឹងនូវព្រះពុទ្ធវ-ចនៈក្នុងគម្ពីរនេះ។

ការរចនាគម្ពីរយមកនេះ មានឧបសគ្គរារាំងយ៉ាងច្រើន ដូចជា ខ្វះអ្នកត្រួតពិនិត្យព្រោះអ្នកបានសិក្សាគម្ពីរនេះមានតិចបំផុត ខ្វះខាតឧបករណ៍ និង ថវិកា មានអាពាធជាគ្រឿងរំខាន ដែលធ្វើឲ្យអូសបន្លាយពេលយ៉ាងយូរ តែទោះជាយ៉ាងនេះក៏ដោយ ក៏យើងខ្ញុំទាំងឡាយខំប្រឹងពុះពារឧបសគ្គទាំងនោះ រហូតបានសម្រេច។

ការរចនាគម្ពីរយមកៈនេះ មានការត្រួតពិនិត្យច្រើនដង តែយើងខ្ញុំទាំងឡាយគិតថាប្រាកដជាមាននៅសល់ពាក្យខុសមិនខាន ដូច្នេះ អ្នកសិក្សាទាំងឡាយ បានឃើញចំណុចណាមួយខុសហើយ សូមមេត្តាជួយកែសម្រួលផង តែកុំកែពីត្រូវទៅខុសវិញ ។

មហាកុសលទាំងឡាយដែលកើតអំពីកម្លាំងឆន្ទៈ និង សេចក្ដីព្យាយាមរបស់ខ្ញុំព្រះករុណាទាំងឡាយ សូមឧទិសដល់សព្វសត្វទាំងអស់ ជាពិសេស សូមជួយជាកម្លាំងចិត្តដល់អ្នកសិក្សាទាំងឡាយ ឲ្យបានសម្រេចទិសដៅនៃការសិក្សា ដើម្បីបានបញ្ញាវុធសម្រាប់បំផ្លាញនូវសំណាញ់អវិជ្ជាកុំបីខាន៕

សូមអនុមោទនា ! ៗ ! ៗ !

# មាតិកាធម៌

## មាតិកា ទំព័រ

បណាមគាថា........................................ ១
សេចក្តីផ្តើមក្នុងយមកសរូបត្ថនិស្សយ........................................ ៣
វចនត្ថរបស់ពាក្យថា យមកៈ........................................ ៣
ក្នុងយមកប្បករណ៍នេះមានបញ្ហា ៤ យ៉ាង........................................ ៤
ធម៌ដែលជាវិសជ្ជនាមាន ៥ យ៉ាង........................................ ៥
វិធីសម្តែងការចែកកោដ្ឋាសៈ........................................ ៧

## មូលយមកៈ

អនុសន្ធិ........................................ ៩
អង្គធម៌របស់កុសលបទ........................................ ១២
កុសលបទ........................................ ១៤
អង្គធម៌របស់អកុសលបទ........................................ ៣៨
អកុសលបទ........................................ ៤០
អង្គធម៌របស់អព្យាកតបទ........................................ ៦៣
អព្យាកតបទ........................................ ៦៥
អង្គធម៌របស់នាមបទ........................................ ៨៧
នាមបទ........................................ ៨៩

## ខន្ធយមកៈ

អនុសន្ធិ........................................ ១១២
អធិប្បាក្នុងមហាវារៈទាំង ៣........................................ ១១៤
អធិប្បាយក្នុងនយវារៈទាំង ៤ មាន បទសោធនវារៈ ជាដើម........................................ ១១៥

## ក. បណ្ណត្តិវារៈ

អង្គធម៌របស់បណ្ណត្តិវារៈ........................................ ១១៥
បទសោធនវារៈ អនុលោម........................................ ១១៧
បទសោធនវារៈ បច្ចនីកៈ........................................ ១២៦

| | |
|---|---|
| បទសោធនមូលចក្កវារៈ អនុលោម | ១៣៤ |
| បទសោធនមូលចក្កវារៈ បច្ចនីកៈ | ១៥៦ |
| សុទ្ធខន្ធវារៈ អនុលោម | ១៧៣ |
| សុទ្ធខន្ធវារៈ បច្ចនីកៈ | ១៧៩ |
| សុទ្ធខន្ធមូលចក្កវារៈ អនុលោម | ១៨៧ |
| សុទ្ធខន្ធមូលចក្កវារៈ បច្ចនីកៈ | ២០៥ |


## ២. បវត្តិវារៈ


| មាតិកា | ទំព័រ | | |
|---|---|---|---|
| | ឧប្បាទវារៈ | និរោធវារៈ | ឧ/និ-វារៈ |
| តារាងអង្គធម៌បច្ចុប្បន្នវារៈ ឧប្បាទវារៈ ល/លោ | ២២៩ | ៤៥៧ | |
| បច្ចុប្បន្នវារៈ បុគ្គលវារៈ អនុលោម | ២៣៣ | ៤៦០ | ៦៤៩ |
| តារាងអង្គធម៌របស់ឱកាសវារៈ គ្រប់កាលទាំង ៦ | ២៥៥ | | |
| បច្ចុប្បន្នវារៈ ឱកាសវារៈ អនុលោម | ២៥៧ | ៤៦៥ | ៦៥២ |
| បច្ចុប្បន្នវារៈ បុគ្គលោកាសវារៈ អនុលោម | ២៦១ | ៤៦៩ | ៦៥៧ |
| បច្ចុប្បន្នវារៈ បុគ្គលវារៈ បច្ចនីកៈ | ២៦៦ | ៤៧៤ | ៦៦១ |
| បច្ចុប្បន្នវារៈ ឱកាសវារៈ បច្ចនីកៈ | ២៧១ | ៤៧៩ | ៦៦៧ |
| បច្ចុប្បន្នវារៈ បុគ្គលោកាសវារៈ បច្ចនីកៈ | ២៧៤ | ៤៨២ | ៦៧០ |
| តារាងអង្គធម៌អតីតវារៈ បុគ្គលវារៈ | ២៧៩ | | |
| អតីតវារៈ បុគ្គលវារៈ អនុលោម | ២៨១ | ៤៨៧ | ៦៧៧ |
| អតីតវារៈ ឱកាសវារៈ អនុលោម | ២៨៥ | ៤៩១ | ៦៨១ |
| តារាងអង្គធម៌អតីតវារៈ បុគ្គលោកាសវារៈ | ២៨៩ | | |
| អតីតវារៈ បុគ្គលោកាសវារៈ អនុលោម | ២៩២ | ៤៩៥ | ៦៨៥ |
| អតីតវារៈ បុគ្គលវារៈ បច្ចនីកៈ | ២៩៧ | ៥០០ | ៦៩០ |
| អតីតវារៈ ឱកាសវារៈ បច្ចនីកៈ | ៣០០ | ៥០៣ | ៦៩៣ |
| អតីតវារៈ បុគ្គលោកាសវារៈ បច្ចនីកៈ | ៣០៣ | ៥០៧ | ៦៩៧ |
| អក្សរកាត់ និង និមិត្តសញ្ញាក្នុងខន្ធយមកៈ បវត្តិវារៈ | ៣០៩ | | |
| តារាងអង្គធម៌អនាគតវារៈ បុគ្គលវារៈ | ៣១៣ | ៥១៣ | |

# មាតិកា


| មាតិកា | ទំព័រ | | |
|---|---|---|---|
| | ឧប្បាទវារៈ | និរោធវារៈ | ឧ/និ-វារៈ |
| អនាគតវារៈ បុគ្គលវារៈ អនុលោម ............................... | ៣១៧ | ៥១៦ | ៧០២ |
| អនាគតវារៈ ឱកាសវារៈ អនុលោម ............................. | ៣២២ | ៥២១ | ៧០៨ |
| តារាងអង្គធម៌អនាគតវារៈ បុគ្គលោកាសវារៈ................. | ៣២៧ | ៥២៥ | |
| អនាគតវារៈ បុគ្គលោកាសវារៈ អនុលោម....................... | ៣៣២ | ៥២៨ | ៧១២ |
| អនាគតវារៈ បុគ្គលវារៈ បច្ចនីកៈ.................................. | ៣៣៨ | ៥៣៤ | ៧១៩ |
| អនាគតវារៈ ឱកាសវារៈ បច្ចនីកៈ ................................ | ៣៤៣ | ៥៣៩ | ៧២៥ |
| អនាគតវារៈ បុគ្គលោកាសវារៈ បច្ចនីកៈ......................... | ៣៤៦ | ៥៤២ | ៧២៨ |
| បច្ចុប្បន្នាតីតវារៈ បុគ្គលវារៈ អនុលោម ......................... | ៣៥៣ | ៥៤៩ | ៧៣៧ |
| បច្ចុប្បនាតីតវារៈ ឱកាសវារៈ អនុលោម ........................ | ៣៥៩ | ៥៥៤ | ៧៤២ |
| បច្ចុប្បន្នាតីតវារៈ បុគ្គលោកាសវារៈ អនុលោម ............... | ៣៦៣ | ៥៥៨ | ៧៤៧ |
| បច្ចុប្បន្នាតីតវារៈ បុគ្គលវារៈ បច្ចនីកៈ ........................... | ៣៧០ | ៥៦៥ | ៧៥៤ |
| បច្ចុប្បន្នាតីតវារៈ ឱកាសវារៈ បច្ចនីកៈ .......................... | ៣៧៤ | ៥៦៩ | ៧៥៧ |
| បច្ចុប្បន្នាតីតវារៈ បុគ្គលោកាសវារៈ បច្ចនីកៈ.................. | ៣៧៧ | ៥៧២ | ៧៦១ |
| បច្ចុប្បន្នានាគតវារៈ បុគ្គលវារៈ អនុលោម...................... | ៣៨៥ | ៥៨០ | ៧៦៩ |
| បច្ចុប្បន្នានាគតវារៈ ឱកាសវារៈ អនុលោម ..................... | ៣៩២ | ៥៨៦ | ៧៧៤ |
| បច្ចុប្បន្នានាគតវារៈ បុគ្គលោកាសវារៈ អនុលោម............ | ៣៩៦ | ៥៩០ | ៧៧៨ |
| បច្ចុប្បន្នានាគតវារៈ បុគ្គលវារៈ បច្ចនីកៈ........................ | ៤០៤ | ៥៩៨ | ៧៨៥ |
| បច្ចុប្បន្នានាគតវារៈ ឱកាសវារៈ បច្ចនីកៈ....................... | ៤១១ | ៦០៣ | ៧៩០ |
| បច្ចុប្បន្នានាគតវារៈ បុគ្គលោកាសវារៈ បច្ចនីកៈ.............. | ៤១៤ | ៦០៦ | ៧៩៣ |
| អតីតានាគតវារៈ បុគ្គលវារៈ អនុលោម ........................ | ៤២៦ | ៦១៥ | ៨០២ |
| អតីតានាគតវារៈ ឱកាសវារៈ អនុលោម ........................ | ៤៣០ | ៦២០ | ៨០៧ |
| អតីតានាគតវារៈ បុគ្គលោកាសវារៈ អនុលោម ............... | ៤៣៥ | ៦២៤ | ៨១១ |
| អតីតានាគតវារៈ បុគ្គលវារៈ បច្ចនីកៈ ........................... | ៤៤២ | ៦៣២ | ៨១៩ |
| អតីតានាគតវារៈ ឱកាសវារៈ បច្ចនីក............................ | ៤៤៥ | ៦៣៦ | ៨២៣ |
| អតីតានាគតវារៈ បុគ្គលោកាសវារៈ បច្ចនីកៈ.................. | ៤៤៨ | ៦៣៩ | ៨២៦ |

# គ. បរិញ្ញាវារៈ

**មាតិកា** **ទំព័រ**


អនុសន្ធិ ........................................ ៨៣៦
បុគ្គល ១០ ពួក ដែលសម្ដែងក្នុងបរិញ្ញាវារៈ ........................................ ៨៣៦
ការចែកបុគ្គល ១០ ពួក ដោយកាល ៣ ........................................ ៨៣៦
ចែកកាលទាំង ៣ ដោយបុគ្គល ១០ ពួក ........................................ ៨៣៧
អធិប្បាយអភព្វបុថុជ្ជន ........................................ ៨៣៨
បច្ចុប្បន្នវារៈ បុគ្គលវារៈ អនុលោម ........................................ ៨៣៨
បច្ចុប្បន្នវារៈ បុគ្គលវារៈ បច្ចនីកៈ ........................................ ៨៤២
អតីតវារៈ បុគ្គលវារៈ អនុលោម ........................................ ៨៤៥
អតីតវារៈ បុគ្គលវារៈ បច្ចនីកៈ ........................................ ៨៤៨
អនាគតវារៈ បុគ្គលវារៈ អនុលោម ........................................ ៨៥២
អនាគតវារៈ បុគ្គលវារៈ បច្ចនីកៈ ........................................ ៨៥៥
បច្ចុប្បន្នាតីតវារៈ បុគ្គលវារៈ អនុលោម ........................................ ៨៥៩
បច្ចុប្បន្នាតីតវារៈ បុគ្គលវារៈ បច្ចនីកៈ ........................................ ៨៦២
បច្ចុប្បន្នានាគតវារៈ បុគ្គលវារៈ អនុលោម ........................................ ៨៦៨
បច្ចុប្បន្នានាគតវារៈ បុគ្គលវារៈ បច្ចនីកៈ ........................................ ៨៧១
អតីតានាគតវារៈ បុគ្គលវារៈ អនុលោម ........................................ ៨៧៧
អតីតានាគតវារៈ បុគ្គលវារៈ បច្ចនីកៈ ........................................ ៨៨០

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

# បណាមគាថា

នុនធម្មំ បកាសេន្តោ នុននត្ថាយ ចាបកំ
នុន ទុក្ខាធិបន្នានំ នុនាមិតំ នមាមិហំ។

**ប្រែថា** *ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់ប្រកាសហើយនូវព្រះធម៌ដ៏ពីរោះ ដើម្បីកម្ចាត់បង់នូវកម្មដ៏លាមក ដល់សត្វទាំងឡាយអ្នកដេកត្រាំក្នុងទុក្ខដោយពិត ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ញុំាងទុក្ខឲ្យខ្ចាត់បង់ហើយ។*

សាវកានំនុសាសេតិ សារធម្មេ ច ចាណិនំ
សារធម្មំ មនុស្សានំ សាសិតំ តំ នមាមិហំ។

**ប្រែថា** *ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់ទូន្មានហើយនូវព្រះធម៌ដ៏មានសារៈទាំងឡាយ ដល់សាវ័ក និង សត្វទាំងឡាយ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ទូន្មានហើយនូវព្រះធម៌ដ៏មានខ្លឹមសារដល់មនុស្សទាំងឡាយ។*

ស្វាគតន្តំ សិវំ រម្មំ ស្វានេយ្យ ធម្មទេសេន្តំ
ស្វាហនេយ្យ បុញ្ញក្ខេត្តំ ស្វាសកន្តំ នមាមិហំ។

**ប្រែថា** *ព្រះធម៌ឯណា ចង្អុលប្រាប់ផ្លូវដ៏ត្រជាក់ក្សេម នាំអ្នកប្រតិបត្តិតាមទៅដោយប្រពៃ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌នោះ ជាខេត្តនៃបុណ្យ ឧបត្ថម្ភគាំទ្រអ្នកគោរពប្រតិបត្តិឲ្យទៅកាន់សួគ៌ និង ព្រះនិព្វាន។*

ខានន្តោ សោ សព្វជនំ ខាយិតំ មធុរធម្មំ
ខាយន្តំ តិវិធំ លោកំ ខាយិតន្តំ នមាមិហំ។

**ប្រែថា** *ព្រះធម៌ឯណា ញុំាងជនទាំងពួងឲ្យបានផឹកនូវរសព្រះធម៌ ដែលឲ្យកើតសេចក្តីសុខស្ងប់ ប្រៀបដូចជាទឹកឃ្មុំ ចូលដល់កាយ វាចា ចិត្ត ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌នោះ ដែលគ្របសង្កត់លោកទាំង ៣ បានដោយដាច់ខាតហើយ។*

អគ្គោ សេដ្ឋោ វរោ ធម្មោ អគ្គបុញ្ញោ បព្វជ្ជតិ
អគ្គធម្មំ សុនិបុណំ អគ្គតន្តិំ នមាមិហំ។

**ប្រែថា** *ព្រះធម៌ឯណា ប្រសើរបំផុត ជាកំពូលបុណ្យ ដាស់សត្វឲ្យភ្ញាក់ពីលក់ គឺកិលេស ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌នោះ ដ៏លើសលប់ ល្អិតសុខុម ជាកំពូលបុណ្យ នាំសត្វឲ្យផុតទុក្ខ ដល់សុខដ៏បរិបូណ៌ ពោលគឺព្រះនិព្វាន។*

បដិសម្ភិទា ចតស្សោ ច បសដ្ឋោ សោ អនុត្តរោ
បញ្ញាយ ឧត្តរោ លោកេ បសដ្ឋំបិ នមាមិហំ។

**ប្រែថា** *ព្រះសង្ឃឯណា បានបទុះបដិសម្ភិទា ៤ ជាបុគ្គលប្រសើរបំផុត ធួន លោកទាំង ៣ ដោយបញ្ញា ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃនោះ ដែល អ្នកប្រាជ្ញសរសើរហើយ។*

បសត្ថោ ធម្មគម្ភីរោ បញ្ញវន្តោ អលង្កតោ
បសន្នោ អត្ថធម្មញ្ញូ បសដ្ឋំបិ នមាមិហំ។

**ប្រែថា** *ព្រះសង្ឃឯណា ជាពួកបុគ្គលដែលមហាជនសរសើរលើកតម្កើងហើយ មាន ការយល់ជម្រៅក្នុងព្រះធម៌ មានបញ្ញាល្អ មិនវៀចដោយ កាយ វាចា ចិត្ត មានការជឿ មាន សេចក្តីជ្រះថ្លាក្នុងព្រះសទ្ធម្ម ជាក់ច្បាស់នូវអត្ថ និង ធម៌ ខ្ញុំព្រះករុណា សូមក្រាបថ្វាយ បង្គំនូវព្រះសង្ឃនោះ ជាបុគ្គលប្រសើរខ្ពង់ខ្ពស់។*

# សេចក្ដីផ្ដើមក្នុងយមកសរូបត្ថនិស្សយ

## វចនត្ថ និង ពាក្យអធិប្បាយក្នុងពាក្យថា យមកៈ

កេនដ្ឋេន យមកន្តិ យុគឡដ្ឋេន យុគឡញ្ហិ យមកន្តិ វុច្ចតិ។

**សួរថា** *ដែលហៅថា* **យមកៈ** *ព្រោះអត្ថថាដូចម្ដេច?*

**ឆ្លើយថា** *ព្រោះអត្ថថា ជាគូនិងគ្នា, ដូច្នេះ របស់ដែលជាគូនិងគ្នា ទើបលោកហៅថា* **យមកៈ។**

*អធិប្បាយថា របស់ដែលជាគូនិងគ្នានោះ គឺ៖*

**អនុលោម** *និង* **បដិលោម** *ជាគូមួយ ។*

**សន្និដ្ឋាន** *និង* **សំសយ** *ជាគូមួយ ។*

**បុច្ឆា** *និង* **វិសជ្ជនា** *ជាគូមួយ ។*

*ពាក្យថា* **យមកៈ** *ក្នុងបទថា* **យមកបាដិហារិយំ** *និង ក្នុងបទថា* **យមកសាលានមន្ទីរ** *នោះ ពាក្យថា* **យមកៈ** *ប្រែថា ជាគូៗ ដូចគ្នា។*

## វចនត្ថរបស់ពាក្យថា យមកៈ

យមស្ស រាជស្ស វិសយំ កាមតិ អតិក្កាមតិ ឯតេនាតិ > **យមកំ** *បករណ៍ដែលឈ្មោះថា* **យមកៈ** *ព្រោះអត្ថថា ជាគ្រឿងកន្លងបង់នូវវិស័យរបស់យមរាជបាន (ករណសាធនៈ កិតបទវិគ្គហៈ* **យម** *សទ្ទូបបទ* **កមុ** *ធាតុ* **ក្វិ** *បច្ច័យ)។*

*ឬ* ១. និព្វានំ យន្តិ គច្ឆន្តិ ឯតេនាតិ > **យំ** *បករណ៍ដែលឈ្មោះថា* **យំ** *ព្រោះអត្ថថា ជាគ្រឿងទៅកាន់ព្រះនិព្វាន (ករណសាធនៈ កិតបទវិគ្គហៈ* **យា** *ធាតុ* **ណ** *បច្ច័យ)។*

២. មនន្តិ ជានន្តិ បរមត្ថធម្មំ ឯតេនាតិ > **មំ** *បករណ៍ដែលឈ្មោះថា* **មំ** *ព្រោះអត្ថថា ជាគ្រឿងដឹងបរមត្ថធម៌របស់វេនេយ្យសត្វ (ករណសាធនៈ កិតបទវិគ្គហៈ* **មន** *ធាតុ* **ក្វិ** *បច្ច័យ)។*

៣. កាមតិ អតិក្កាមតិ វិចិកិច្ឆំ ឯតេនាតិ > **កំ** *បករណ៍ដែលឈ្មោះថា* **កំ** *ព្រោះអត្ថថា ជាគ្រឿងកន្លងបង់នូវវិចិកិច្ឆារបស់វេនេយ្យសត្វ (ករណសាធនៈ*

*កិតបទវិគ្គហៈ* **កមុ ធាតុ ក្វិ** *បច្ច័យ)។*

**៤. យញ្ច តំ មញ្ច កញ្ចាតិ > យមកំ** *បករណ៍ដែលឈ្មោះថា* **យមកៈ** *ព្រោះអត្ថថា ជាគ្រឿងបន្ទុះព្រះនិព្វាន ជាគ្រឿងជីងបរមត្ថធម៌ និង ជាគ្រឿងកន្ទងបង់នូវវិចិកិច្ឆារបស់វេនេយ្យសត្វ* **(តិ** *បទកម្មធារយសមាសវិគ្គហៈ)។*

*ក្នុងយមកប្បករណ៍នេះ ព្រះអង្គទ្រង់សំដែងសភាវធម៌ទាំងឡាយ ជា* **មូល** *ជា* **ខន្ធ** *ជា* **អាយតនៈ** *ជាដើម ទាំងនេះ សុទ្ធតែពាក្យសួរ និងពាក្យឆ្លើយទាំងអស់។*

*ដូច្នេះ បណ្ដាពួកបុគ្គលដែលជាអ្នកសិក្សា និង ជាអ្នកមាននាទីបង្រៀនទាំងឡាយ គួរ យល់ចូលចិត្តក្នុងសំនួរ និង ចម្លើយ ដូចតទៅនេះ។*

## ក្នុងយមកប្បករណ៍នេះ មានបញ្ហា ៤ យ៉ាងគឺ ៖

**១. បុរេបញ្ហា** *គឺជាសំនួរដែលមានអត្ថធម៌ផ្សេងគ្នា គឺអត្ថធម៌របស់សន្និដ្ឋានបទ ផ្សេងគ្នាពីអត្ថធម៌របស់សំសយបទ។*

**២. បច្ឆាបញ្ហា** *គឺជាសំនួរដែលមានអត្ថធម៌ដូចគ្នា គឺអត្ថធម៌របស់សន្និដ្ឋានបទ និង អត្ថធម៌របស់សំសយបទនោះ ដូចគ្នា។*

**៣. បរិបុណ្ណបញ្ហា** *គឺជាសំនួរដែលមានអត្ថធម៌ផ្សេងគ្នាក៏មាន អត្ថធម៌ដូចគ្នាក៏មាន គឺអត្ថធម៌របស់សន្និដ្ឋានបទមួយចំនួន ក៏ផ្សេងគ្នាពីអត្ថធម៌របស់សំសយបទ មួយចំនួនទៀត ក៏ដូចគ្នានឹងអត្ថធម៌របស់សំសយបទ បានសេចក្ដីថា មានទាំងបុរេបញ្ហា និង បច្ឆាបញ្ហាព្រមនៅក្នុងបញ្ហានេះ។*

**៤. មោឃបញ្ហា** *មោឃបញ្ហានេះ មាន ២ យ៉ាងគឺ ៖*

*១- ជាសំនួរដែលសួរដល់អត្ថធម៌របស់សន្និដ្ឋានបទ ដែលអត្ថធម៌របស់សន្និដ្ឋានបទនោះ មិនមាន ដូច្នេះ សំនួរប្រភេទនេះ ទើបជា* **មោឃបញ្ហា** *។*

*២- ជាសំនួរដែលសួរដល់អត្ថធម៌របស់សន្និដ្ឋានបទ តែសំសយបទ ដែលជាបទសួរនោះ មិនមានអត្ថធម៌ ដូច្នេះ សំនួរនេះ ក៏ជា* **មោឃបញ្ហា** *ដូចគ្នា។*

## ធម៌ដែលជាពាក្យវិសជ្ជនាមាន ៥ យ៉ាងគឺ ៖

១. **សរូបទស្សនវិសជ្ជនា** *គឺជាពាក្យវិសជ្ជនាដោយការសំដែងសរុបអន្តធម៌របស់ធម៌ពួកមុន និង ពួកក្រោយទាំង ២ ទៅជាមួយគ្នា ដូចជាពាក្យវិសជ្ជនាក្នុងបទថា* **តីណេវ** កុសលមូលានិ អវសេសា កុសលា ធម្មា ន កុសលមូលា។

តីណេវ កុសលមូលានិ *ជាបុរិមកោដ្ឋាសៈ,* អវសេសា កុសលា ធម្មា ន កុសលមូលា *ជាបច្ឆិមកោដ្ឋាសៈ ដូចនេះ ជាដើម។*

## សរូបទស្សនវិសជ្ជនា មាន ២ យ៉ាងគឺ ៖

*១. សរូបទស្សនវិសជ្ជនា ដែលមានវិភង្គដោយត្រង់។*

*២. សរូបទស្សនវិសជ្ជនា ដែលមានវិភង្គដោយអម។*

*- ការសំដែងវិសជ្ជនាដោយលើកយកធម៌ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង មកតាំងជាធម៌ពួកដំបូង ហើយលើកយកធម៌ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ មកតាំងជាធម៌ពួកក្រោយ ហៅថា* **សរូប-ទស្សនវិសជ្ជនាដែលមានវិភង្គដោយត្រង់** *ដូចជា* កុសលសមុដ្ឋានំ រូបំ កុសល-មូលេន ឯកមូលំ ន កុសលំ *ជាធម៌ពួកដំបូង,* កុសលំ កុសលមូលេន ឯកមូលញ្ចេវ កុសលញ្ច, *ជាធម៌ពួកក្រោយ ដូចនេះ ជាដើម។*

*- ការសំដែងវិសជ្ជនាដោយលើកយកធម៌ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ មកតាំងជាធម៌ពួកដំបូង ហើយលើកយកធម៌ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង មកតាំងជាធម៌ពួកក្រោយ ហៅថា* **សរូបទស្សនវិសជ្ជនាដែលមានវិភង្គដោយអម** *ដូចជា* មូលានិ យានិ ឯកតោ ឧប្បជ្ជន្តិ កុសលមូលានិ ឯកមូលានិ ចេវ អញ្ញមញ្ញមូលានិ ច, *ជាធម៌ពួកដំបូង,* អវសេសា កុសលមូលសហជាតា ធម្មា កុសលមូលេន ឯកមូលា ន ច អញ្ញមញ្ញមូលា *ជាធម៌ពួកក្រោយ ដូចនេះ ជាដើម។*

**២. បដិវចនវិសជ្ជនា** *គឺជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ បានដល់ពាក្យថា* **អាមន្តា** *នោះឯង។*

**៣. ឋាឡិតវិសជ្ជនា** *គឺជាពាក្យវិសជ្ជនាដែលឆ្លើយផ្ទុយពីពាក្យសួរ ដូចជាសួរថា* **យត្ថ រូបក្ខន្ធោ នុប្បជ្ជតិ, តត្ថ វេទនាក្ខន្ធោ នុប្បជ្ជតីតិ?** *រូបក្ខន្ធមិនមែនកំពុងកើតក្នុងភូមិណា, វេទនាខន្ធក៏មិនមែនកំពុងកើតក្នុងភូមិនោះឬ? ឆ្លើយថា* **ឧប្បជ្ជតិ** *កំពុងកើត។*

**៤. បដិក្ខេបវិសជ្ជនា** *គឺជាពាក្យវិសជ្ជនាដែលពោលហាមពាក្យសួរ ព្រោះពាក្យសួរនោះមិនមានអត្ថធម៌នៅក្នុងសន្និដ្ឋានបទ ដូចជាសួរថា* **យស្ស រូបក្ខន្ធោ នុប្បជ្ជិត្ថ, តស្ស វេទនាក្ខន្ធោ នុប្បជ្ជិត្ថាតិ?** *រូបក្ខន្ធមិនធ្លាប់កើតដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះឬ? ឆ្លើយថា* **នត្ថិ** *មិនមាន។ បានសេចក្តីថា អ្នកដែលរូបក្ខន្ធមិនធ្លាប់កើតនោះ មិនមានឡើយ ដូច្នេះ ពាក្យសួរបទនេះ ទើបជា* **មោឃបញ្ហា** *ជាបញ្ហាដែលមិនមានពាក្យឆ្លើយ។*

**៥. បដិសេធវិសជ្ជនា** *គឺជាពាក្យវិសជ្ជនាដែលពោលបដិសេធសំសយបទ ព្រោះសំសយបទនោះ មិនមានអត្ថធម៌ ដូចជាសួរថា* **យោ រូបក្ខន្ធំ បរិជានាតិ, សោ វេទនាក្ខន្ធំ បរិជានិត្ថាតិ?** *បុគ្គលណា កំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ឆ្លើយថា* **នោ** *មិនមែនទេ។*

*បានសេចក្តីថា ពួកបុគ្គលដែលកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធនោះ នឹងធ្លាប់បានកំណត់ដឹងច្បាស់នូវវេទនាខន្ធមកហើយនោះ មិនមាន ដូច្នេះ សំនួរនេះ ក៏ជា* **មោឃបញ្ហា** *ដូចគ្នា តែជា* **មោឃបញ្ហា** *ដែលនៅមានពាក្យឆ្លើយបាន។*

❋❋❋❋❋

# វិធីសំដែងការចែកកោដ្ឋាសៈ

១. បរិបុណ្ណបញ្ហា = **សរូបទស្សនវិសជ្ជនា**ដែលមានវិភង្គដោយអម។

*ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ....... ឬ? ទើបព្រះអដ្ឋកថាចារ្យ ទ្រង់សំដែងដោយការលើកយក ......... ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបុរិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា ......... ហើយទ្រង់លើកយក ....... ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ បានតែម្យ៉ាង ទុកក្នុងបច្ឆិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា .........ពាក្យវិសជ្ជនាក្នុង.......នេះ ជាសរូបទស្សនវិសជ្ជនាដែលមានវិភង្គដោយអម។*

២. បរិបុណ្ណបញ្ហា = **សរូបទស្សនវិសជ្ជនា**ដែលមានវិភង្គដោយត្រង់។

*ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា.........ឬ? ទើបព្រះអដ្ឋកថាចារ្យទ្រង់ សំដែងដោយការលើកយក........ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុង បុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា.........ហើយទ្រង់លើក យក ......... ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុង បច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា........ពាក្យវិសជ្ជនា ក្នុង.........នេះ ជាសរូបទស្សនវិសជ្ជនាដែលមានវិភង្គដោយត្រង់។*

៣. បច្ចាបញ្ហា = **បដិវចនវិសជ្ជនា**

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ...... ឬ? ទើបព្រះអដ្ឋកថាចារ្យទ្រង់សំដែង ដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់ សន្និដ្ឋានបទ ព្រោះថា......ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏ជា ..... ផង។*

៤. បុរេបញ្ហា = **បាឡិគតិវិសជ្ជនា**

*ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា.........ឬ? ទើបព្រះអដ្ឋកថាចារ្យទ្រង់សំដែង ដោយបាឡិគតិវិសជ្ជនាថា ....... ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា ....... .ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សួម្បី........ មិនមែនកំពុងកើត តែ ....... កំពុងកើត។*

**៥. មោឃបញ្ហា = បដិក្ខេបវិសជ្ជនា**

*ដូច្នេះ ពាក្យសួរបទនេះ ជា* ***មោឃបញ្ហា*** *សួរថា រូបក្ខន្ធមិនធ្លាប់កើតដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ* ***បដិក្ខេបវិសជ្ជនាថា ឆត្តិ*** *ដែលជាពាក្យវិសជ្ជនាហាមអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា ពួកបុគ្គលដែលរូបក្ខន្ធមិនធ្លាប់កើតក្នុងភពផ្សេងៗនោះ មិនមាន មានតែពួកបុគ្គលដែលរូបក្ខន្ធ ធ្លាប់កើតមកហើយទាំងអស់។*

**៦. មោឃបញ្ហា = បដិសេធវិសជ្ជនា**

*ដូច្នេះ ពាក្យសួរបទនេះ ជា* ***មោឃបញ្ហា*** *សួរថា បុគ្គលណា កំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា* **នោ** *ដែលជាពាក្យវិសជ្ជនា បដិសេធអង្គធម៌របស់សំសយបទ ព្រោះថា អរហត្តមគ្គបុគ្គល ១ ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ តែមិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ ៕*

**(អក្សរដែលគូសបន្ទាត់ខាងក្រោមនេះ ជាកន្លែងដែលត្រូវប្តូរទៅតាមបទនោះៗ)។**

# មូលយមកៈ

## កុសលតិកនិទ្ទេសវារៈ

### អនុសន្ធិ

*កាលព្រះអង្គទ្រង់សំដែងគម្ពីរ* **កថាវត្ថុ** *ចប់សព្វគ្រប់ហើយ ទើបទ្រង់សំដែងគម្ពីរ* **យមកៈ** *ជាបន្ទ។*

### គម្ពីរយមកៈនោះឯង មាន ១០ យមកៈ គឺ ៖

**១. មូលយមកៈ ២. ខន្ធយមកៈ ៣. អាយតនយមកៈ ៤. ធាតុយមកៈ ៥. សច្ចយមកៈ ៦. សង្ខារយមកៈ ៧. អនុសយយមកៈ ៨. ចិត្តយមកៈ ៩. ធម្មយមកៈ ១០. ឥន្ទ្រិយយមកៈ។**

*ក្នុងយមកៈ ១០ យ៉ាងនេះ ព្រះអង្គទ្រង់សំដែង* **មូលយមកៈ** *មុន រួចទើបទ្រង់សំដែង* **ខន្ធយមកៈ** *ជាដើម តទៅតាមលំដាប់។*

### មូលយមកៈ មាន ២ យ៉ាងគឺ ៖

**ឧទ្ទេស** *និង* **និទ្ទេស** *ព្រះអង្គទ្រង់សំដែង* **ឧទ្ទេស** *មុន រួចទើបទ្រង់សំដែង* **និទ្ទេស** *តទៅ។*

### ឧទ្ទេស មាន ២ យ៉ាងគឺ ៖

**តិកមាតិកាឧទ្ទេស** *និង* **ទុកមាតិកាឧទ្ទេស** *ព្រះអង្គទ្រង់សំដែង* **តិកមាតិកាឧទ្ទេស** *មុន រួចទើបទ្រង់សំដែង* **ទុកមាតិកាឧទ្ទេស** *តទៅ។*

**បញ្ជាក់ ៖** តិកមាតិកាឧទ្ទេស និង ទុកមាតិកាឧទ្ទេស ទាំង ២ នេះ មិនចាំបាច់នាំមកសំដែងក្នុងទីនេះ ព្រោះថា ក្នុងឧទ្ទេសនោះ មិនមានពាក្យអធិប្បាយពិសេសទេ មានត្រឹមតែជាចំណងជើងរបស់និទ្ទេស ប្រហែលៗនឹងមាតិកា។

## និទ្ទេស មាន ២ យ៉ាងគឺ ៖

**តិកមាតិកានិទ្ទេស** *និង* **ទុកមាតិកានិទ្ទេស** *ព្រះអង្គទ្រង់សំដែង* **តិកមាតិកានិទ្ទេស** *មុនរួចទើបទ្រង់សំដែង* **ទុកមាតិកានិទ្ទេស** *តទៅ។*

**តិកមាតិកានិទ្ទេស** *មានតិក ២២ គឺ* **កុសលតិកៈ** *ជាដើម រហូតដល់* **សនិទស្សនតិកៈ** *ជាទីបំផុត។*

**ទុកមាតិកានិទ្ទេស** *មានទុក ១០០ គឺ* **ហេតុទុកៈ** *ជាដើម រហូតដល់* **សរណទុកៈ** *ជាទីបំផុត។*

*ក្នុង* **តិកមាតិកានិទ្ទេស** *២២ នោះ ព្រះអង្គទ្រង់សំដែង* **កុសលតិកនិទ្ទេស** *មុនរួចទើបទ្រង់សំដែង* **វេទនាតិកនិទ្ទេស** *តទៅតាមលំដាប់។*

## កុសលតិកនិទ្ទេសមាន ១០ វារៈគឺ ៖

១. មូលវារៈ, ២. ហេតុវារៈ, ៣. និទានវារៈ, ៤. សម្ភវវារៈ,
៥. បភវវារៈ, ៦. សមុដ្ឋានវារៈ, ៧. អាហារវារៈ, ៨. អារម្មណវារៈ,
៩. បច្ចយវារៈ, ១០. សមុទយវារៈ។

មូលំ ហេតុ និទានញ្ច សម្ភវោ បភវេន ច
សមុដ្ឋានាហារារម្មណា បច្ចយោ សមុទយេន ជាតិ។

*ក្នុងវារៈទាំង ១០ យ៉ាងនោះ ព្រះអង្គទ្រង់សំដែង* **មូលវារៈ** *មុន ហើយទ្រង់សំដែង* **ហេតុវារៈ** *ជាដើម តទៅតាមលំដាប់។*

## ក្នុងមូលវារៈ មាន ៤ បទគឺ ៖

១. កុសលបទ, ២. អកុសលបទ, ៣. អព្យាកតបទ, ៤. នាមបទ ។

*ក្នុង ៤ បទនោះ ព្រះអង្គទ្រង់សំដែង* **កុសលបទ** *មុន ហើយទើបទ្រង់សំដែង* **អកុសលបទ** *ជាដើម តទៅតាមលំដាប់។*

## ក្នុងកុសលបទ មានន័យ ៤ យ៉ាងគឺ ៖

១. មូលន័យ, ២. មូលមូលន័យ, ៣. មូលកន័យ, ៤. មូលមូលកន័យ។

*ក្នុងន័យ ៤ យ៉ាងនេះ ព្រះអង្គទ្រង់សំដែង* **មូលន័យ** *មុន ហើយទ្រង់សំដែង* **មូលមូលន័យ** *ជាដើម តទៅតាមលំដាប់ៗ*

## មូលន័យ មានយមកៈ ៣ យ៉ាងគឺ ៖

**១. មូលយមកៈ, ២. ឯកមូលយមកៈ, ៣. អញ្ញមញ្ញមូលយមកៈ។**

*ក្នុងយមកៈ ៣ យ៉ាងនោះ ព្រះអង្គទ្រង់សំដែង* **មូលយមកៈ** *មុន ហើយទ្រង់សំដែង* **ឯកមូលយមកៈ** *ជាដើម តទៅតាមលំដាប់ៗ*

## ក្នុងមូលយមកៈនេះ មាន ២ យ៉ាងគឺ ៖

**អនុលោម** *និង* **បដិលោម** *ព្រះអង្គទ្រង់សំដែង* **អនុលោម** *មុន ហើយទ្រង់សំដែង* **បដិលោម** *តទៅ។*

## អនុលោមមាន ២ យ៉ាងគឺ ៖

**បុច្ឆា** *និង* **វិសជ្ជនា** *ព្រះអង្គទ្រង់សំដែង* **បុច្ឆា** *មុន ហើយទើបទ្រង់សំដែង* **វិសជ្ជនា** *តទៅ។*

## បុច្ឆា មាន ២ យ៉ាងគឺ ៖

**សន្និដ្ឋាន** *និង* **សំសយ** *ព្រះអង្គទ្រង់សំដែង* **សន្និដ្ឋាន** *មុន ហើយទ្រង់សំដែង* **សំសយ** *តទៅ ។*

# តារាងអនុសន្ធិ ក្នុងយមកប្បករណ៍

<table>
<tr><td colspan="11">កថាវត្ថុប្បករណ៍ → យមកប្បករណ៍</td></tr>
<tr><td>មូល</td><td>ខន្ធ</td><td>អាយតនៈ</td><td>ធាតុ</td><td>សច្ចៈ</td><td>សង្ខារ</td><td>អនុសយៈ</td><td>ចិត្ត</td><td>ធម្ម</td><td>ឥន្ទ្រិយ</td><td>សរុប</td></tr>
<tr><td colspan="6">ឧទ្ទេស</td><td colspan="4">និទ្ទេស</td><td>២</td></tr>
<tr><td colspan="11">និទ្ទេស</td></tr>
<tr><td colspan="6">តិកមាតិកានិទ្ទេស</td><td colspan="4">ទុកមាតិកានិទ្ទេស</td><td>២</td></tr>
<tr><td colspan="10">កុសលតិកៈ ។ល។ សនិទស្សនតិកៈ</td><td>២២</td></tr>
<tr><td>មូល</td><td>ហេតុ</td><td>និទាន</td><td>សម្ភវៈ</td><td>បភវៈ</td><td>សមុដ្ឋាន</td><td>អាហារ</td><td>អារម្មណៈ</td><td>បច្ចយៈ</td><td>សមុទយៈ</td><td>១០</td></tr>
<tr><td colspan="3">កុសលបទ</td><td colspan="3">អកុសលបទ</td><td colspan="2">អព្យាកតបទ</td><td colspan="2">នាមបទ</td><td>៤</td></tr>
<tr><td colspan="3">មូលន័យ</td><td colspan="3">មូលមូលន័យ</td><td colspan="2">មូលកន័យ</td><td colspan="2">មូលមូលកន័យ</td><td>៤</td></tr>
<tr><td colspan="3">មូលយមកៈ</td><td colspan="5">ឯកមូលយមកៈ</td><td colspan="2">អញ្ញមញ្ញមូលយមកៈ</td><td>៣</td></tr>
<tr><td colspan="6">អនុលោម</td><td colspan="4">បដិលោម</td><td>២</td></tr>
<tr><td colspan="6">បុច្ឆា</td><td colspan="4">វិសជ្ជនា</td><td>២</td></tr>
<tr><td colspan="6">សន្និដ្ឋានបទ</td><td colspan="4">សំសយបទ</td><td>២</td></tr>
</table>

# អត្ថធម៌មូលយមកៈ ក្នុងកុសលបទ

កុសលា ធម្មា = ពួកធម៌ជាកុសល។

*៙ អត្ថធម៌ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨។*

កុសលមូលា = ឈ្មោះថា កុសលមូល។

*៙ អត្ថធម៌ បានដល់ កុសលមូល ៣។*

កុសលមូលមូលា = ឈ្មោះថា មូលដែលជាកុសលមូល។

*៙ អត្ថធម៌ បានដល់ កុសលមូល ៣។*

កុសលមូលេន ឯកមូលា = មានមូលតែមួយ ជាមួយនឹងកុសលមូល។

៙ អន្តធម៌ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ កុសលចិត្តជរូប ១៧។

កុសលមូលេន ឯកមូលមូលា = **មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូល។**

៙ អន្តធម៌ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ កុសលចិត្តជរូប ១៧។

កុសលមូលេន អញ្ញមញ្ញមូលា = **ឈ្មោះថាជាមូលដល់គ្នានិងគ្នា ជាមួយនឹងកុសលមូល។**

៙ អន្តធម៌ បានដល់ កុសលមូល ៣។

កុសលមូលេន អញ្ញមញ្ញមូលមូលា = **ឈ្មោះថាមូលដែលជាមូលដល់គ្នានិងគ្នា ជាមួយនឹងកុសលមូល។**

៙ អន្តធម៌ បានដល់ កុសលមូល ៣។

កុសលមូលកា = **មានមូលជាកុសល។**

៙ អន្តធម៌ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ កុសលចិត្តជរូប ១៧។

កុសលមូលមូលកា = **មានមូលដែលជាកុសលមូល។**

៙ អន្តធម៌ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ កុសលចិត្តជរូប ១៧។

កុសលមូលេន ឯកមូលកា = **មានមូលតែមួយជាមួយនឹងកុសលមូល។**

៙ អន្តធម៌ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ កុសលចិត្តជរូប ១៧។

កុសលមូលេន ឯកមូលមូលកា = **មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូល។**

៙ អន្តធម៌ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ កុសលចិត្តជរូប ១៧។

កុសលមូលេន អញ្ញមញ្ញមូលកា = **មានមូលដល់គ្នានិងគ្នា ជាមួយនឹងកុសលមូល។**

*១ អគ្គធម៌ បានដល់ កុសលមូល ៣។*

កុសលមូលេន អញ្ញមញ្ញមូលមូលកា = **មានមូលដែលជាមូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូល។**

*១ អគ្គធម៌ បានដល់ កុសលមូល ៣ ។*

# មូលវារៈ

## កុសលបទ

## ក. មូលន័យ

### ១. មូលយមកៈ

**អនុលោមបុច្ឆា** យេ កេចិ កុសលា ធម្មា, សព្វេ តេ កុសលមូលាតិ? *ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ទាំងអស់នោះ ឈ្មោះថា កុសលមូលឬ?*

**វិសជ្ជនា** តីណេវ កុសលមូលានិ, អវសេសា កុសលា ធម្មា ន កុសលមូលា។ *អលោភៈ អទោសៈ អមោហៈ តែ៣ ប៉ុណ្ណោះ ឈ្មោះថា កុសលមូល កុសលធម៌ដែលនៅសល់ក្រៅពីនោះ មិនឈ្មោះថាកុសលមូលឡើយ។*

**បដិលោមបុច្ឆា** យេ វា បន កុសលមូលា, សព្វេ តេ ធម្មា កុសលាតិ? *ម្យ៉ាងទៀត ពួកធម៌ណា ឈ្មោះថាកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ?*

**វិសជ្ជនា** អាមន្តា *មែន។*

## ការសំដែងអគ្គធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យេ កេចិ កុសលា ធម្មា *ជាសន្និដ្ឋានបទ។*

**សព្វេ តេ កុសលមូលា** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៥ (-៣ ) និង កុសលមូល ៣ ។

៙ អន្តធម៌របស់សំសយបទ បានដល់ កុសលមូល ៣ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ ទាំងអស់នោះ ឈ្មោះថា កុសលមូលឬ? ទើបព្រះអង្គទ្រង់សំដែង ដោយការលើកយក **កុសលមូល ៣** ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុង បុរិមកោដ្ឋាស: មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **តីណេវ កុសលមូលានិ** ហើយទ្រង់លើកយក **កុសលចិត្ត ២១ ចេតសិក ៣៥ (វៀរកុសល មូល ៣)** ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបច្ឆិមកោដ្ឋាស: មានការ បដិសេធសំសយបទ ដូចបានសំដែងថា **អវសេសា កុសលា ធម្មា ន កុសលមូលា** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមាន វិកប្បដោយអម។

## ក្នុងបដិលោមបុច្ឆា

**យេ វា បន កុសលមូលា** ជាសន្និដ្ឋានបទ។

**សព្វេ តេ ធម្មា កុសលា** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កុសលមូល ៣។

៙ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ឆាបញ្ហា** សួរថា ម្យ៉ាងទៀត ពួកធម៌ណា ឈ្មោះថា កុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ? ទើបព្រះអង្គទ្រង់សំដែងដោយ **បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា កុសលមូល ៣ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏ជាកុសលផង។

## ២. ឯកមូលយមកៈ

**អនុលោមបុច្ឆា** យេ កេចិ កុសលា ធម្មា, សព្វេ តេ កុសលមូលេន ឯកមូលាតិ? *ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ជាមួយនឹងកុសលមូលឬ?*

**វិសជ្ជនា** អាមន្តា *មែនៗ*

**បដិលោមបុច្ឆា** យេ វា បន កុសលមូលេន ឯកមូលា, សព្វេ តេ ធម្មា កុសលាតិ? *ម្យ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ?*

**វិសជ្ជនាៈ** កុសលសមុដ្ឋានំ រូបំ កុសលមូលេន ឯកមូលំ ន កុសលំ, កុសលំ កុសលមូលេន ឯកមូលញ្ចេវ កុសលញ្ច។ *រូបដែលមានកុសលជាសមុដ្ឋាន មានមូលតែមួយ ជាមួយនឹងកុសលមូល តែមិនមែនជាកុសលឡើយ, កុសលធម៌ មានមូលតែមួយ ជាមួយនឹងកុសលមូលផង ជាកុសលផងៗ*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យេ កេចិ កុសលា ធម្មា *ជាសន្និដ្ឋានបទៗ*

សព្វេ តេ កុសលមូលេន ឯកមូលា *ជាសំសយបទៗ*

- *អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ៗ*
- *អត្ថធម៌របស់សំសយបទ ដូចគ្នាៗ*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ ទាំងអស់នោះ មានមូលតែមួយ ជាមួយនឹងកុសលមូលឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួល*

អន្តធម៌របស់ សន្និដ្ឋានបទ ព្រោះថា កុសលចិត្ត ២១ចេតសិក ៣៨ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ ទាំងនោះ ក៏មានមូលតែមួយជាមួយនឹងកុសលមូលផង។

## ក្នុងបដិលោមបុច្ឆា

យេ វា បន កុសលមូលេន ឯកមូលា ជាសន្និដ្ឋានបទ។

សព្វេ តេ ធម្មា កុសលា ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្តជួរប ១៧ និង កុសលចិត្ត ២១ ចេតសិក ៣៨។

៙ អន្តធម៌របស់សំសយបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក កុសលចិត្តជួរប ១៧ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ បានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **កុសលសមុដ្ឋានំ រូបំ កុសលមូលេន ឯកមូលំ ន កុសលំ**, ហើយទ្រង់លើកយក **កុសលចិត្ត ២១ ចេតសិក ៣៨** ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និងសំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **កុសលំ កុសលមូលេន ឯកមូលញ្ចេវ កុសលញ្ច** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនាដែលមានវិកប្បដោយត្រង់។

## ៣. អញ្ញមញ្ញមូលយមកៈ

**អនុលោមបុច្ឆា** យេ កេចិ កុសលមូលេន ឯកមូលា ធម្មា, សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលាតិ? ពួកធម៌ណាមួយ មានមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ឈ្មោះថាជាមូលដល់គ្នានិងគ្នាជាមួយនឹង កុសលមូលឬ?

**វិសជ្ជនា** មូលានិ យានិ ឯកតោ ឧប្បជ្ជន្តិ កុសលមូលានិ

ឯកមូលានិ ចេវ អញ្ញមញ្ញមូលានិ ច, អវសេសា កុសលមូល-សហជាតា ធម្មា កុសលមូលេន ឯកមូលា ន ច អញ្ញមញ្ញមូលា។ *កុសលមូលពួកណា កើតឡើងក្នុងគ្រាជាមួយគ្នា កុសលមូលពួកនោះ មានមូលតែមួយ ជាមួយគ្នាផង ឈ្មោះថា ជាមូលដល់គ្នានិងគ្នាផង, ពួកធម៌ដែលកើតព្រមជាមួយនឹងកុសលមូល ដែលនៅសល់ក្រៅពីនោះ មានមូលតែមួយ ជាមួយនឹងកុសលមូល តែមិនឈ្មោះថាជាមូលដល់គ្នានិងគ្នាឡើយ។*

**បដិលោមបុច្ឆា** យេ វា បន កុសលមូលេន អញ្ញមញ្ញមូលា, សព្វេ តេ ធម្មា កុសលាតិ? *ម្យ៉ាងទៀត ពួកធម៌ណា ឈ្មោះថា ជាមូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសលឬ?*

**វិសជ្ជនា** អាមន្តា *មែន។*

# ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យេ កេចិ កុសលមូលេន ឯកមូលា ធម្មា *ជាសន្និដ្ឋានបទ។*

សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលា *ជាសំសយបទ។*

*๏ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៥ (-៣) កុសលចិត្តជរូប ១៧ និងកុសលមូល ៣ ។*

*๏ អត្ថធម៌របស់សំសយបទ បានដល់ កុសលមូល ៣ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ពួកធម៌ណាមួយ មានមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ឈ្មោះថាជាមូលដល់គ្នានិងគ្នាជាមួយនឹង កុសលមូលឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក កុសលមូល ៣ ដែលជា អត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបុរិមកោដ្ឋាសៈ មិនមានការ បដិសេធសំសយបទ ដូចបានសំដែងថា* មូលានិ យានិ ឯកតោ ឧប្បជ្ជន្តិ កុសលមូលានិ ឯកមូលានិ ចេវ

អញ្ញមញ្ញមូលានិ  ច, ហើយទ្រង់លើក យក កុសលចិត្ត ២១ ចេតសិក ៣៥ (វៀរកុសលមូល ៣) កុសលចិត្តជរូប ១៧ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ បានតែម្យ៉ាង ទុកក្នុងបច្ចិមកោដ្ឋាសៈ មានការបដិសេធ សំសយបទ ដូចបានសំដែងថា អវសេសា កុសលមូលសហជាតា ធម្មា កុសលមូលេន ឯកមូលា ច ច អញ្ញមញ្ញមូលា ពាក្យវិសជ្ជនា ក្នុង អនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយអមៈ។

## ក្នុងបដិលោមបុច្ឆា

យេ វា បន កុសលមូលេន អញ្ញមញ្ញមូលា ជាសន្និដ្ឋានបទ ។

សព្វេ តេ ធម្មា កុសលា ជាសំសយបទ។

១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលមូល ៣។

១ អត្ថធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ឆាបញ្ហា សួរថា ម្យ៉ាងទៀត ពួកធម៌ណា ឈ្មោះថា ជាមូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសលឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា អាមន្តា ដែលជាពាក្យវិសជ្ជនាព្រមទទួល អត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា កុសលមូល ៣ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏ជាកុសលផង ៕

**(ចប់មូលន័យ)**

# ខ. មូលមូលន័យ

## ១. មូលយមកៈ

**អនុលោមបុច្ឆា** យេ កេចិ កុសលា ធម្មា, សព្វេ តេ កុសលមូលមូលាតិ? ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ទាំងអស់នោះ ឈ្មោះថាមូល ដែលជាកុសលមូលឬ?

**វិសជ្ជនា** *តីណេវ កុសលមូលមូលានិ, អវសេសា កុសលា ធម្មា ន កុសលមូលមូលា។ អលោភៈ អទោសៈ អមោហៈ តែ ៣ ប៉ុណ្ណោះ ឈ្មោះថាមូល ដែលជាកុសលមូល កុសលធម៌ដែលនៅសល់ក្រៅពីនោះ មិនឈ្មោះថាមូលដែលជាកុសលមូលឡើយ។*

**បដិលោមបុច្ឆា** *យេ វា បន កុសលមូលមូលា, សព្វេ តេ ធម្មា កុសលាតិ? មួយវិញទៀត ពួកធម៌ណា ឈ្មោះថាមូលដែលជា កុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ?*

**វិសជ្ជនា** *អាមន្តា មែន។*

# ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

# ក្នុងអនុលោមបុច្ឆា

*យេ កេចិ កុសលា ធម្មា ជាសន្និដ្ឋានបទ។*

*សព្វេ តេ កុសលមូលមូលា ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៥ (-៣ ) និងកុសលមូល ៣ ។*

*៙ អត្ថធម៌របស់សំសយបទ បានដល់ កុសលមូល ៣ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ទាំងអស់នោះ ឈ្មោះថាមូល ដែលជាកុសលមូលឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក កុសលមូល ៣ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបុរិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **តីណេវ កុសលមូលមូលានិ** *ហើយទ្រង់លើកយក កុសលចិត្ត ២១ ចេតសិក ៣៥ (វៀរកុសលមូល ៣) ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបច្ឆិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **អវសេសា កុសលា**

ធម្មា ច កុសលមូលមូលា ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយអម។

## ក្នុងបដិលោមបុច្ឆា

យេ វា បន កុសលមូលមូលា ជាសន្និដ្ឋានបទ។

សព្វេ តេ ធម្មា កុសលា ជាសំសយបទ។

១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលមូល ៣។

១ អត្ថធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ឆាបញ្ហា សួរថា ម្យ៉ាងទៀត ពួកធម៌ណា ឈ្មោះថាមូលដែលជាកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា កុសលមូល ៣ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏ជាកុសលផង។

## ២. ឯកមូលយមកៈ

**អនុលោមបុច្ឆា** យេ កេចិ កុសលា ធម្មា, សព្វេ តេ កុសលមូលេន ឯកមូលមូលាតិ? ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ទាំងអស់នោះ មានមូល ដែលជាមូលតែមួយ ជាមួយនឹងកុសលមូលឬ?

**វិសជ្ជនា** អាមន្តា មែន។

**បដិលោមបុច្ឆា** យេ វា បន កុសលមូលេន ឯកមូលមូលា, សព្វេ តេ ធម្មា កុសលាតិ? ម្យ៉ាងទៀត ពួកធម៌ណា មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ?

**វិសជ្ជនា** កុសលសមុដ្ឋានំ រូបំ កុសលមូលេន ឯកមូលមូលំ ន កុសលំ, កុសលំ កុសលមូលេន ឯកមូលមូលញ្ចេវ កុសលញ្ច។ រូបដែលមានកុសលជាសមុដ្ឋាន មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូល

តែមិនមែនជាកុសលឡើយ, កុសលធម៌ មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូលផង ជាកុសលផង។

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

**យេ កេចិ កុសលា ធម្មា** ជាសន្និដ្ឋានបទ។

**សព្វេ តេ កុសលមូលេន ឯកមូលមូលា** ជាសំសយបទ។

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨។

៙ អត្ថធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ ទាំងអស់នោះ មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូលឬ? ទើបព្រះអង្គទ្រង់ សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់ សន្និដ្ឋានបទ ព្រោះថា **កុសលចិត្ត ២១ ចេតសិក ៣៨** ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ ទាំងនោះ ក៏មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូលផង។

## ក្នុងបដិលោមបុច្ឆា

**យេ វា បន កុសលមូលេន ឯកមូលមូលា** ជាសន្និដ្ឋានបទ។

**សព្វេ តេ ធម្មា កុសលា** ជាសំសយបទ។

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្តរូប ១៧ និងកុសលចិត្ត ២១ ចេតសិក ៣៨។

៙ អត្ថធម៌របស់សំសយបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត ពួកធម៌ណា មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ?

*ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក* កុសលចិត្តជួប ១៧ *ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* កុសលសមុដ្ឋានំ រូបំ កុសលមូលេន ឯកមូលមូលំ ន កុសលំ *ហើយទ្រង់លើកយក* កុសលចិត្ត ២១ ចេតសិក ៣៨ *ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* កុសលំ កុសលមូលេន ឯកមូលមូលញ្ចេវ កុសលញ្ច *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភត្តិដោយត្រង់ៗ*

## ៣. អញ្ញមញ្ញមូលយមកៈ

**អនុលោមបុច្ឆា** យេ កេចិ កុសលមូលេន ឯកមូលមូលា ធម្មា, សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលាតិ? *ពួកធម៌ណាមួយមានមូល ដែលជាមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ឈ្មោះថាមូល ដែលជាមូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូលឬ?*

**វិសជ្ជនា** មូលានិ យានិ ឯកតោ ឧប្បជ្ជន្តិ កុសលមូលានិ ឯកមូលមូលានិ ចេវ អញ្ញមញ្ញមូលមូលានិ ច, អវសេសា កុសល-មូលសហជាតា ធម្មា កុសលមូលេន ឯកមូលមូលា ន ច អញ្ញ-មញ្ញមូលមូលា។ *កុសលមូលពួកណា កើតឡើងក្នុងគ្រាជាមួយគ្នា កុសលមូលពួកនោះមានមូលដែលជាមូលតែមួយជាមួយគ្នាផង ឈ្មោះថាមូលដែលជាមូលដល់គ្នានិងគ្នាផង, ពួកធម៌ដែលកើតព្រមជាមួយនឹងកុសលមូលដែលនៅសល់ក្រៅពីនោះ មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូល តែមិនឈ្មោះថាមូល ដែលជាមូលដល់គ្នានិងគ្នាឡើយ។*

**បដិលោមបុច្ឆា** យេ វា បន កុសលមូលេន អញ្ញមញ្ញមូល-មូលា, សព្វេ តេ ធម្មា កុសលាតិ? *ម្យ៉ាងទៀត ពួកធម៌ណា ឈ្មោះថា*

មូល ដែលជាមូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ?

**វិសជ្ជនា** អាមន្តា មែន។

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យេ កេចិ កុសលមូលេន ឯកមូលមូលា ធម្មា ជាសន្និដ្ឋានបទ។

សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលា ជាសំសយបទ។

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៥ (-៣ ) កុសលចិត្តជរូប ១៧ និងកុសលមូល ៣ ។

៙ អត្ថធម៌របស់សំសយបទ បានដល់ កុសលមូល ៣ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ពួកធម៌ណាមួយ មានមូល ដែលជា មូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ឈ្មោះថាមូល ដែលជា មូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូលឬ? ទើបព្រះអដ្ឋកថាទ្រង់សំដែងដោយការលើកយក កុសលមូល ៣ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទ បានទាំង ២ ទុកក្នុងបុរិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **មូលានិ យានិ ឯកតោ ឧប្បជ្ជន្តិ កុសលមូលានិ ឯកមូលមូលានិ ចេវ អញ្ញមញ្ញមូលមូលានិ ច** ហើយទ្រង់លើកយក កុសលចិត្ត ២១ ចេតសិក ៣៥ (វៀរកុសលមូល ៣) កុសលចិត្តជរូប ១៧ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ បានតែ ម្យ៉ាង ទុកក្នុងបច្ឆិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អវសេសា កុសលមូលសហជាតា ធម្មា កុសលមូលេន ឯកមូលមូលា ន ច អញ្ញមញ្ញមូលមូលា** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយអម។

## ក្នុងបដិលោមបុច្ឆា

យេ វា បន កុសលមូលេន អញ្ញមញ្ញមូលមូលា *ជាសន្និដ្ឋានបទ។*

សព្វេ តេ ធម្មា កុសលា *ជាសំសយបទ។*

*១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលមូល ៣។*

*១ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត ពួកធម៌ណា ឈ្មោះថាមូលដែលជាមូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ? ទើបព្រះអង្គទ្រង់សំដែងដោយ***បដិវចនវិសជ្ជនា***ថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា* **កុសលមូល ៣** *ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏ជាកុសលផង ។*

**(ចប់មូលមូលន័យ)**

## គ. មូលកន័យ

## ១. មូលយមកៈ

**អនុលោមបុច្ឆា** យេ កេចិ កុសលា ធម្មា, សព្វេ តេ កុសលមូលកាតិ? *ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ទាំងអស់នោះ មានមូលជាកុសលឬ?*

**វិសជ្ជនា** អាមន្តា *មែន។*

**បដិលោមបុច្ឆា** យេ វា បន កុសលមូលកា, សព្វេ តេ ធម្មា កុសលាតិ? *ម្យ៉ាងទៀត ពួកធម៌ណា មានមូលជាកុសល, ពួកធម៌ទាំងអស់ នោះជាកុសលឬ?*

**វិសជ្ជនា** កុសលសមុដ្ឋានំ រូបំ កុសលមូលកំ ន កុសលំ, កុសលំ កុសលមូលកញ្ចេវ កុសលញ្ច។ *រូបដែលមានកុសល ជាសមុដ្ឋាន*

មានមូលជាកុសល តែមិនមែនជាកុសលឡើយ, កុសលធម៌ មានមូលជាកុសលផង ជាកុសលផង។

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

**យេ កេចិ កុសលា ធម្មា** ជាសន្និដ្ឋានបទ។

**សព្វេ តេ កុសលមូលកា** ជាសំសយបទ។

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨។

៙ អត្ថធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បុច្ឆាបញ្ហា** សួរថា ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ ទាំងអស់នោះ មានមូលជាកុសលឬ? ទើបព្រះអង្គទ្រង់សំដែងដោយ **បដិវចនវិសជ្ជនាថា អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់ សន្និដ្ឋានបទ ព្រោះថា **កុសល ចិត្ត ២១ ចេតសិក ៣៨** ដែលជាអត្ថធម៌របស់ សន្និដ្ឋានបទទាំងនោះ ក៏មានមូលជា កុសលផង។

## ក្នុងបដិលោមបុច្ឆា

**យេ វា បន កុសលមូលកា** ជាសន្និដ្ឋានបទ។

**សព្វេ តេ ធម្មា កុសលា** ជាសំសយបទ។

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្តជរូប ១៧ និងកុសលចិត្ត ២១ ចេតសិក ៣៨។

៙ អត្ថធម៌របស់សំសយបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត ពួកធម៌ណា មាន មូលជាកុសល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ? ទើបព្រះអង្គទ្រង់សំដែងដោយ ការលើកយក **កុសលចិត្តជរូប ១៧** ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **កុសលស–**

មុដ្ឋានំ រូបំ កុសលមូលកំ ន កុសលំ *ហើយទ្រង់លើកយកកុសលចិត្ត ២១ ចេតសិក ៣៨ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ចិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **កុសលំ** កុសលមូលកញ្ចេវ កុសលញ្ច *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ*

## ២. ឯកមូលយមកៈ

**អនុលោមបុច្ឆា** យេ កេចិ កុសលា ធម្មា, សព្វេ តេ កុសលមូលេន ឯកមូលកាតិ? *ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ជាមួយនឹងកុសលមូលឬ?*

**វិសជ្ជនា** *អាមន្តា មែនៗ*

**បដិលោមបុច្ឆា** យេ វា បន កុសលមូលេន ឯកមូលកា, សព្វេ តេ ធម្មា កុសលាតិ? *ម្យ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ?*

**វិសជ្ជនា** កុសលសមុដ្ឋានំ រូបំ កុសលមូលេន ឯកមូលកំ ន កុសលំ, កុសលំ កុសលមូលេន ឯកមូលកញ្ចេវ កុសលញ្ច។ *រូបដែលមានកុសលជាសមុដ្ឋាន មានមូលតែមួយ ជាមួយនឹងកុសលមូល តែមិនមែនជាកុសលឡើយ, កុសលធម៌ មានមូលតែមួយជាមួយនឹងកុសលមូលផង ជាកុសលផង។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យេ កេចិ កុសលា ធម្មា *ជាសន្និដ្ឋានបទ។*

សព្វេ តេ កុសលមូលេន ឯកមូលកា *ជាសំសយបទ។*

*១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨។*

៙ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ ទាំងអស់នោះ មានមូលតែមួយ ជាមួយនឹងកុសលមូលឬ? ទើបព្រះអង្គទ្រង់សំដែង ដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា **កុសលចិត្ត ២១ ចេតសិក ៣៨** ដែលជាអន្តធម៌របស់សន្និដ្ឋានបទ ទាំងនោះ ក៏មានមូលតែមួយជាមួយនឹងកុសលមូលផង។

## ក្នុងបដិលោមបុច្ឆា

**យេ វា បន កុសលមូលេន ឯកមូលកា** ជាសន្និដ្ឋានបទ។

**សព្វេ តេ ធម្មា កុសលា** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្តរូប ១៧ និងកុសលចិត្ត ២១ ចេតសិក ៣៨។

៙ អន្តធម៌របស់សំសយបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក **កុសលចិត្តជរូប ១៧** ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **កុសលសមុដ្ឋានំ រូបំ កុសលមូលេន ឯកមូលកំ ន កុសលំ,** ហើយទ្រង់លើកយក **កុសលចិត្ត ២១ ចេតសិក ៣៨** ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និងសំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **កុសលំ កុសលមូលេន ឯកមូលកញ្ចេវ កុសលញ្ច** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជា**សរូបទស្សនវិសជ្ជនា** ដែលមានវិកន្តដោយត្រង់។

## ៣. អញ្ញមញ្ញមូលយមកៈ

**អនុលោមបុច្ឆា** យេ កេចិ កុសលមូលេន ឯកមូលកា ធម្មា, សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលកាតិ? *ពួកធម៌ណាមួយ មានមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ មានមូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូលឬ?*

**វិសជ្ជនា** មូលានិ យានិ ឯកតោ ឧប្បជ្ជន្តិ កុសលមូលានិ ឯកមូលកានិ ចេវ អញ្ញមញ្ញមូលកានិ ច, អវសេសា កុសល-មូលសហជាតា ធម្មា កុសលមូលេន ឯកមូលកា ន ច អញ្ញមញ្ញមូលកា។ *កុសលមូលពួកណា កើតឡើងក្នុងគ្រាជាមួយគ្នា កុសលមូលពួកនោះ មានមូលតែមួយ ជាមួយគ្នាផង មានមូលដល់គ្នានិងគ្នាផង, ពួកធម៌ដែលកើតព្រមជាមួយនឹងកុសលមូលដែលនៅសល់ក្រៅពីនោះ មានមូលតែមួយ ជាមួយនឹងកុសលមូល តែមិនមានមូលដល់គ្នានិងគ្នាឡើយ។*

**បដិលោមបុច្ឆា** យេ វា បន កុសលមូលេន អញ្ញមញ្ញ-មូលកា, សព្វេ តេ ធម្មា កុសលាតិ? *ម្យ៉ាងទៀត ពួកធម៌ណា មានមូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ?*

**វិសជ្ជនា** អាមន្តា *មែន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ
## ក្នុងអនុលោមបុច្ឆា

យេ កេចិ កុសលមូលេន ឯកមូលកា ធម្មា *ជាសន្និដ្ឋានបទ។*

សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលកា *ជាសំសយបទ។*

*១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៥ (-៣) កុសលចិត្តជរូប ១៧ និងកុសលមូល ៣ ។*

๏ អន្តធម៌របស់សំសយបទ បានដល់ កុសលមូល ៣ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ពួកធម៌ណាមួយ មានមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ មានមូលដល់គ្នានិងគ្នា ជាមួយនឹងកុសលមូល ឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក **កុសលមូល ៣** ដែលជាអន្តធម៌របស់ សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបុរិមកោដ្ឋាសៈ មិនមានការបដិសេធ សំសយបទ ដូចបានសំដែងថា **មូលានិ យានិ ឯកតោ ឧប្បជ្ជន្តិ កុសលមូលានិ ឯកមូលកានិ ចេវ អញ្ញមញ្ញមូលកានិ ច,** ហើយទ្រង់ លើកយក **កុសលចិត្ត ២១ ចេតសិក ៣៥ (វៀរកុសលមូល ៣) កុសលចិត្តជរូប ១៧** ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុង បច្ឆិមកោដ្ឋាសៈ មានការបដិសេធ សំសយបទ ដូចបានសំដែងថា **អវសេសា កុសលមូលសហជាតា ធម្មា កុសលមូលេន ឯកមូលកា ន ច អញ្ញមញ្ញមូលកា** ពាក្យវិសជ្ជនា ក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយអម។

## ក្នុងបដិលោមបុច្ឆា

**យេ វា បន កុសលមូលេន អញ្ញមញ្ញមូលកា** ជាសន្និដ្ឋានបទ។

**សព្វេ តេ ធម្មា កុសលា** ជាសំសយបទ។

๏ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កុសលមូល ៣។

๏ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ឆាបញ្ហា** សួរថា ម្យ៉ាងទៀត ពួកធម៌ណា មានមូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា កុសលមូល ៣ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏ជាកុសលផង ៕

**(ចប់មូលកន័យ)**

# ឃ. មូលមូលកនយ័

## ១. មូលយមក:

**អនុលោមបុច្ឆា** យេ កេចិ កុសលា ធម្មា, សព្វេ តេ កុសលមូលមូលកាតិ? *ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ទាំងអស់នោះ មានមូល ដែលជាកុសលមូលឬ?*

**វិសជ្ជនា** *អាមន្តា មែន។*

**បដិលោមបុច្ឆា** យេ វា បន កុសលមូលមូលកា, សព្វេ តេ ធម្មា កុសលាតិ? *ម្យ៉ាងទៀត ពួកធម៌ណា មានមូលដែលជាកុសលមូល, ពួកធម៌ ទាំងអស់នោះ ជាកុសលឬ?*

**វិសជ្ជនា** កុសលសមុដ្ឋានំ រូបំ កុសលមូលមូលកំ ន កុសលំ, កុសលំ កុសលមូលមូលកញ្ចេវ កុសលញ្ច។ *រូបដែលមានកុសលជាសមុដ្ឋាន មានមូលដែលជាកុសលមូល តែមិនមែនជាកុសលឡើយ, កុសលធម៌ មានមូលដែលជាកុសលមូលផង ជាកុសលផង។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យេ កេចិ កុសលា ធម្មា *ជាសន្និដ្ឋានបទ។*

សព្វេ តេ កុសលមូលមូលកា *ជាសំសយបទ។*

*◉ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨។*

*◉ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជា*បុច្ឆាបញ្ហា *សួរថា ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ ទាំងអស់នោះ មានមូលដែលជាកុសលមូលឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ*

ព្រោះថា កុសលចិត្ត ២១ ចេតសិក ៣៨ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏មានមូល ដែលជាកុសលមូលផង។

## ក្នុងបដិលោមបុច្ឆា

**យេ វា បន កុសលមូលមូលកា** ជាសន្និដ្ឋានបទ។

**សព្វេ តេ ធម្មា កុសលា** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ និង កុសលចិត្តជរូប ១៧។

៙ អន្តធម៌របស់សំសយបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត ពួកធម៌ណា មាន មូលដែលជាកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ? ទើបព្រះអង្គទ្រង់សំដែង ដោយការលើកយក **កុសលចិត្តជរូប ១៧** ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **កុសល-សមុដ្ឋានំ រូបំ កុសលមូលមូលកំ ន កុសលំ** ហើយទ្រង់លើកយក **កុសលចិត្ត ២១ ចេតសិក ៣៨** ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទ បានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **កុសលំ កុសលមូលមូលកញ្ចេវ កុសលញ្ច** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆា នេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្ពដោយត្រង់។

## ២. ឯកមូលយមកៈ

**អនុលោមបុច្ឆា យេ កេចិ កុសលា ធម្មា, សព្វេ តេ កុសលមូលេន ឯកមូលមូលកាតិ?** ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ទាំងអស់ នោះ មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូលឬ?

**វិសជ្ជនា អាមន្តា** មែន។

**បដិលោមបុច្ឆា** យេ វា បន កុសលមូលេន ឯកមូលមូលកា, សព្វេ តេ ធម្មា កុសលាតិ? *ម្យ៉ាងទៀត ពួកធម៌ណា មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ?*

**វិសជ្ជនា** កុសលសមុដ្ឋានំ រូបំ កុសលមូលេន ឯកមូលមូលកំ ន កុសលំ, កុសលំ កុសលមូលេន ឯកមូលមូលកញ្ចេវ កុសលញ្ច។ *រូបដែលមានកុសលជាសមុដ្ឋាន មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូល តែមិនមែនជាកុសលឡើយ, កុសលធម៌ មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូលផង ជាកុសលផង។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យេ កេចិ កុសលា ធម្មា *ជាសន្និដ្ឋានបទ។*

សព្វេ តេ កុសលមូលេន ឯកមូលមូលកា *ជាសំសយបទ។*

*๏ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨។*

*๏ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ឆាបញ្ហា សួរថា ពួកធម៌ណាមួយ ជាកុសល, ពួកធម៌ ទាំងអស់នោះ មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូលឬ? ទើបព្រះអង្គ ទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនា ព្រមទទួលអត្ថធម៌ របស់សន្និដ្ឋានបទ ព្រោះថា* **កុសលចិត្ត ២១ ចេតសិក ៣៨** *ដែលជាអត្ថធម៌របស់ សន្និដ្ឋានបទទាំងនោះ ក៏មានមូលដែលជាមូលតែមួយជាមួយនឹងកុសលមូលផង។*

## ក្នុងបដិលោមបុច្ឆា

យេ វា បន កុសលមូលេន ឯកមូលមូលកា *ជាសន្និដ្ឋានបទ។*

**សព្វេ តេ ធម្មា កុសលា** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្តជួរូប ១៧ និងកុសលចិត្ត ២១ ចេតសិក ៣៨។

៙ អន្តធម៌របស់សំសយបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៨ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត ពួកធម៌ណា មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក កុសលចិត្តជួរូប ១៧ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **កុសលសមុដ្ឋានំ រូបំ កុសលមូលេន ឯកមូលមូលកំ ន កុសលំ** ហើយទ្រង់លើកយក **កុសលចិត្ត ២១ ចេតសិក ៣៨** ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **កុសលំ កុសលមូលេន ឯកមូលមូលកញ្ចេវ កុសលញ្ច** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកន្តដោយត្រង់។

## ៣. អញ្ញមញ្ញមូលយមក:

**អនុលោមបុច្ឆា** យេ កេចិ កុសលមូលេន ឯកមូលមូលកា ធម្មា, សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលកាតិ? ពួកធម៌ណា មានមូលដែលជាមូលតែមួយ ជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ មានមូលដែលជាមូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូលឬ ?

**វិសជ្ជនា** មូលានិ យានិ ឯកតោ ឧប្បជ្ជន្តិ កុសលមូលានិ ឯកមូលមូលកានិ ចេវ អញ្ញមញ្ញមូលមូលកានិ ច, អវសេសា កុសលមូលសហជាតា ធម្មា កុសលមូលេន ឯកមូលមូលកា ន ច អញ្ញមញ្ញមូលមូលកា។ កុសលមូលពួកណា កើតឡើងក្នុងគ្រាជាមួយគ្នា កុសល-

*មូលពួកនោះ មានមូលដែលជាមូលតែមួយជាមួយគ្នាផង មានមូលដែលជាមូលដល់គ្នានិងគ្នាផង, ពួកធម៌ដែលកើតព្រមជាមួយនឹងកុសលមូលដែលនៅសល់ក្រៅពីនោះ មានមូលដែលជាមូលតែមួយជាមួយនឹងកុសលមូល តែមិនមានមូល ដែលជាមូលដល់គ្នានិងគ្នាឡើយ។*

**បដិលោមបុច្ឆា** យេ វា បន កុសលមូលេន អញ្ញមញ្ញមូល-មូលកា, សព្វេ តេ ធម្មា កុសលាតិ? *ម្យ៉ាងទៀត ពួកធម៌ណា មានមូលដែលជាមូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ?*

**វិសជ្ជនា** *អាមន្តា មែន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យេ កេចិ កុសលមូលេន ឯកមូលមូលកា ធម្មា *ជាសន្និដ្ឋានបទ។*

សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលកា *ជាសំសយបទ។*

*๑ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលចិត្ត ២១ ចេតសិក ៣៥ (-៣ ) កុសលចិត្តជរូប ១៧ និងកុសលមូល។*

*๑ អត្ថធម៌របស់សំសយបទ បានដល់ កុសលមូល ៣ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ពួកធម៌ណាមួយមានមូលដែលជា មូលតែមួយជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះមានមូលដែលជាមូលដល់គ្នា និងគ្នាជាមួយនឹងកុសលមូលឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក កុសលមូល ៣ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និងសំសយបទបានទាំង ២ ទុកក្នុងបុរិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទដូចបានសំដែងថា* មូលានិ យានិ ឯកតោ ឧប្បជ្ជន្តិ កុសលមូលានិ ឯកមូលមូលកានិ ចេវ អញ្ញមញ្ញមូលមូលកានិ ច *ហើយទ្រង់លើកយកកុសលចិត្ត ២១ ចេតសិក ៣៥ (វៀរកុសលមូល ៣) កុសលចិត្តជរូប ១៧*

*ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបច្ឆិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **អវសេសា កុសលមូលសហជាតា ធម្មា កុសលមូលេន ឯកមូលមូលកា ន ច អញ្ញមញ្ញមូលមូលកា** *ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្ប ដោយអម។*

## ក្នុងបដិលោមបុច្ឆា

**យេ វា បន កុសលមូលេន អញ្ញមញ្ញមូលមូលកា** *ជាសន្និដ្ឋានបទ។*

**សព្វេ តេ ធម្មា កុសលា** *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កុសលមូល ៣។*

*៙ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជា***បច្ចាបញ្ហា** *សួរថា ម្យ៉ាងទៀត ពួកធម៌ណា មានមូលដែលជាមូលដល់គ្នានិងគ្នាជាមួយនឹងកុសលមូល, ពួកធម៌ទាំងអស់នោះ ជាកុសលឬ? ទើបព្រះអង្គទ្រង់សំដែងដោយ***បដិវចនវិសជ្ជនា***ថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា* **កុសលមូល ៣** *ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏ជាកុសលផង។*

**(ចប់មូលមូលកន័យ)**

**( ចប់កុសលបទ)**

# តារាងសង្ខេប

| ឈ្មោះយមកៈ / ឈ្មោះន័យ | សរុបមូលវារៈ: ក្នុងកុសលបទ | | |
|---|---|---|---|
| | **១. មូលយមកៈ** | **២. ឯកមូលយមកៈ** | **៣. អញ្ញមញ្ញមូលយមកៈ** |
| ក. មូលន័យ | *អនុ.បុ. <u>កុ.២១,ចេ.៣៥(-កុ.មូល៣)</u> +៣*<br>*បដិ.បុ. អា ៣* | *អនុ.បុ. អា កុ.២១, ចេ. ៣៨*<br>*បដិ.បុ. <u>កុ.ចិរុ.១៧</u> +កុ.២១,ចេ. ៣៨* | *អនុ.បុ. <u>កុ.២១,ចេ.៣៥(-កុ.មូល៣), កុ.ចិរុ.១៧</u>+៣*<br>*បដិ.បុ. អា ៣* |
| ខ. មូលមូលន័យ | ↓ | | ↓ |
| គ. មូលកន័យ | ↑ | | |
| ឃ. មូលមូលកន័យ | | | ↓ |

**បញ្ជាក់** = អក្សរដែលមានបន្ទាត់ពីក្រោម ជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង។

# អត្ថធម៌មូលយមកៈ ក្នុងអកុសលបទ

*អកុសលា ធម្មា* **= ពួកធម៌ជាអកុសល។**

*៙ អត្ថធម៌ បានដល់ អកុសលចិត្ត ១២ ចេតសិក ២៧។*

*អកុសលមូលា* **= ឈ្មោះថាអកុសលមូល។**

*៙ អត្ថធម៌ បានដល់ អកុសលមូល ៣។*

*អកុសលមូលមូលា* **= ឈ្មោះថាមូលដែលជាអកុសលមូល។**

*៙ អត្ថធម៌ បានដល់ អកុសលមូល ៣។*

*អកុសលមូលេន ឯកមូលា* **= មានមូលតែមួយ ជាមួយនឹងអកុសលមូល។**

*៙ អត្ថធម៌ បានដល់ អកុសលចិត្ត ១២ ចេតសិក ២៧ អកុសលចិត្តជួរបូ ១៧ (វៀរមោហចេតសិក ដែលនៅក្នុងមោហមូលចិត្ត ២)។*

*អកុសលមូលេន ឯកមូលមូលា* **= មានមូលដែលជាមូលតែមួយ ជាមួយនឹងអកុសលមូល។**

*៙ អត្ថធម៌ បានដល់ អកុសលចិត្ត ១២ ចេតសិក ២៧ អកុសលចិត្តជួរបូ ១៧ (វៀរមោហចេតសិក ដែលនៅក្នុងមោហមូលចិត្ត ២)។*

*អកុសលមូលេន អញ្ញមញ្ញមូលា* **= ឈ្មោះថាជាមូលដល់គ្នានិងគ្នា ជាមួយនឹងអកុសលមូល។**

*៙ អត្ថធម៌ បានដល់ អកុសលមូល ៣ (វៀរមោហចេតសិក ដែលនៅក្នុងមោហមូលចិត្ត ២)។*

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធធ្លាប់កើតដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏ធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក តិហេតុកបុថុជ្ជន ១ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ និងអរូបភូមិ៤ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អរូបានំ តេសំ តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិត្ថ នោ ច តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជិត្ថ** ហើយទ្រង់លើកយកបុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការានំ តេសំ តត្ថ វេទនាក្ខន្ធោ ច ឧប្បជ្ជិត្ថ រូបក្ខន្ធោ ច ឧប្បជ្ជិត្ថ** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភង្គដោយត្រង់។

**(មូលីដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ វេទនាខន្ធោ ឧប្បជ្ជិត្ថ, តស្ស តត្ថ សញ្ញាខន្ធោ ឧប្បជ្ជិត្ថាតិ? *វេទនាខន្ធធ្លាប់កើតដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏ធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

**បដិលោមបុច្ឆាៈ** យស្ស វា បន យត្ថ សញ្ញាខន្ធោ ឧប្បជ្ជិត្ថ, តស្ស តត្ថ វេទនាខន្ធោ ឧប្បជ្ជិត្ថាតិ? *ម្យ៉ាងទៀត សញ្ញាខន្ធធ្លាប់កើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏ធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ វេទនាខន្ធោ ឧប្បជ្ជិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស តត្ថ សញ្ញាខន្ធោ ឧប្បជ្ជិត្ថ *ជាសំសយបទ។*

*๏ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។*

*๏ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចុប្បន្នបញ្ហា សួរថា វេទនាខន្ធធ្លាប់កើតដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏ធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុង*

ចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏ធ្លាប់កើតផង។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាខន្ធោ ឧប្បជ្ជិត្ថ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ វេទនាខន្ធោ ឧប្បជ្ជិត្ថ** ជាសំសយបទ។

១ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។

១ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចបញ្ហា សួរថា សញ្ញាខន្ធធ្លាប់កើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏ធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌ របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏ធ្លាប់កើតផង៕

**(មូលី មូលៈដែលនៅសល់ក៏សំដែងរបៀបគ្នា)**

**( ចប់ បុគ្គលោកាសវារៈ)**

**(ចប់ ឧប្បាទវារៈ អតីតវារៈ អនុលោម)**

# បវត្តិវារៈ ឧប្បាទវារៈ អតីតវារៈ បច្ចនីកៈ បុគ្គលវារៈ

## (រ. ន. ២ ច. ឍ.)

## ឥ. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យស្ស រូបក្ខន្ធោ នុប្បជ្ជិត្ថ, តស្ស វេទនាក្ខន្ធោ នុប្បជ្ជិត្ថាតិ? *រូបក្ខន្ធមិនធ្លាប់កើតដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** នត្ថិ *មិនមាន។*

**បដិលោមបុច្ឆាៈ** យស្ស វា បន វេទនាក្ខន្ធោ នុប្បជ្ជិត្ថ, តស្ស រូបក្ខន្ធោ នុប្បជ្ជិត្ថាតិ? *ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់កើតដល់បុគ្គលណា, រូបក្ខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** នត្ថិ *មិនមាន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស រូបក្ខន្ធោ នុប្បជ្ជិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស វេទនាក្ខន្ធោ នុប្បជ្ជិត្ថ *ជាសំសយបទ។*

*១ អត្ថធម៌របស់សន្និដ្ឋានបទ មិនមាន កាលបើអត្ថធម៌របស់សន្និដ្ឋានបទ មិនមានហើយ អត្ថធម៌របស់សំសយបទ ក៏មិនមានដូចគ្នា ។*

*ដូច្នេះ ពាក្យសួរបទនេះ ជាមោឃបញ្ហា សួរថា រូបក្ខន្ធមិនធ្លាប់កើតដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិក្ខេបវិសជ្ជនាថា* នត្ថិ *ដែលជាពាក្យវិសជ្ជនាហាមអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា*

ពួកបុគ្គលដែលរូបក្ខន្ធ មិនធ្លាប់កើតក្នុងភពផ្សេងៗនោះ មិនមាន មានតែពួកបុគ្គលដែលរូបក្ខន្ធ ធ្លាប់កើតមកហើយ ទាំងអស់ ។

## ក្នុងបដិលោមបុច្ឆា

យស្ស វា បន វេទនាក្ខន្ធោ នុប្បជ្ជិត្ថ ជាសន្និដ្ឋានបទ ។

តស្ស រូបក្ខន្ធោ នុប្បជ្ជិត្ថ ជាសំសយបទ ។

๑ អត្ថធម៌របស់សន្និដ្ឋានបទ មិនមាន កាលបើអត្ថធម៌របស់សន្និដ្ឋានបទ មិនមានហើយ អត្ថធម៌របស់សំសយបទ ក៏មិនមានដូចគ្នា ។

ដូច្នេះ ពាក្យសួរបទនេះ ជា **មោឃបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់កើតដល់បុគ្គលណា, រូបក្ខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ **បដិក្ខេបវិសជ្ជនា**ថា **នត្ថិ** ដែលជាពាក្យវិសជ្ជនាហាមអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថាពួកបុគ្គលដែលវេទនាខន្ធមិនធ្លាប់កើតក្នុងភពផ្សេងៗនោះ មិនមាន មានតែពួកបុគ្គលដែល វេទនាខន្ធធ្លាប់កើតមកហើយទាំងអស់ ។

**(មូលីដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យស្ស វេទនាក្ខន្ធោ នុប្បជ្ជិត្ថ, តស្ស សញ្ញាក្ខន្ធោ នុប្បជ្ជិត្ថាតិ? វេទនាខន្ធមិនធ្លាប់កើតដល់បុគ្គលណា, សញ្ញាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះឬ?

**វិសជ្ជនាៈ** នត្ថិ មិនមាន ។

**បដិលោមបុច្ឆាៈ** យស្ស វា បន សញ្ញាក្ខន្ធោ នុប្បជ្ជិត្ថ, តស្ស វេទនាក្ខន្ធោ នុប្បជ្ជិត្ថាតិ? ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់កើតដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះឬ?

**វិសជ្ជនា:** នត្ថិ *មិនមាន។*

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

### ក្នុងអនុលោមបុច្ឆា

យស្ស វេទនាខន្ធោ នុប្បជ្ជិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស សញ្ញាខន្ធោ នុប្បជ្ជិត្ថ *ជាសំសយបទ។*

*១ អន្តធម៌របស់សន្និដ្ឋានបទ មិនមាន កាលបើអន្តធម៌របស់សន្និដ្ឋានបទ មិនមាន ហើយ អន្តធម៌របស់សំសយបទ ក៏មិនមានដូចគ្នា ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា* មោឃបញ្ហា *សួរថា។ល។*

### ក្នុងបដិលោមបុច្ឆា

យស្ស វា បន សញ្ញាខន្ធោ នុប្បជ្ជិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស វេទនាខន្ធោ នុប្បជ្ជិត្ថ *ជាសំសយបទ។*

*១ អន្តធម៌របស់សន្និដ្ឋានបទ មិនមាន កាលបើអន្តធម៌របស់សន្និដ្ឋានបទមិនមាន ហើយ អន្តធម៌របស់សំសយបទ ក៏មិនមានដូចគ្នា ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា* មោឃបញ្ហា *សួរថា។ល។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់បុគ្គលវារៈ)**

# បវត្តិវារៈ ឧប្បាទវារៈ អតីតវារៈ បច្ចនីកៈ ឱកាសវារៈ

## (វំ. ឧ. ២ ច. ឱ.)

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យត្ថ រូបក្ខន្ធោ ន ឧប្បជ្ជិត្ថ, តត្ថ វេទនាក្ខន្ធោ នុប្បជ្ជិត្ថាតិ? *រូបក្ខន្ធមិនធ្លាប់កើតក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់កើត ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** ឧប្បជ្ជិត្ថ *ធ្លាប់កើត។*

**បដិលោមបុច្ឆាៈ** យត្ថ វា បន វេទនាក្ខន្ធោ នុប្បជ្ជិត្ថ, តត្ថ រូបក្ខន្ធោ នុប្បជ្ជិត្ថាតិ? *ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់កើតក្នុងភូមិណា, រូបក្ខន្ធក៏មិនធ្លាប់កើតក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** ឧប្បជ្ជិត្ថ *ធ្លាប់កើត។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យត្ថ រូបក្ខន្ធោ នុប្បជ្ជិត្ថ *ជាសន្និដ្ឋានបទ។*

តត្ថ វេទនាក្ខន្ធោ នុប្បជ្ជិត្ថ *ជាសំសយបទ។*

*◉ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤។*

*◉ អត្ថធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា រូបក្ខន្ធមិនធ្លាប់កើតក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់កើតក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ***បាឡិគតិវិសជ្ជនា***ថា* ឧប្បជ្ជិត្ថ *ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អរូបភូមិ ៤ ដែលជាទីកើត*

នៃនាមក្ខន្ធ ៤ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីរូបក្ខន្ធមិនជាប់កើត តែវេទនាខន្ធជាប់កើត។

**ក្នុងបដិលោមបុច្ឆា**

**យត្ថ វា បន វេទនាក្ខន្ធោ ន ុប្បជ្ជិត្ថ** ជាសន្និដ្ឋានបទ។

**តត្ថ រូបក្ខន្ធោ ន ុប្បជ្ជិត្ថ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។

៙ អន្តធម៌របស់សំសយបទ មិនមាន។

ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធមិនជាប់កើតក្នុងភូមិណា, រូបក្ខន្ធក៏មិនជាប់កើតក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបាឡិគតិវិសជ្ជនាថា **ឧប្បជ្ជិត្ថ** ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីវេទនាខន្ធមិនជាប់កើត តែរូបក្ខន្ធជាប់កើត។

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់រូបក្ខន្ធមូលៈ)**

## ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយចកៈ

**អនុលោមបុច្ឆា៖** យត្ថ វេទនាក្ខន្ធោ ន ុប្បជ្ជិត្ថ, តត្ថ សញ្ញាក្ខន្ធោ ន ុប្បជ្ជិត្ថាតិ? វេទនាខន្ធមិនជាប់កើតក្នុងភូមិណា, សញ្ញាខន្ធក៏មិនជាប់កើតក្នុងភូមិនោះឬ?

**វិសជ្ជនា៖** អាមន្តា មែន។

**បដិលោមបុច្ឆា៖** យត្ថ វា បន សញ្ញាក្ខន្ធោ ន ុប្បជ្ជិត្ថ, តត្ថ

*វេទនាខន្ធោ ឧប្បជ្ជិត្ថាតិ? ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់កើតក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់កើតក្នុងភូមិនោះឬ?*

**វិសជ្ជនា:** **អាមន្តា** *មែន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

**យត្ថ វេទនាខន្ធោ ន ឧប្បជ្ជិត្ថ** *ជាសន្និដ្ឋានបទ។*

**តត្ថ សញ្ញាខន្ធោ ន ឧប្បជ្ជិត្ថ** *ជាសំសយបទ។*

*๏ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។*

*๏ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា វេទនាខន្ធមិនធ្លាប់កើតក្នុងភូមិណា, សញ្ញាខន្ធក៏មិនធ្លាប់កើតក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏មិនធ្លាប់កើតផង។*

## ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន សញ្ញាខន្ធោ ន ឧប្បជ្ជិត្ថ** *ជាសន្និដ្ឋានបទ។*

**តត្ថ វេទនាខន្ធោ ន ឧប្បជ្ជិត្ថ** *ជាសំសយបទ។*

*๏ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។*

*๏ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់កើតក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់កើតក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* ***អាមន្តា*** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏មិនធ្លាប់កើតផង។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ឱកាសវារៈ)**

# បវត្តិវារៈ ឧប្បាទវារៈ អតីតវារៈ បច្ចនីកៈ បុគ្គលោកាសវារៈ

**(វំ. ឧ. ២ ច. លោ.)**

## ក. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា** យស្ស យត្ថ រូបក្ខន្ធោ នុប្បជ្ជិត្ថ, តស្ស តត្ថ វេទនាក្ខន្ធោ នុប្បជ្ជិត្ថាតិ? *រូបក្ខន្ធមិនធ្លាប់កើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា** អរូបានំ តេសំ តត្ថ រូបក្ខន្ធោ នុប្បជ្ជិត្ថ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ នុប្បជ្ជិត្ថ, សុទ្ធាវាសានំ តេសំ តត្ថ រូបក្ខន្ធោ ច នុប្បជ្ជិត្ថ វេទនាក្ខន្ធោ ច នុប្បជ្ជិត្ថ។ *ពួកបុគ្គលដែលកើតនៅក្នុងអរូបភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធមិនធ្លាប់កើត តែវេទនាខន្ធធ្លាប់កើតដល់បុគ្គលពួកនោះក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងសុទ្ធាវាសភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធក៏មិនធ្លាប់កើត វេទនាខន្ធ ក៏មិនធ្លាប់កើត។*

**បដិលោមបុច្ឆា** យស្ស វា បន យត្ថ វេទនាក្ខន្ធោ នុប្បជ្ជិត្ថ, តស្ស តត្ថ រូបក្ខន្ធោ នុប្បជ្ជិត្ថាតិ? *ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់កើតដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា** អសញ្ញសត្តានំ តេសំ តត្ថ វេទនាក្ខន្ធោ នុប្បជ្ជិត្ថ នោ ច តេសំ តត្ថ រូបក្ខន្ធោ នុប្បជ្ជិត្ថ, សុទ្ធាវាសានំ តេសំ តត្ថ វេទនាក្ខន្ធោ ច នុប្បជ្ជិត្ថ រូបក្ខន្ធោ ច នុប្បជ្ជិត្ថ។ *ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធមិនធ្លាប់កើត តែរូបក្ខន្ធធ្លាប់កើតដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងសុទ្ធាវាសភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធ ក៏មិនធ្លាប់កើត រូបក្ខន្ធក៏មិនធ្លាប់កើត។*

## ការសំដែងអង្គធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ រូបក្ខន្ធោ នុប្បជ្ជិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស តត្ថ វេទនាក្ខន្ធោ នុប្បជ្ជិត្ថ *ជាសំសយបទ។*

*៙ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ តិហេតុកបុថុជ្ជន ១ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ និងអរូបភូមិ ៤,*

*និង អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥។*

*៙ អង្គធម៌របស់សំសយបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា រូបក្ខន្ធមិនធ្លាប់កើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក តិហេតុកបុថុជ្ជន ១ ផលបុគ្គល ៤ ដែលកំពុងកើត និង*

កំពុងស្លាប់ក្នុងអរូបភូមិ និងអរូបភូមិ ៤ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អរូបានំ តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជិត្ថ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិត្ថ** ហើយទ្រង់លើកយក អនាគាមីបុគ្គល ១ ដែលកំពុងកើត ក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទ បានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសានំ តេសំ តត្ថ រូបក្ខន្ធោ ច ឧប្បជ្ជិត្ថ វេទនាក្ខន្ធោ ច ឧប្បជ្ជិត្ថ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកត្តដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិត្ថ** ជាសន្និដ្ឋានបទៗ

**តស្ស តត្ថ រូបក្ខន្ធោ ឧប្បជ្ជិត្ថ** ជាសំសយបទៗ

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១,

**និង** អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥ៗ

៙ អត្ថធម៌របស់សំសយបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥ ប៉ុណ្ណោះៗ

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់កើតដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធ ក៏មិនធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត

*និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបាន សំដែងថា* **អសញ្ញសត្តានំ តេសំ តត្ថ វេទនាខន្ធោ នុប្បជ្ជិត្ថ នោ ច តេសំ តត្ថ រូបក្ខន្ធោ នុប្បជ្ជិត្ថ** *ហើយទ្រង់លើកយកអនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥ ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **សុទ្ធាវាសានំ តេសំ តត្ថ វេទនាខន្ធោ ច នុប្បជ្ជិត្ថ រូបក្ខន្ធោ ច នុប្បជ្ជិត្ថ**, *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភង្គដោយត្រង់ៗ*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់រូបក្ខន្ធមូលះ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ វេទនាខន្ធោ នុប្បជ្ជិត្ថ, តស្ស តត្ថ សញ្ញាខន្ធោ នុប្បជ្ជិត្ថាតិ? *វេទនាខន្ធមិនធ្លាប់កើតដល់បុគ្គលណា ក្នុងភូមិ ណា, សញ្ញាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

**បដិលោមបុច្ឆាៈ** យស្ស វា បន យត្ថ សញ្ញាខន្ធោ នុប្បជ្ជិត្ថ, តស្ស តត្ថ វេទនាខន្ធោ នុប្បជ្ជិត្ថាតិ? *ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់កើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

# ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

**យស្ស យត្ថ វេទនាខន្ធោ ឧប្បជ្ជិត្ថ** *ជាសន្និដ្ឋានបទ។*

**តស្ស តត្ថ សញ្ញាខន្ធោ ឧប្បជ្ជិត្ថ** *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥,*

*សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១។*

*៙ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា វេទនាខន្ធ មិនធ្លាប់កើតដល់បុគ្គលណាក្នុងភូមិណា, សញ្ញាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និងកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធ ក៏មិន ធ្លាប់កើតផង។*

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាខន្ធោ ឧប្បជ្ជិត្ថ** *ជាសន្និដ្ឋានបទ។*

**តស្ស តត្ថ វេទនាខន្ធោ ឧប្បជ្ជិត្ថ** *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥,*

*សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និង អសញ្ញសត្តភូមិ ១។*

*១ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា ម្យ៉ាងទៀត សញ្ញាខន្ធ មិនធ្លាប់កើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធ ក៏មិនធ្លាប់កើតផង។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់បុគ្គលោកាសវារៈ)**

## (ចប់ ឧប្បាទវារៈ អតីតវារៈ បច្ចនីកៈ)

# អក្សរកាត់ និង និមិត្តសញ្ញាក្នុងខន្ធយមកៈ បវត្តិវារៈ

បឧ = បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ = ពួកបុគ្គលដែលកំពុងកើត ក្នុងបញ្ចវោការភូមិ។

អឧ = អរូបំ ឧបបជ្ជន្តានំ តេសំ = ពួកបុគ្គលដែលកំពុងកើតក្នុងអរូបភូមិ។

ញឧ = អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ = ពួកបុគ្គលដែលកំពុងកើត ក្នុងអសញ្ញសត្តភូមិ។

តុបឧ = ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ = ពួកបុគ្គលដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ។

សុឧ = សុទ្ធាវាសំ ឧបបជ្ជន្តានំ តេសំ តត្ថ = ពួកបុគ្គលដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ក្នុងភូមិនោះ។ (មានក្នុងបុគ្គលោកាសវារៈតែម៉្យាង)។

សំឧ = សព្វេសំ ឧបបជ្ជន្តានំ តេសំ = ពួកបុគ្គលទាំងអស់ដែលកំពុង កើតក្នុង ៣១ ភូមិ។

បច = បញ្ចវោការា ចវន្តានំ តេសំ = ពួកបុគ្គលដែលកំពុងស្លាប់ ក្នុងបញ្ចវោការភូមិ។

អច = អរូបា ចវន្តានំ តេសំ = ពួកបុគ្គលដែលកំពុងស្លាប់ក្នុងអរូបភូមិ។

ញច = អសញ្ញសត្តា ចវន្តានំ តេសំ = ពួកបុគ្គលដែលកំពុងស្លាប់ ក្នុងអសញ្ញសត្តភូមិ។

តុបច = ចតុវោការា បញ្ចវោការា ចវន្តានំ តេសំ = បុគ្គលដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ។

សំច = សព្វេសំ ចវន្តានំ តេសំ = ពួកបុគ្គលទាំងអស់ដែលកំពុងស្លាប់

*ក្នុង ៣១ ភូមិ។*

**ប** = **បញ្ចវោការានំ តេសំ** = *ពួកបុគ្គលដែលកើតនៅក្នុងបញ្ចវោការភូមិ។*

**អ** = **អរូបានំ តេសំ** = *ពួកបុគ្គលដែលកើតនៅក្នុងអរូបភូមិ។*

**ញ** = **អសញ្ញសត្តានំ តេសំ** = *ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិ។*

**សុ** = **សុទ្ធាវាសានំ តេសំ តត្ថ** = *ពួកបុគ្គលដែលកើតនៅក្នុងសុទ្ធាវាសភូមិ ក្នុងភូមិនោះ ។ (មានក្នុងបុគ្គលោកាសវារៈតែម្យ៉ាង)។*

**តុប** = **ចតុវោការានំ បញ្ចវោការានំ តេសំ** = *ពួកបុគ្គលដែលកើត នៅក្នុងចតុវោការភូមិ បញ្ចវោការភូមិ។*

**ជិបឧ** = **បច្ឆិមភវិកានំ បញ្ចវោការេ ឧបបជ្ជន្តានំ តេសំ** = *បច្ឆិមភវិកៈបុគ្គល ដែលកំពុងកើតក្នុងបញ្ចវោការភូមិ។*

**ជិអឧ** = **បច្ឆិមភវិកានំ អរូបេ ឧបបជ្ជន្តានំ តេសំ** = *បច្ឆិមភវិកៈបុគ្គល ដែលកំពុងកើតក្នុងអរូបភូមិ។*

**ជិឧ** = **បច្ឆិមភវិកានំ ឧបបជ្ជន្តានំ តេសំ** = *បច្ឆិមភវិកៈបុគ្គល ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ។*

**ជិ** = **បច្ឆិមភវិកានំ តេសំ** = *បច្ឆិមភវិកៈបុគ្គល ដែលកើតនៅក្នុងចតុវោការភូមិ បញ្ចវោការភូមិ។*

**បជិ** = **បញ្ចវោការេ បច្ឆិមភវិកានំ តេសំ** = *បច្ឆិមភវិកៈបុគ្គល ដែលកើតនៅក្នុងបញ្ចវោការភូមិ។*

**អជិ** = **អរូបេ បច្ឆិមភវិកានំ តេសំ** = *បច្ឆិមភវិកៈបុគ្គល ដែលកើតនៅក្នុងអរូបភូមិ។*

បធិ = បញ្ចវោការេ បរិនិព្ពន្តានំ តេសំ = *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ។*

អធិ = អរូបេ បរិនិព្ពន្តានំ តេសំ = *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុង អរូបភូមិ។*

ធិ = បរិនិព្ពន្តានំ តេសំ = *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុង*
*ចតុវោការភូមិ បញ្ចវោការភូមិ។*

សុធិ = សុទ្ធាវាសេ បរិនិព្ពន្តានំ តេសំ តត្ថ = *ពួកបុគ្គលដែលកំពុង បរិនិព្វានក្នុងសុទ្ធាវាសភូមិ ក្នុងភូមិនោះ ។ (មានក្នុងបុគ្គលោកាសវារៈ តែម្យ៉ាង)។*

យេអវាធិ = យេ អរូបំ ឧបបជ្ជិត្វា បរិនិព្ពាយិស្សន្តិ តេសំ = *បុគ្គលណា នឹងទៅកើតក្នុងអរូបភូមិ ហើយបរិនិព្វាន បុគ្គលនោះ។*

យេអវាធិតេច = យេ អរូបំ ឧបបជ្ជិត្វា បរិនិព្ពាយិស្សន្តិ តេសំ ចវន្តានំ តេសំ = *បុគ្គលណា នឹងទៅកើតក្នុងអរូបភូមិ ហើយបរិនិព្វាន បុគ្គលនោះកំពុងស្លាប់។*

យេចអវាធិតេច = យេ ច អរូបំ ឧបបជ្ជិត្វា បរិនិព្ពាយិស្សន្តិ តេសំ ចវន្តានំ តេសំ = *បុគ្គលណា នឹងទៅកើតក្នុងអរូបភូមិ ហើយបរិនិព្វាន បុគ្គលនោះកំពុងស្លាប់ក្ដី។*

ឥបឧ = ឥតរេសំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ = *ពួកបុគ្គលដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលក្រៅពី...។*

ឥតុបឧ = ឥតរេសំ ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ = *ពួកបុគ្គលដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលក្រៅពី...។*

ឥបច = ឥតរេសំ បញ្ចវោការា ចវន្តានំ តេសំ = *ពួកបុគ្គលដែល កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ដែលក្រៅពី...។*

ឥតុបច = ឥតរេសំ ចតុវោការា បញ្ចវោការា ចវន្តានំ តេសំ = *ពួកបុគ្គលដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលក្រៅពី...។*

ឥប = ឥតរេសំ បញ្ចវោការានំ តេសំ = *ពួកបុគ្គលដែលកើតនៅក្នុងបញ្ចវោការភូមិ ដែលក្រៅពី...។*

ឥតុប = ឥតរេសំ ចតុវោការានំ បញ្ចវោការានំ តេសំ = *ពួកបុគ្គលដែលកើតនៅក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលក្រៅពី...។*

ឥ = ឥតរេសំ តេសំ = *ពួកបុគ្គលដែលនៅសល់ក្រៅពីនោះ។*

**បញ្ជាក់** បាលីនេះ បើប្រើក្នុងបុគ្គលោកាសវារៈ ត្រូវថែមពាក្យ តត្ថ បន្ទាប់ពី តេសំ ទាំងអស់។

# តារាងអង្គធម៌ ក្នុងឧប្បាទវារៈ អនាគតវារៈ បុគ្គលវារៈ

| | ទ.ឧ.៣.នុ.ល | ទ.ឧ.៣.ច.ល |
|---|---|---|
| | នឹងកើត | នឹងមិនកើត |
| **រូបក្ខន្ធ** | តិ.១<br>អរូបភូមិ<br>សុ.១<br>អសញ្ញី<br>បញ្ចវោ.<br>ប.៤+៣បញ្ច → បញ្ច.ទៀត (ប)<br>សុ.១, តិបុ.១ អសញ្ញ.អរូប | អរូបភូមិ<br>ចិ ៣ ៣ និ<br>បញ្ចវោ.<br>ចិ ១+៣ ៣ និ<br>តិបុ.១+៣ ចិ.ចតុ.បញ្ច. អរផ.១ បរិ.ចតុ.បញ្ច (ជិ)<br>តិបុ.១កាមសុ.៧ រូប.៩(-ចតុត្ថ)មគ្គ.ក → អរូប.បរិ<br>ផល៣ កាមសុ.៧ រូប.៩(-ចតុត្ថ) → អរូប.បរិ<br>ផល. ៣ អរូប → អរូបទៀត(-ទាប)បរិ.<br>(យេអវាធិ) |
| **នាមក្ខន្ធ** | អរូបភូមិ<br>អសញ្ញី<br>បញ្ចវោ.<br>ប.៤+៣(-ចិ)=៣០ ភូមិ (-អក.១) | អរូបភូមិ<br>ចិ និ តិបុ.១+៣ ចិ. ចតុ.បញ្ច អរផ១ បរិ ចតុ.បញ្ច (ជិ)<br>បញ្ចវោ.<br>ចិ និ |

**បញ្ជាក់** - បើអង្គធម៌ណា បានខាងកើតតែម្យ៉ាង អង្គធម៌នោះ ត្រូវសំដែងដោយមានពាក្យថា " ដែលហៅថា ឧប្បាទក្ខណសមង្គីរបស់......." ។

- បើអង្គធម៌ណា បានខាងស្លាប់តែម្យ៉ាង អង្គធម៌នោះ ត្រូវសំដែងដោយមានពាក្យថា " ដែលហៅថា ភង្គក្ខណសមង្គីរបស់......." ។

- បើអង្គធម៌ណា បានទាំងកើតទាំងស្លាប់ អង្គធម៌នោះ ត្រូវសំដែងដោយមិនមានពាក្យថា " ដែលហៅថា ឧប្បាទក្ខណសមង្គីរបស់.......ឬ ភង្គក្ខណសមង្គីរបស់......." ប្រើទូទៅគ្រប់កន្លែង និង គ្រប់កាល ក្នុងបុគ្គលវារៈ និង បុគ្គលោកាសវារៈ ។

## វិធីគិត និង អង្គធម៌ ក្នុង ឋ.ឌ្ញ.៣.នុ/ច.ល




**❀ រូបក្ខន្ធនឹងកើត**

*- ពួកបុគ្គលដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុង បញ្ចវោការភូមិទៀត។*

*- សុគតិអហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិ។*

*៙ អង្គធម៌ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងបញ្ចវោការភូមិទៀត។*

*សុគតិអហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិ។*




**❀ រូបក្ខន្ធនឹងមិនកើត**

- ភូមិដែលមានរូបក្ខន្ធក្តី មិនមានរូបក្ខន្ធក្តី រូបក្ខន្ធនឹងមិនកើត បាន(ជិ. និ.)។

- ពួកបុគ្គលដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងទៅកើត ក្នុងអរូបភូមិ បរិនិព្វាន។

- ពួកបុគ្គលដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងអរូបភូមិ ទៀត (វៀរភូមិដែលទាបជាងខ្លួន) បរិនិព្វាន។

៙ អន្តធម៌ បានដល់ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមភវិក: ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ។

តិហេតុកបុថុជ្ជន ១ ដែលកំពុងកើតក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩ (វៀរចតុត្ថជ្ឈានភូមិ ៧) ដែលនឹងបានមគ្គថ្នាក់ក្រោម ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន ដែលហៅថា ឧប្បាទក្ខណសមង្គីរបស់បញ្ចវោការតិហេតុកបដិសន្ធិចិត្ត ៨ (វៀររូបាវចរ-បញ្ចមជ្ឈានបដិសន្ធិចិត្ត ១) ចេតសិក ៣៥ កម្មជកលាប ៣-៧-៤។

ផលសេក្ខបុគ្គល ៣ ដែល កំពុងកើត និង កំពុងស្លាប់ក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩ (វៀរចតុត្ថជ្ឈានភូមិ ៧) ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន។

ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងអរូបភូមិទៀត (វៀរភូមិដែលទាបជាងខ្លួន) បរិនិព្វាន។




## ❀ នាមក្ខន្ធនឹងកើត

- ពួកបុគ្គលដែលកំពុងកើត និង កំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងទៅកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិទៀត។

- សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ។

៙ អន្តធម៌ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ (វៀរបច្ឆិមភវិក:) ដែលកំពុងកើត និង កំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ ១)។

*អរូប* ┌───┐ ឋិ និ

*បញ្ចវោ.* ┌───┐ ឋិ និ

## ❁ នាមក្ខន្ធនឹងមិនកើត

*- ភូមិដែលមាននាមក្ខន្ធ នាមក្ខន្ធនឹងមិនកើត បាន (ឋិ. និ.)។*

*១ អគ្គធម៌ បានដល់ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមភវិកៈ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ៕*

**បញ្ជាក់** ឋិ = ពួកបុគ្គលដែលជាបច្ឆិមភវិកៈ ដែលកំពុងកើត។

និ = ព្រះអរហន្ត ដែលកំពុងបរិនិព្វាន។

# បវត្តិវារៈ ឧប្បាទវារៈ អនាគតវារៈ អនុលោម បុគ្គលវារៈ

## (វ. ឧ. ៣ នុ. ល.)

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស រូបក្ខន្ធោ ឧប្បជ្ជិស្សតិ, តស្ស វេទនា-ខន្ធោ ឧប្បជ្ជិស្សតីតិ? *រូបក្ខន្ធនឹងកើតដល់បុគ្គលណា, វេទនាខន្ធក៏នឹងកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

**បដិលោមបុច្ឆាៈ** យស្ស វា បន វេទនាខន្ធោ ឧប្បជ្ជិស្សតិ, តស្ស រូបក្ខន្ធោ ឧប្បជ្ជិស្សតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងកើតដល់បុគ្គលណា, រូបក្ខន្ធក៏នឹងកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** យេ អរូបំ ឧបបជ្ជិត្វា បរិនិព្វាយិស្សន្តិ តេសំ វេទនា-ខន្ធោ ឧប្បជ្ជិស្សតិ នោ ច តេសំ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ, ឥតរេសំ តេសំ វេទនាខន្ធោ ច ឧប្បជ្ជិស្សតិ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ។ *ពួកបុគ្គលណា នឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន បុគ្គលនោះ វេទនាខន្ធនឹងកើតតែរូបក្ខន្ធ នឹងមិនកើតដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលនៅសល់ក្រៅពីនោះ វេទនាខន្ធក៏នឹងកើត រូបក្ខន្ធ ក៏នឹងកើត។*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

### ក្នុងអនុលោមបុច្ឆា

យស្ស រូបក្ខន្ធោ ឧប្បជ្ជិស្សតិ *ជាសន្និដ្ឋានបទ។*

តស្ស វេទនាខន្ធោ ឧប្បជ្ជិស្សតិ *ជាសំសយបទ។*

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងបញ្ចវោការភូមិទៀត, សុគតិអហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិ។

៙ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា រូបក្ខន្ធនឹងកើតដល់បុគ្គលណា, វេទនាខន្ធក៏នឹងកើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងបញ្ចវោការភូមិទៀត សុគតិអហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏នឹងកើតផង។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស រូបក្ខន្ធោ ឧប្បជ្ជិស្សតិ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើតក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩ (វៀរចតុត្ថជ្ឈានភូមិ៧) ដែលនឹងបានមគ្គថ្នាក់ក្រោម ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន ដែលហៅថា ឧប្បាទក្ខណសមង្គីរបស់បញ្ចវោការតិហេតុកបដិសន្ធិចិត្ត ៨ (វៀររូបាវចរបញ្ចមជ្ឈានបដិសន្ធិចិត្ត ១) ចេតសិក ៣៥ កម្មជកលាប ៣-៧-៤, ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩ (វៀរចតុត្ថជ្ឈានភូមិ៧) ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន, ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងអរូបភូមិទៀត (វៀរភូមិដែលទាបជាងខ្លួន) បរិនិព្វាន,

**និង** បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុង

បញ្ចវោការភូមិ ហើយនឹងកើតក្នុងបញ្ចវោការភូមិទៀត, សុគតិអហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិៗ

៦ អន្តធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងបញ្ចវោការភូមិទៀត, សុគតិអហេតុក-បុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិ ប៉ុណ្ណោះៗ

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងកើតដល់បុគ្គលណា, រូបក្ខន្ធក៏នឹងកើតដល់បុគ្គលនោះឬ? ទើបព្រះអដ្ឋកថាទ្រង់សំដែងដោយការលើកយកតិហេតុកបុថុជ្ជន ១ ដែលកំពុងកើតក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩(វៀរបតុត្ថជ្ឈានភូមិ ៧) ដែលនឹងបានមគ្គថ្នាក់ក្រោម ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន ដែលហៅថាឧប្បាទក្ខណសមង្គីរបស់បញ្ចវោការតិហេតុកបដិសន្ធិចិត្ត ៨ (វៀររូបាវចរបញ្ចមជ្ឈានបដិសន្ធិចិត្ត ១) ចេតសិក ៣៥ កម្មជកលាប ៣-៧-៤, ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩(វៀរបតុត្ថជ្ឈានភូមិ ៧) ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន, ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងអរូបភូមិទៀត (វៀរភូមិដែលទាបជាងខ្លួន) បរិនិព្វាន ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទដូចបានសំដែងថា **យេ អរូបំ ឧបបជ្ជិត្វា បរិនិព្វាយិស្សន្តិ តេសំ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ នោ ច តេសំ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ** ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងបញ្ចវោការភូមិទៀត, សុគតិអហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុង បច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **ឥតរេសំ តេសំ វេទនាក្ខន្ធោ ច ឧប្បជ្ជិស្សតិ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ,** ពាក្យវិសជ្ជនាក្នុងបដិលោម-

*បុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្ប់ដោយត្រង់ៗ*

(មូលីដែលនៅសល់សំដែងរបៀបគ្នា)

(ចប់ រូបក្ខន្ធមូលៈ)

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ, តស្ស សញ្ញាក្ខន្ធោ ឧប្បជ្ជិស្សតីតិ? *វេទនាខន្ធនឹងកើតដល់បុគ្គលណា, សញ្ញាខន្ធក៏នឹងកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

**បដិលោមបុច្ឆាៈ** យស្ស វា បន សញ្ញាក្ខន្ធោ ឧប្បជ្ជិស្សតិ, តស្ស វេទនាក្ខន្ធោ ឧប្បជ្ជិស្សតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងកើតដល់បុគ្គលណា, វេទនាខន្ធក៏នឹងកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ *ជាសន្និដ្ឋានបទៗ*

តស្ស សញ្ញាក្ខន្ធោ ឧប្បជ្ជិស្សតិ *ជាសំសយបទៗ*

*◉ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ (វៀរបច្ឆិមភវិកៈ) ដែលកំពុងកើត និង កំពុងស្លាប់ក្នុង ៣០ ភូមិ(វៀរអកនិដ្ឋភូមិ ១)ៗ*

*◉ អត្ថធម៌របស់សំសយបទ ដូចគ្នាៗ*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចុប្បញ្ញា សួរថា វេទនាខន្ធនឹងកើតដល់បុគ្គលណា,*

សញ្ញាខន្ធក៏នឹងកើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣(វៀរបច្ឆិមភវិកៈ) ដែលកំពុងកើត និង កំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ ១) ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏នឹងកើតផង។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន សញ្ញាខន្ធោ ឧប្បជ្ជិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស វេទនាខន្ធោ ឧប្បជ្ជិស្សតិ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ (វៀរបច្ឆិមភវិកៈ) ដែលកំពុងកើត និង កំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ ១)។

៙ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងកើតដល់បុគ្គលណា, វេទនាខន្ធក៏នឹងកើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ (វៀរបច្ឆិមភវិកៈ) ដែលកំពុងកើត និង កំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ ១) ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏នឹងកើតផង ៕

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលវារៈ)**

# បចត្តិវារៈ ឧប្បាទវារៈ អនាគតវារៈ អនុលោម ឱកាសវារៈ

## (រំ. ឧ. ៣ នុ. ឱ.)

## គ. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា៖** យត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ, តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតីតិ? *រូបក្ខន្ធនឹងកើតក្នុងភូមិណា, វេទនាខន្ធក៏នឹងកើតក្នុងភូមិនោះឬ?*

**វិសជ្ជនា៖** អសញ្ញសត្តេ តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ នោ ច តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ, បញ្ចវោការេ តត្ថ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ វេទនាក្ខន្ធោ ច ឧប្បជ្ជិស្សតិ។ *ក្នុងអសញ្ញសត្តភូមិនោះ រូបក្ខន្ធនឹងកើត តែវេទនាខន្ធនឹងមិនកើតក្នុងភូមិនោះ, ក្នុងបញ្ចវោការភូមិនោះ រូបក្ខន្ធក៏នឹងកើត វេទនាខន្ធក៏នឹងកើត។*

**បដិលោមបុច្ឆា៖** យត្ថ វា បន វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ, តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតីតិ? *មួយវិញទៀត វេទនាខន្ធនឹងកើតក្នុងភូមិណា, រូបក្ខន្ធក៏នឹងកើតក្នុងភូមិនោះឬ?*

**វិសជ្ជនា៖** អរូបេ តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ, នោ ច តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ, បញ្ចវោការេ តត្ថ វេទនាក្ខន្ធោ ច ឧប្បជ្ជិស្សតិ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ។ *ក្នុងអរូបភូមិនោះ វេទនាខន្ធនឹងកើត តែរូបក្ខន្ធនឹងមិនកើតក្នុងភូមិនោះ, ក្នុងបញ្ចវោការភូមិនោះ វេទនាខន្ធក៏នឹងកើត រូបក្ខន្ធក៏នឹងកើត។*

# ការសំដែងអគ្គធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ ជាសន្និដ្ឋានបទ។

តត្ថ វេទនាខន្ធោ ឧប្បជ្ជិស្សតិ ជាសំសយបទ។

៙ អគ្គធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង,

និង បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។

៙ អគ្គធម៌របស់សំសយបទ បានដល់ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា រូបក្ខន្ធនឹងកើតក្នុងភូមិណា, វេទនាខន្ធក៏នឹងកើតក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអគ្គធម៌របស់សន្និដ្ឋានបទ បានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អសញ្ញសត្តេ តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ នោ ច តត្ថ វេទនាខន្ធោ ឧប្បជ្ជិស្សតិ** ហើយទ្រង់លើកយក បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអគ្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការេ តត្ថ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ វេទនាខន្ធោ ច ឧប្បជ្ជិស្សតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆា នេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

យត្ថ វា បន វេទនាខន្ធោ ឧប្បជ្ជិស្សតិ ជាសន្និដ្ឋានបទ។

តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤, និង បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។

៙ អន្តធម៌របស់សំសយបទ បានដល់ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងកើតក្នុងភូមិណា, រូបក្ខន្ធក៏នឹងកើតក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយកអរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាងទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អរូបេ តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ នោ ច តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ** ហើយទ្រង់លើកយកបញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការេ តត្ថ វេទនាក្ខន្ធោ ច ឧប្បជ្ជិស្សតិ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភត្តដោយត្រង់។

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ, តត្ថ សញ្ញាក្ខន្ធោ ឧប្បជ្ជិស្សតីតិ? វេទនាខន្ធនឹងកើតក្នុងភូមិណា, សញ្ញាខន្ធក៏នឹងកើតក្នុងភូមិនោះឬ?

**វិសជ្ជនាៈ** អាមន្តា មែន។

**បដិលោមបុច្ឆាៈ** យត្ថ វា បន សញ្ញាក្ខន្ធោ ឧប្បជ្ជិស្សតិ,

តត្ថ វេទនាខន្ធោ ឧប្បជ្ជិស្សតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងកើតក្នុងភូមិណា, វេទនាខន្ធក៏នឹងកើតក្នុងភូមិនោះឬ?*

**វិសជ្ជនា:** អាមន្តា *មែន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យត្ថ វេទនាខន្ធោ ឧប្បជ្ជិស្សតិ *ជាសន្និដ្ឋានបទ។*

តត្ថ សញ្ញាខន្ធោ ឧប្បជ្ជិស្សតិ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*៙ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជា***បច្ចុបញ្ញា** *សួរថា វេទនាខន្ធនឹងកើតក្នុងភូមិណា, សញ្ញាខន្ធក៏នឹងកើតក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ***បដិវចនវិសជ្ជនា***ថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏នឹងកើតផង។*

## ក្នុងបដិលោមបុច្ឆា

យត្ថ វា បន សញ្ញាខន្ធោ ឧប្បជ្ជិស្សតិ *ជាសន្និដ្ឋានបទ។*

តត្ថ វេទនាខន្ធោ ឧប្បជ្ជិស្សតិ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*៙ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ឆាបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងកើតក្នុងភូមិណា, វេទនាខន្ធក៏នឹងកើតក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏នឹងកើតផងៗ*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ និកាសវារៈ)**

# តារាងអន្តធម៌ ក្នុងឧប្បាទវារៈ អនាគតវារៈ បុគ្គលោកាសវារៈ

| | រ.ឧ.៣.នុ.លោ | រ.ឧ.៣.ច.លោ |
|---|---|---|
| ខន្ធ ៥ | នឹងកើត | នឹងមិនកើត |
| រូបក្ខន្ធ | អសញ្ញី ស.១<br>បញ្ច. ២១(-៥)<br>៤+៣ ៤+៣<br>៤+៣ បញ្ច២១(-៥) ប → ភូមិ.ទៀត<br>ស.១អសញ្ញ.១ ញ → អសញ្ញ.ទៀត | អរូប. ៤<br>១+៣ ១+៤<br>អសញ្ញី. ស.១<br>* *<br>បញ្ចវោ. ២៦<br>ចិ ទិ<br>* *<br>តិ.បុ.១+៣ចិ.បញ្ច អវេ.១ បរិ.បញ្ច.២២(-៤) (បចិ)<br>* បុ.៤+៣.បញ្ច.២៥(-អក១) → មិន.ភូមិ.ទៀត<br>* ស.១អសញ្ញ.១ → មិន.អសញ្ញ.ទៀត<br>តិបុ.១+៤ អរូប.៤ (អ) |

# តារាងអង្គធម៌ ក្នុងឧប្បាទវារៈ អនាគតវារៈ បុគ្គលោកាសវារៈ

| | វំ.ឧ.៣.នុ.លោ | វំ.ឧ.៣.ច.លោ |
|---|---|---|
| ខន្ធ ៥ | នឹងកើត | នឹងមិនកើត |
| នាមក្ខន្ធ | អរូប ៤ ១+៣ ១+៣<br>បញ្ចវោ. ២១(-៥) ៤+៣ ៤+៣<br>បុ.៤+៣ចតុ៤ បញ្ច២១(-៥) ⟶ ភូមិ.ទៀត<br>(តុប) | អរូប. ៤ ធិ ✳ និ ✳<br>អសញ្ញី. សុ.១<br>បញ្ចវោ. ២៦ ធិ ✳ និ ✳<br>តិ.បុ.១+៣ធិ.ចតុ.បញ្ច. អរផ.១បរិ.ចតុ.៤បញ្ច.២២(-៤) (ធិ)<br>✳ បុ.៤+៣.ចតុ.៤ បញ្ច.២៥(-អក១) ⟶ មិន.ភូមិ.ទៀត<br>សុ.១ អសញ្ញ.១ (ញ) |

**បញ្ជាក់** (✳) = សញ្ញាអង្គធម៌ដោយអមនេះ មិនមានបាលីដោយចំពោះ។

(↶) = សញ្ញានេះ បញ្ជាក់ថា ... ហើយនឹងកើត ក្នុងភូមិដែលខ្លួនកើតនៅទៀត។

( ＼ ) = សញ្ញានេះ បញ្ជាក់ចំនួនអង្គធម៌ ៣ ពួកគឺ៖ (ធិ ឬ និ, ✳, ↶) បើបាន ១ ពួក គូស ១, បាន ២ ពួក គូស ២, បាន ៣ ពួក គូស ៣។

# វិធីគិត និង អន្តធម៌ក្នុង វ.ឧ.៣.នុ/ច.លោ




❁ **រូបក្ខន្ធនឹងកើត** = *ភូមិដែលមានរូបក្ខន្ធ ពួកបុគ្គលដែលកំពុងកើត និង កំពុងស្លាប់ រូបក្ខន្ធនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀតៗ*

*◉ អន្តធម៌ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀតៗ*

*សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ហើយនឹងកើតក្នុងអសញ្ញសត្តភូមិទៀត និងអសញ្ញសត្តភូមិ ១ៗ*




❁ **រូបក្ខន្ធនឹងមិនកើត** = *ភូមិដែលមានរូបក្ខន្ធ រូបក្ខន្ធនឹងមិនកើត បាន(ជិ. និ. ✶) ភូមិដែលមិនមានរូបក្ខន្ធ បានទាំងអស់មិនមានសល់ៗ*

*◉ អន្តធម៌ បានដល់ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមភវិកៈ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤)ៗ (អន្តធម៌ដោយត្រង់)ៗ*

*✶ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ១) ហើយនឹងមិនកើតក្នុងភូមិដែលខ្លួនកើតនៅទៀតៗ (អន្តធម៌ដោយអម)ៗ*

*✶ សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ហើយនឹងមិនកើតក្នុងអសញ្ញសត្តភូមិ ទៀតៗ (អន្តធម៌ដោយអម)ៗ*

*តិហេតុកបុថុជ្ជន ១ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ៤ៗ*

\២១(-៥)/ \ ៤ /

❁ **នាមក្ខន្ធនឹងកើត** = ភូមិដែលមាននាមក្ខន្ធ ពួកបុគ្គលដែលកំពុងកើត និង កំពុងស្លាប់ នាមក្ខន្ធនឹងកើតក្នុងភូមិដែលខ្លួនកើតទៅទៀត។

៙ អន្តធម៌ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតទៅទៀត។

\\ ២៦ // \\ ១ // \\ ៤ //

ជិ និ ជិ និ

✳ ✳ ✳ ✳

❁ **នាមក្ខន្ធនឹងមិនកើត** = ភូមិដែលមាននាមក្ខន្ធ នាមក្ខន្ធនឹងមិនកើត បាន (ជិ. និ. ✳) ភូមិដែលមិនមាននាមក្ខន្ធ បានទាំងអស់មិនមានសល់។

៙ អន្តធម៌ បានដល់ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមភវិកៈ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) ។ (អន្តធម៌ ដោយត្រង់)។

✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) ហើយនឹងមិនកើតក្នុងភូមិដែលខ្លួនកើតទៅទៀត។ (អន្តធម៌ ដោយអម)។

សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ១។

**បញ្ជាក់** ជិ = ពួកបុគ្គលដែលជាបច្ឆិមភវិកៈ ដែលកំពុងកើត។

និ = ព្រះអរហន្ត ដែលកំពុងបរិនិព្វាន។

✳ = បុគ្គលដោយអម បានសេចក្តីថា បច្ឆិមភវិកៈបុគ្គល ដែលកំពុងកើត និង ព្រះអរហន្ត ដែលកំពុងបរិនិព្វាននេះ ចំពោះព្រះអរហន្ត លោកឈប់មានការកើតទៀតហើយ ជាតិនេះ គឺជាជាតិចុងក្រោយរបស់លោក ហៅថា **បច្ឆិមភវិកៈ ដោយត្រង់**, ចំណែក បុគ្គលដោយអមនោះ គឺកើតក្នុងភូមិនេះហើយ ឈប់កើតក្នុង

*ភូមិនេះទៀត ប៉ុន្តែ ទៅកើតក្នុងភពដទៃៗទៀត ហើយបរិនិព្វាន បុគ្គលនេះ ហៅថា* ***បច្ឆិមភវិកៈដោយអម*** *(គឺជាជាតិចុងក្រោយ ក្នុងភូមិនោះៗ)៕*

## បវត្តិវារៈ ឧប្បាទវារៈ អនាគតវារៈ អនុលោម បុគ្គលោកាសវារៈ

## (វំ. ឧ. ៣ នុ. លោ.)

## ឥ. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ, តស្ស តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតីតិ? *រូបក្ខន្ធនឹងកើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អសញ្ញសត្តានំ តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ, បញ្ចវោការានំ តេសំ តត្ថ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ វេទនាក្ខន្ធោ ច ឧប្បជ្ជិស្សតិ។ *ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធនឹងកើត តែវេទនាខន្ធនឹងមិនកើតដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងបញ្ចវោការភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធក៏នឹងកើត វេទនាខន្ធក៏នឹងកើត។*

**បដិលោមបុច្ឆាៈ** យស្ស វា បន យត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ, តស្ស តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងកើតដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏នឹងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អរូបានំ តេសំ តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ, បញ្ចវោការានំ តេសំ តត្ថ វេទនាក្ខន្ធោ ច ឧប្បជ្ជិស្សតិ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ, *ពួកបុគ្គលដែលកើតនៅក្នុងអរូបភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធនឹងកើត តែរូបក្ខន្ធនឹងមិនកើតដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងបញ្ចវោការភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធក៏នឹងកើត រូបក្ខន្ធក៏នឹងកើត។*

# ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

# ក្នុងអនុលោមបុច្ឆា

**យស្ស យត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ** *ជាសន្និដ្ឋានបទ។*

**តស្ស តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ** *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ហើយនឹងកើតក្នុងអសញ្ញសត្តភូមិទៀត និង អសញ្ញសត្តភូមិ ១,*

*និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។*

*៙ អន្តធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា រូបក្ខន្ធនឹងកើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែង ដោយការលើកយក សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ហើយនឹងកើតក្នុងអសញ្ញសត្តភូមិទៀត និងអសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **អសញ្ញសត្តានំ តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ** *ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **បញ្ច-**

**វោការានំ តេសំ តត្ថ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ វេទនាក្ខន្ធោ ច ឧប្បជ្ជិស្សតិ** *ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។*

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ** *ជាសន្និដ្ឋានបទ។*

**តស្ស តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ** *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងអរូបភូមិ ៤,*

***និង** បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។*

*៙ អត្ថធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងកើតដល់បុគ្គលណា ក្នុងភូមិណា, រូបខន្ធក៏នឹងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងអរូបភូមិ ៤ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **អរូបានំ តេសំ តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ** *ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ*

*២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបាន ទាំង ២ ទុកក្នុងបច្ចិមកោដ្ឋាសៈ មិនមានការបដិសេធ សំសយបទ ដូចបានសំដែងថា* បញ្ចវោការានំ តេសំ តត្ថ វេទនាក្ខន្ធោ ច ឧប្បជ្ជិស្សតិ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកន្តដោយត្រង់ៗ*

**(មូលីដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

## ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ, តស្ស តត្ថ សញ្ញាក្ខន្ធោ ឧប្បជ្ជិស្សតីតិ? *វេទនាខន្ធនឹងកើតដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

**បដិលោមបុច្ឆាៈ** យស្ស វា បន យត្ថ សញ្ញាក្ខន្ធោ ឧប្បជ្ជិស្សតិ, តស្ស តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងកើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ *ជាសន្និដ្ឋានបទៗ*

តស្ស តត្ថ សញ្ញាក្ខន្ធោ ឧប្បជ្ជិស្សតិ *ជាសំសយបទៗ*

๏ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត។

๏ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា វេទនាខន្ធនឹងកើតដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ហើយនឹងកើតក្នុងភូមិ ដែលខ្លួនកើតនៅទៀត ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏នឹងកើតផង។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាខន្ធោ ឧប្បជ្ជិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ វេទនាខន្ធោ ឧប្បជ្ជិស្សតិ** ជាសំសយបទ។

๏ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និងកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត។

๏ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងកើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១

*(វៀរសុទ្ធាវាសភូមិ ៥) ហើយនឹងកើតក្នុងភូមិ ដែលខ្លួនកើតនៅទៀត ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏នឹងកើតផង។*

**(មូលិ មូលៈ ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលោកាសវារៈ)**

## (ចប់ ឧប្បាទវារៈ អនាគតវារៈ អនុលោម)

## បវត្តិវារៈ ឧប្បាទវារៈ អនាគតវារៈ បច្ចនីកៈ បុគ្គលវារៈ

**(រំ. ឧ. ៣ ច. ឈ.)**

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យស្ស រូបក្ខន្ធោ នុប្បជ្ជិស្សតិ, តស្ស វេទនាខន្ធោ នុប្បជ្ជិស្សតីតិ? *រូបក្ខន្ធនឹងមិនកើតដល់បុគ្គលណា, វេទនាខន្ធក៏នឹងមិនកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** យេ អរូបំ ឧបបជ្ជិត្វា បរិនិព្វាយិស្សន្តិ តេសំ រូបក្ខន្ធោ នុប្បជ្ជិស្សតិ នោ ច តេសំ វេទនាខន្ធោ នុប្បជ្ជិស្សតិ, បច្ឆិមភវិកានំ តេសំ រូបក្ខន្ធោ ច នុប្បជ្ជិស្សតិ វេទនាខន្ធោ ច នុប្បជ្ជិស្សតិ។ *ពួកបុគ្គលណានឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន ពួកបុគ្គលនោះ រូបក្ខន្ធនឹងមិនកើត តែវេទនាខន្ធនឹងកើតដល់បុគ្គលពួកនោះ, ពួកបច្ឆិមភវិកបុគ្គលដែលកើតនៅក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ រូបក្ខន្ធក៏នឹងមិនកើត វេទនាខន្ធក៏នឹងមិនកើត។*

**បដិលោមបុច្ឆាៈ** យស្ស វា បន វេទនាខន្ធោ នុប្បជ្ជិស្សតិ, តស្ស រូបក្ខន្ធោ នុប្បជ្ជិស្សតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងមិនកើតដល់បុគ្គលណា, រូបក្ខន្ធក៏នឹងមិនកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន*

### ការសំដែងអង្គធម៌ និង ការចែកកោដ្ឋាសៈ

### ក្នុងអនុលោមបុច្ឆា

យស្ស រូបក្ខន្ធោ នុប្បជ្ជិស្សតិ *ជាសន្និដ្ឋានបទ។*

**តស្ស វេទនាខន្ធោ ឧប្បជ្ជិស្សតិ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើតក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩ (វៀរចតុត្ថជ្ឈានភូមិ ៧) ដែលនឹងបានមគ្គថ្នាក់ក្រោម ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន ដែលហៅថា ឧប្បាទក្ខណសមង្គីរបស់បញ្ចវោការតិហេតុកបដិសន្ធិចិត្ត ៨ (វៀររូបាវចរបញ្ចមជ្ឈានបដិសន្ធិចិត្ត ១) ចេតសិក ៣៥ កម្មជកលាប ៣-៧-៤, ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩ (វៀរចតុត្ថជ្ឈានភូមិ ៧) ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន, ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងអរូបភូមិទៀត (វៀរភូមិដែលទាបជាងខ្លួន) បរិនិព្វាន។

**និង** តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមភវិកៈ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ។

៙ អន្តធម៌របស់សំសយបទ បានដល់ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមភវិកៈ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា រូបក្ខន្ធនឹងមិនកើតដល់បុគ្គលណា, វេទនាខន្ធក៏នឹងមិនកើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក តិហេតុកបុថុជ្ជន ១ ដែលកំពុងកើតក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩(វៀរចតុត្ថជ្ឈានភូមិ ៧) ដែលនឹងបានមគ្គថ្នាក់ក្រោម ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន ដែលហៅថា ឧប្បាទក្ខណសមង្គីរបស់បញ្ចវោការតិហេតុកបដិសន្ធិចិត្ត ៨ (វៀររូបាវចរបញ្ចមជ្ឈាន-បដិសន្ធិចិត្ត ១) ចេតសិក ៣៥ កម្មជកលាប ៣-៧-៤, ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩(វៀរចតុត្ថជ្ឈានភូមិ ៧) ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន, ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងអរូបភូមិទៀត (វៀរភូមិដែលទាបជាងខ្លួន) បរិនិព្វាន ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធ

សំសយបទ ដូចបានសំដែងថា **យេ អរូបំ ឧបបជ្ជន្តា បរិនិព្វាយិស្សន្តិ តេសំ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ នោ ច តេសំ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ** ហើយទ្រង់លើកយក តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមភវិកៈ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បច្ឆិមភវិកានំ តេសំ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ វេទនាក្ខន្ធោ ច ឧប្បជ្ជិស្សតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ** ជាសន្និដ្ឋានបទៗ

**តស្ស រូបក្ខន្ធោ ឧប្បជ្ជិស្សតិ** ជាសំសយបទៗ

๑ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមភវិកៈ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិៗ

๑ អង្គធម៌របស់សំសយបទ ដូចគ្នាៗ

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ឆាបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងមិនកើតដល់បុគ្គលណា, រូបក្ខន្ធក៏នឹងមិនកើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមភវិកៈ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ រូបក្ខន្ធក៏នឹងមិនកើតផងៗ

**(មូលីដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**និង** *បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ និងបញ្ចវោការភូមិ ២១(វៀរសុទ្ធាវាសភូមិ ៥) ។*

*៙ អន្តធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា***បរិបុណ្ណបញ្ហា** *សួរថា ម្យ៉ាងទៀត វេទនាខន្ធធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក តិហេតុកបុថុជ្ជន ១ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ និងអរូបភូមិ ៤, ដែលជាអន្តធម៌របស់សន្និដ្ឋានបទ បានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **អរូបានំ តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ** *ហើយទ្រង់លើកយក* **និង** *បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងបញ្ចវោការភូមិ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **បញ្ចវោការានំ**

*តេសំ* តត្ថ វេទនាខន្ធោ ច និរុជ្ឈិត្ថ រូបក្ខន្ធោ ច និរុជ្ឈិត្ថ, *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលះ)**

# ខ. វេទនាខន្ធមូលះ

## ១. វេទនាខន្ធមូលះ សញ្ញាខន្ធមូលីយចក្កះ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ វេទនាខន្ធោ និរុជ្ឈិត្ថ, តស្ស តត្ថ សញ្ញាខន្ធោ និរុជ្ឈិត្ថាតិ? *វេទនាខន្ធធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

**បដិលោមបុច្ឆាៈ** យស្ស វា បន យត្ថ សញ្ញាខន្ធោ និរុជ្ឈិត្ថ, តស្ស តត្ថ វេទនាខន្ធោ និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត សញ្ញាខន្ធធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសះ ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ វេទនាខន្ធោ និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទៗ*

តស្ស តត្ថ សញ្ញាខន្ធោ និរុជ្ឈិត្ថ *ជាសំសយបទៗ*

*១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)ៗ*

១ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា វេទនាខន្ធធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏ធ្លាប់រលត់ផង។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាខន្ធោ និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ វេទនាខន្ធោ និរុជ្ឈិត្ថ** ជាសំសយបទ។

១ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងកើត និងកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។

១ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងកើត និងកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏ធ្លាប់រលត់ផង។

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលោកាសវារៈ)**

## (ចប់ និរោធវារៈ អតីតវារៈ អនុលោម)

# បណ្ណត្តិវារៈ និរោធវារៈ អតីតវារៈ បច្ចនីកៈ បុគ្គលវារៈ

## (វំ. និ. ២ ច. ឍ.)

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស រូបក្ខន្ធោ ន និរុជ្ឈិត្ថ, តស្ស វេទនាខន្ធោ ន និរុជ្ឈិត្ថាតិ? *រូបក្ខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** នត្ថិ *មិនមាន។*

**បដិលោមបុច្ឆាៈ** យស្ស វា បន វេទនាខន្ធោ ន និរុជ្ឈិត្ថ, តស្ស រូបក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, រូបក្ខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** នត្ថិ *មិនមាន។*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស រូបក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស វេទនាខន្ធោ ន និរុជ្ឈិត្ថ *ជាសំសយបទ។*

*๏ អត្ថធម៌របស់សន្និដ្ឋានបទ មិនមាន កាលបើអត្ថធម៌របស់សន្និដ្ឋានបទមិនមាន-ហើយ អត្ថធម៌របស់សំសយបទ ក៏មិនមានដូចគ្នា ។*

*ដូច្នេះ ពាក្យសួរបទនេះ ជាមោឃបញ្ហា សួរថា រូបក្ខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ បដិក្ខេប-វិសជ្ជនាថា* នត្ថិ *ដែលជាពាក្យវិសជ្ជនាហាមអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា*

ពួកបុគ្គលដែលរូបក្ខន្ធមិនធ្លាប់រលត់ក្នុងភពផ្សេងៗនោះ មិនមាន មានតែពួកបុគ្គលដែលរូបក្ខន្ធ ធ្លាប់រលត់មកហើយទាំងអស់ ។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទ ។

**តស្ស រូបក្ខន្ធោ ន និរុជ្ឈិត្ថ** ជាសំសយបទ ។

១ អត្ថធម៌របស់សន្និដ្ឋានបទ មិនមាន កាលបើអត្ថធម៌របស់សន្និដ្ឋានបទមិនមាន-ហើយ អត្ថធម៌របស់សំសយបទ ក៏មិនមានដូចគ្នា ។

ដូច្នេះ ពាក្យសួរបទនេះ ជា **មោឃបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, រូបក្ខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិក្ខេបវិសជ្ជនាថា **នត្ថិ** ដែលជាពាក្យវិសជ្ជនាហាមអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា ពួកបុគ្គលដែលវេទនាខន្ធមិនធ្លាប់រលត់ក្នុងភពផ្សេងៗនោះ មិនមាន មានតែបុគ្គល ដែលវេទនាខន្ធធ្លាប់រលត់មកហើយទាំងអស់ ។

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. ចេតនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលិយមកៈ

**អនុលោមបុច្ឆាៈ** យស្ស វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ, តស្ស សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *វេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** នត្ថិ *មិនមាន។*

**បដិលោមបុច្ឆាៈ** យស្ស វា បន សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថ, តស្ស វេទនាក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** នត្ថិ *មិនមាន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសំសយបទ។*

*๏ អត្ថធម៌របស់សន្និដ្ឋានបទ មិនមាន កាលបើអត្ថធម៌របស់សន្និដ្ឋានបទមិនមាន-ហើយ អត្ថធម៌របស់សំសយបទ ក៏មិនមានដូចគ្នា ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា* **មោឃបញ្ហា** *សួរថា វេទនាខន្ធ មិនធ្លាប់រលត់ដល់បុគ្គលណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ* **បដិក្ខេបវិសជ្ជនាថា នត្ថិ** *ដែលជាពាក្យវិសជ្ជនាហាមអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថាពួកបុគ្គលដែលវេទនាខន្ធមិនធ្លាប់រលត់ក្នុងភពផ្សេងៗនោះ មិនមាន មានតែពួកបុគ្គលដែល វេទនាខន្ធធ្លាប់រលត់មកហើយទាំងអស់។*

## ក្នុងបដិលោមបុច្ឆា

យស្ស វា បន សញ្ញាខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស វេទនាខន្ធោ ន និរុជ្ឈិត្ថ *ជាសំសយបទ។*

*១ អត្ថធម៌របស់សន្និដ្ឋានបទ មិនមាន កាលបើអត្ថធម៌របស់សន្និដ្ឋានបទមិនមាន- ហើយ អត្ថធម៌របស់សំសយបទ ក៏មិនមានដូចគ្នា ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា* **មោឃបញ្ហា** *សួរថា ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិក្ខេបវិសជ្ជនាថា* នត្ថិ *ដែលជាពាក្យវិសជ្ជនាហាមអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា ពួកបុគ្គលដែលសញ្ញាខន្ធមិនធ្លាប់រលត់ក្នុងភពផ្សេងៗនោះមិនមាន មានតែពួកបុគ្គលដែលសញ្ញាខន្ធធ្លាប់រលត់មកហើយទាំងអស់។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ បុគ្គលវារៈ)**

## បវត្តិវារៈ និរោធវារៈ អតីតវារៈ បច្ចនីកៈ ឱកាសវារៈ

**(វ. និ. ២ ច. ឱ.)**

### ត. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ, តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថាតិ? *រូបក្ខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** និរុជ្ឈិត្ថ *ធ្លាប់រលត់។*

**បដិលោមបុច្ឆា:** យត្ថ វា បន វេទនាខន្ធោ ន និរុជ្ឈិត្ថ, តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, រូបក្ខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** និរុជ្ឈិត្ថ *ធ្លាប់រលត់។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ *ជាសំសយបទ។*

*๑ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤។*

*๑ អត្ថធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា រូបក្ខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ*បាឡិគតិវិសជ្ជនា*ថា* និរុជ្ឈិត្ថ *ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីរូបក្ខន្ធ មិនធ្លាប់រលត់ តែវេទនាខន្ធធ្លាប់រលត់។*

## ក្នុងបដិលោមបុច្ឆា

យត្ថ វា បន វេទនាខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសំសយបទ។*

*๑ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។*

*๑ អត្ថធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, រូបក្ខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ*

*បាឡិគតិវិសជ្ជនាថា* **ឆ និរុជ្ឈិត្ថ** *ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីវេទនាខន្ធមិនធ្លាប់រលត់ តែរូបក្ខន្ធធ្លាប់រលត់។*

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយចកៈ

**អនុលោមបុច្ឆា៖** យត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ, តត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *វេទនាខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា៖** អាមន្តា *មែន។*

**បដិលោមបុច្ឆា៖** យត្ថ វា បន សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថ, តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា៖** អាមន្តា *មែន។*

### ការសំដែងអង្គធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសំសយបទ។*

៙ *អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។*

៙ *អង្គធម៌របស់សំសយបទ ដូចគ្នា។*

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា វេទនាខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏មិនធ្លាប់រលត់ផង។

## ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន សញ្ញាខន្ធោ ន និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទ។

**តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ** ជាសំសយបទ។

๑ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។

๑ អង្គធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏មិនធ្លាប់រលត់ផង។

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ និកាសវារៈ)**

# បវត្តិវារៈ និរោធវារៈ អតីតវារៈ បច្ចនីកៈ បុគ្គលោកាសវារៈ

## (វំ. និ. ២ ច. លោ.)

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា៖** យស្ស យត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ, តស្ស តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *រូបក្ខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា៖** អរូបានំ តេសំ តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ, សុទ្ធាវាសានំ តេសំ តត្ថ រូបក្ខន្ធោ ច ន និរុជ្ឈិត្ថ វេទនាក្ខន្ធោ ច ន និរុជ្ឈិត្ថ។ *ពួកបុគ្គលដែលកើតនៅក្នុងអរូបភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធមិនធ្លាប់រលត់ តែវេទនាខន្ធធ្លាប់រលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងសុទ្ធាវាសភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធ ក៏មិនធ្លាប់រលត់ វេទនាខន្ធក៏មិនធ្លាប់រលត់។*

**បដិលោមបុច្ឆា៖** យស្ស វា បន យត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ, តស្ស តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា៖** អសញ្ញសត្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ, សុទ្ធាវាសានំ តេសំ តត្ថ វេទនាក្ខន្ធោ ច ន និរុជ្ឈិត្ថ រូបក្ខន្ធោ ច ន និរុជ្ឈិត្ថ។ *ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធមិនធ្លាប់រលត់ តែរូបក្ខន្ធ ធ្លាប់រលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងសុទ្ធាវាសភូមិ ក្នុងភូមិនោះ វេទនាខន្ធក៏មិនធ្លាប់រលត់ រូបក្ខន្ធក៏មិនធ្លាប់រលត់។*

# ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

# ក្នុងអនុលោមបុច្ឆា

**យស្ស យត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ** *ជាសន្និដ្ឋានបទ។*

**តស្ស តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ** *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ តិហេតុកបុថុជ្ជន ១ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ និងអរូបភូមិ ៤,*

*និង អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥។*

*៙ អន្តធម៌របស់សំសយបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា រូបក្ខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក តិហេតុកបុថុជ្ជន ១ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ និងអរូបភូមិ ៤, ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **អរូបានំ តេសំ តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ** *ហើយទ្រង់លើកយក និង អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **សុទ្ធាវាសានំ តេសំ តត្ថ រូបក្ខន្ធោ ច ន និរុជ្ឈិត្ថ វេទនាក្ខន្ធោ ច ន និរុជ្ឈិត្ថ** *ពាក្យវិសជ្ជនា*

ក្នុងអនុលោមបុច្ឆានេះ ជា សុរូបទស្សនវិសជ្ជនា ដែលមានវិកប្ប ដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១,

និង អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥ៗ

៙ អន្តធម៌របស់សំសយបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១), អរហត្ត-ផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១, ដែលជាអន្តធម៌របស់សន្និ-ដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អសញ្ញសត្តានំ តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ** ហើយទ្រង់លើកយក អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសានំ តេសំ តត្ថ**

វេទនាខន្ធោ ច ន និរុជ្ឈិត្ថ រូបក្ខន្ធោ ច ន និរុជ្ឈិត្ថ ពាក្យវិសជ្ជនា ក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភត្តដោយត្រង់ៗ

(មូលី ដែលនៅសល់សំដែងរបៀបគ្នា)

(ចប់ រូបក្ខន្ធមូលៈ)

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ, តស្ស តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិត្ថាតិ? *វេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

**បដិលោមបុច្ឆាៈ** យស្ស វា បន យត្ថ សញ្ញាខន្ធោ ន និរុជ្ឈិត្ថ, តស្ស តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន ៗ*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទៗ*

តស្ស តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិត្ថ *ជាសំសយបទៗ*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥,*

សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និង អសញ្ញសត្តភូមិ ១។

៙ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា វេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និង អសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏មិនធ្លាប់រលត់ផង។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១។

៙ អន្តធម៌របស់សំសយបទ ដូចគ្នា ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុង

*សុទ្ធាវាសភូមិ ៥ និង កំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១), អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និង អសញ្ញសត្តភូមិ ១ ដែលជាអង្គធម៌របស់ សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏មិនធ្លាប់ រលត់ផង។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ បុគ្គលោកាសវារៈ)**

## (ចប់ និរោធវារៈ អតីតវារៈ បច្ចនីកៈ)

# អង្គធម៌និរោធវារៈ អនាគតវារៈ ក្នុង បុគ្គលវារៈ

| ខន្ធ ៥ | រ.និ.៣.នុ.ល. | រ.និ.៣.ច.ល. |
|---|---|---|
| រូបក្ខន្ធ | - អរូប តិ.១<br>- អសញ្ញ សុ.១<br>- បញ្ចវោ<br>បុ.៤+៣ បញ្ច បុ.៤+៣ បញ្ច → បញ្ច.ទៀត (ប.)<br>សុ.១, តិបុ.១ អសញ្ញ, អរូប | - អរូប<br>ធិ ៣ ៣ និ<br>- បញ្ចវោ<br>៣ និ<br>អរ.ផ.១ បរិ.បញ្ច (បនិ.)<br>ផល៣ ធិ. អរូប អរផ.១ បរិ.អរូប (អធិ.)<br>ផលសេក្ខ.៣ កាមសុ.៧, រូប.៩(-ចតុត្ថ.ភូមិ) → អរូប.បរិ.<br>ផលសេក្ខ.៣ អរូប. → អរូប.ទៀត(-ទាប)បរិ.<br>} យេអវានិតេច. |
| នាមក្ខន្ធ | - អរូប តិ.១<br>- អសញ្ញី សុ.១<br>- បញ្ចវោ<br>បុ.៤+៣ = ៣១ ភូមិ បុ.៤+៣ = ៣០ ភូមិ(-អក១) | - អរូប<br>និ<br>- បញ្ចវោ<br>និ<br>អរផ.១ បរិ.ចតុ.បញ្ច (និ.) |

# វិធីគិតនិងអង្គធម៌ក្នុង ទ. និ. ៣ នុ. ច. ល.




## ❀ រូបក្ខន្ធនឹងរលត់

- បុគ្គលដែលកំពុងកើតក្នុងបញ្ចវោការភូមិ រូបក្ខន្ធនឹងរលត់នៅពេលស្លាប់, បុគ្គលដែលកំពុងស្លាប់ រូបក្ខន្ធនឹងរលត់ក្នុងបញ្ចវោការភូមិទៀត,

- សុគតិអហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិ។

៙ អង្គធម៌ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងបញ្ចវោការភូមិទៀត។

សុគតិអហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិ។




## ❀ រូបក្ខន្ធនឹងមិនរលត់

- ភូមិដែលមានរូបក្ខន្ធ រូបក្ខន្ធនឹងមិនរលត់ បាន (ឆិ.), ភូមិដែលមិនមាន រូបក្ខន្ធ បាន (ធិ. ឆិ.)។

- បុគ្គលដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន។

- បុគ្គលដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងអរូបភូមិទៀត (វៀរភូមិដែលទាបជាងខ្លួន) បរិនិព្វាន។

៙ អង្គធម៌ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ ដែលហៅថា ភង្គក្ខណសមង្គីរបស់បញ្ចវោការតិហេតុកចុតិចិត្ត ៩ ចេតសិក ៣៥ កម្មជរូប

ដែលកំពុងរលត់គ្រាចុងក្រោយ។

ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមភវិកៈ ដែលកំពុងកើតក្នុងអរូបភូមិ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ។

ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩ (វៀរចតុត្ថជ្ឈានភូមិ ៧) ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន ដែលហៅថា កន្ទក្ខណ-សមង្គីរបស់បញ្ចវោការតិហេតុកចុតិចិត្ត ៨ (វៀររូបាវចរបញ្ចមជ្ឈានចុតិចិត្ត ១) ចេតសិក ៣៥ កម្មជរូប ដែលកំពុងរលត់គ្រាចុងក្រោយ។

ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងស្លាប់ក្នុងអរូបភូមិទៀត (វៀរភូមិដែល ទាបជាងខ្លួន) បរិនិព្វាន។




❁ **នាមក្ខន្ធនឹងរលត់**

- ភូមិដែលមាននាមក្ខន្ធ បុគ្គលដែលកំពុងកើត នាមក្ខន្ធនឹងរលត់នៅពេលស្លាប់ បុគ្គលដែលកំពុងស្លាប់ នាមក្ខន្ធនឹងរលត់ក្នុងចតុវោការភូមិ បញ្ចវោការភូមិទៀត។

- សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ។

៙ អន្តធម៌ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ ១)។




❁ **នាមក្ខន្ធនឹងមិនរលត់**

- ភូមិដែលមាននាមក្ខន្ធ នាមក្ខន្ធនឹងមិនរលត់ បាន (ឆិ)

៙ អន្តធម៌ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុង ចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា កន្ទក្ខណសមង្គីរបស់តិហេតុកចុតិចិត្ត ១៣ ចេតសិក ៣៥ កម្មជរូបដែលកំពុងរលត់គ្រាចុងក្រោយ។

# បវត្តិវារៈ និរោធវារៈ អនាគតវារៈ អនុលោម បុគ្គលវារៈ

## (វំ. និ. ៣ នុ. ឈ.)

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយចកៈ

**អនុលោមបុច្ឆា** យស្ស រូបក្ខន្ធោ និរុជ្ឈិស្សតិ, តស្ស វេទនាខន្ធោ និរុជ្ឈិស្សតីតិ? *រូបក្ខន្ធនឹងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា** អាមន្តា *មែន។*

**បដិលោមបុច្ឆា** យស្ស វា បន វេទនាខន្ធោ និរុជ្ឈិស្សតិ, តស្ស រូបក្ខន្ធោ និរុជ្ឈិស្សតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា** បច្ឆិមភវិកានំ អរូបំ ឧបបជ្ជន្តានំ យេ ច អរូបំ ឧបបជ្ជិត្វា បរិនិព្វាយិស្សន្តិ តេសំ ចវន្តានំ តេសំ វេទនាខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ រូបក្ខន្ធោ និរុជ្ឈិស្សតិ, ឥតរេសំ តេសំ វេទនាខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈិស្សតិ។ *ពួកបច្ឆិមភវិកបុគ្គលដែលកំពុងកើតក្នុងអរូបភូមិក្តី ពួកបុគ្គលណា នឹងទៅកើតក្នុងអរូបភូមិ ហើយបរិនិព្វានពួកបុគ្គលនោះកំពុងស្លាប់ក្តី វេទនាខន្ធនឹងរលត់ តែរូបក្ខន្ធនឹងមិនរលត់ដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលនៅសល់ក្រៅពីនោះ វេទនាខន្ធក៏នឹងរលត់ រូបក្ខន្ធ ក៏នឹងរលត់។*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

### ក្នុងអនុលោមបុច្ឆា

យស្ស រូបក្ខន្ធោ និរុជ្ឈិស្សតិ *ជាសន្និដ្ឋានបទ។*

តស្ស វេទនាខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទ។*

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងបញ្ចវោការភូមិទៀត, សុគតិអហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិ។

៙ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា រូបក្ខន្ធនឹងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងបញ្ចវោការភូមិទៀត, សុគតិ-អហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏នឹងរលត់ផង។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន វេទនាខន្ធោ និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស រូបក្ខន្ធោ និរុជ្ឈិស្សតិ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមកភវិកៈ ដែលកំពុងកើតក្នុងអរូបភូមិ ដែលហៅថា ឧប្បាទក្ខណសមង្គីរបស់អរូបបដិសន្ធិចិត្ត ៤ ចេតសិក ៣០, ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩ (វៀរចតុត្ថជ្ឈានភូមិ ៧) ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន ដែលហៅថា ភង្គក្ខណសមង្គីរបស់បញ្ចវោការតិហេតុកចុតិចិត្ត ៨(វៀររូបាវចរបញ្ចមជ្ឈានចុតិចិត្ត ១) ចេតសិក ៣៥ កម្មជរូបដែលកំពុងរលត់គ្រាចុងក្រោយ, ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងអរូបភូមិទៀត (វៀរភូមិដែលទាបជាងខ្លួន) បរិនិព្វាន,

**និង** បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ, បុថុជ្ជន ៤

ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងបញ្ចវោ-ការភូមិទៀត, សុគតិអហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិ។

៙ អន្តធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងបញ្ចវោការភូមិទៀត, សុគតិអហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមភវិកៈ ដែលកំពុងកើតក្នុងអរូបភូមិ ដែលហៅថា។ល។, ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩ (វៀរចតុត្ថជ្ឈានភូមិ ៧) ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន ដែលហៅថា។ល។, ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតអរូបភូមិទៀត (វៀរភូមិដែលទាបជាងខ្លួន) បរិនិព្វាន ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **បច្ឆិមភវិកានំ អរូបំ ឧបបជ្ជន្តានំ យេ ច អរូបំ ឧបបជ្ជិត្វា បរិនិព្វាយិស្សន្តិ តេសំ ចវន្តានំ តេសំ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ រូបក្ខន្ធោ និរុជ្ឈិស្សតិ** ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងបញ្ចវោការភូមិទៀត, សុគតិអហេតុកបុគ្គល ១ តិហេតុកបុថុជ្ជន ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ អរូបភូមិ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **ឥតរេសំ តេសំ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈិស្សតិ**

*ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ*

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលះ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យស្ស វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, តស្ស សញ្ញាក្ខន្ធោ និរុជ្ឈិស្សតីតិ? *វេទនាខន្ធនឹងរលត់ដល់បុគ្គលណា, សញ្ញាខន្ធក៏នឹងរលត់ដល់បុគ្គល នោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

**បដិលោមបុច្ឆាៈ** យស្ស វា បន សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ, តស្ស វេទនាក្ខន្ធោ និរុជ្ឈិស្សតីតិ? *មួយវិញទៀត សញ្ញាខន្ធនឹងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស វេទនាក្ខន្ធោ និរុជ្ឈិស្សតិ *ជាសន្និដ្ឋានបទៗ*

តស្ស សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទៗ*

*◉ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ ១)ៗ*

*◉ អត្ថធម៌របស់សំសយបទ ដូចគ្នាៗ*

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា វេទនាខន្ធនឹងរលត់ដល់បុគ្គលណា, សញ្ញាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអសញ្ញសត្តភូមិ ១) ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏នឹងរលត់ផង។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន សញ្ញាខន្ធោ និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស វេទនាខន្ធោ និរុជ្ឈិស្សតិ** ជាសំសយបទ។

៙ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអសញ្ញសត្តភូមិ ១)។

៙ អង្គធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា សញ្ញាខន្ធនឹងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអសញ្ញសត្តភូមិ ១) ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏នឹងរលត់ផង។

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលវារៈ)**

# បវត្តិវារៈ និរោធវារៈ អនាគតវារៈ អនុលោម ឱកាសវារៈ

## (វ. និ. ៣ នុ. ឱ.)

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ, តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតីតិ? *រូបក្ខន្ធនឹងរលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អសញ្ញសត្តេ តត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, បញ្ចវោការេ តត្ថ រូបក្ខន្ធោ ច និរុជ្ឈិស្សតិ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ។ *ក្នុងអសញ្ញសត្តភូមិនោះ រូបក្ខន្ធនឹងរលត់ តែវេទនាខន្ធនឹងមិនរលត់ក្នុងភូមិនោះ, ក្នុងបញ្ចវោការភូមិនោះ រូបក្ខន្ធក៏នឹងរលត់ វេទនាខន្ធក៏នឹងរលត់។*

**បដិលោមបុច្ឆាៈ** យត្ថ វា បន វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, តត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ក្នុងភូមិណា, រូបក្ខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អរូបេ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ, បញ្ចវោការេ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈិស្សតិ។ *ក្នុងអរូបភូមិនោះ វេទនាខន្ធនឹងរលត់ តែរូបក្ខន្ធនឹងមិនរលត់ក្នុងភូមិនោះ, ក្នុងបញ្ចវោការភូមិនោះ វេទនាខន្ធក៏នឹងរលត់ រូបក្ខន្ធក៏នឹងរលត់។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ *ជាសន្និដ្ឋានបទ។*

**តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតិ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង,

និង បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។

៙ អន្តធម៌របស់សំសយបទ បានដល់ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា រូបក្ខន្ធនឹងរលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអន្តធម៌របស់សន្និដ្ឋានបទ បានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អសញ្ញសត្តេ តត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតិ** ហើយទ្រង់លើកយក បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការេ តត្ថ រូបក្ខន្ធោ ច និរុជ្ឈិស្សតិ វេទនាខន្ធោ ច និរុជ្ឈិស្សតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន វេទនាខន្ធោ និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤,

និង បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។

៙ អន្តធម៌របស់សំសយបទ បានដល់ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ប៉ុណ្ណោះ។

*ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ក្នុងភូមិណា, រូបក្ខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **អរូបេ តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតិ នោ ច តត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ** *ហើយទ្រង់លើកយក បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **បញ្ចវោការេ តត្ថ វេទនាខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈិស្សតិ** *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ*

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលះ)**

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យត្ថ វេទនាខន្ធោ និរុជ្ឈិស្សតិ, តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតីតិ? *វេទនាខន្ធនឹងរលត់ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

**បដិលោមបុច្ឆាៈ** យត្ថ វា បន សញ្ញាខន្ធោ និរុជ្ឈិស្សតិ, តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែនៗ*

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

### ក្នុងអនុលោមបុច្ឆា

**យត្ថ វេទនាខន្ធោ និរុជ្ឈិស្សតិ** *ជាសន្និដ្ឋានបទ។*

**តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ** *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*៙ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា វេទនាខន្ធនឹងរលត់ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ***បដិវចនវិសជ្ជនាថា អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏នឹងរលត់ផង។*

### ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន សញ្ញាខន្ធោ និរុជ្ឈិស្សតិ** *ជាសន្និដ្ឋានបទ។*

**តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតិ** *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*៙ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា មយ៉ាងទៀត សញ្ញាខន្ធនឹងរលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ***បដិវចនវិសជ្ជនាថា អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏នឹងរលត់ផង។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ និកាសវារៈ)**

# អព្ពធម៌ ក្នុងនិរោធវារៈ អនាគតវារៈ ឲ្យុក្តលោកាសវារៈ

| | វំ.និ.៣.នុ.លោ | វំ.និ.៣.ច.លោ |
|---|---|---|
| **ខន្ធ ៥** | **នឹងរលត់** | **នឹងមិនរលត់** |
| **រូបក្ខន្ធ** | អសញ្ញី សុ.១<br>បញ្ចវោ. ២៦ ២១(-៥)<br>បុ.៤+៣ បញ្ច.២៦ ៤+៣បញ្ច.២១(-៥) → កូមិ.ទៀត (ប.)<br>សុ.១ អសញ្ញ.១ សុ.១ អសញ្ញ.១ → អសញ្ញ.ទៀត (ញ.) | អរូប. ៤<br>អរផ.១បរិ.បញ្ច.២២(-៤) (បដិ.)<br>អសញ្ញី. សុ.១ ✳ ✳ បុ.៤+៣ បញ្ច.២៥(-១) → មិន.កូមិ.ទៀត<br>✳ សុ.១អសញ្ញ.១ → មិន.អសញ្ញ.ទៀត<br>បញ្ចវោ. ២៦ និ ✳ តិ.បុ១+៤អរូប៤ (អ.) |
| **នាមក្ខន្ធ** | អរូប ៤<br>បញ្ចវោ. ២៦ ២១(-៥)<br>បុ.៤+៣ ចតុ៤ បញ្ច២៦ ៤+៣ចតុ៤ បញ្ច២១(-៥ → កូមិ.ទៀត<br>(តុប.) | អរូប. ៤ និ ✳<br>អរផ.១បរិ.ចតុ.៤ បញ្ច.២២(-៤) (ដិ.)<br>អសញ្ញី. សុ.១<br>✳ បុ.៤+៣.ចតុ.៤ បញ្ច.២៥(-អក១) → មិន.កូមិ.ទៀត<br>បញ្ចវោ. ២៦ និ ✳ សុ.១ អសញ្ញ.១ (ញ.) |

# វិធីគិត និង អគ្គធម៌ក្នុង ទ. និ. ៣ នុ. ច. លោ.

អសញ្ញី ⑊ ស្ុ.១ /

បញ្ចវោ. ⑊ ២៦ ២១(-៥) / ❁ **រូបក្ខន្ធនឹងរលត់**

- ភូមិដែលមានរូបក្ខន្ធ បុគ្គលដែលកំពុងកើត រូបក្ខន្ធនឹងរលត់នៅពេលស្លាប់ បុគ្គលដែលកំពុងស្លាប់ រូបក្ខន្ធនឹងរលត់ក្នុងភូមិដែលខ្ជួនកើតនៅទៀត។

៙ អគ្គធម៌ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ២៦, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការ-ភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ហើយនឹងរលត់ក្នុងភូមិដែលខ្ជួនកើតនៅទៀត។

សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ, សុគតិអហេតុក-បុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ១ ហើយនឹងរលត់ក្នុងអសញ្ញសត្តភូមិទៀត។

អរូប. ⑊ ៤ ///

អសញ្ញី. ស្ុ.១ /

✳

❁ **រូបក្ខន្ធនឹងមិនរលត់**

បញ្ចវោ. ២៦ // - ភូមិដែលមានរូបក្ខន្ធ រូបក្ខន្ធនឹងមិនរលត់ បាន (ឆិ. ✳)

និ - ភូមិដែលមិនមានរូបក្ខន្ធ បានទាំងអស់ មិនមានសល់។

✳

៙ អគ្គធម៌ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ ២២(វៀរអបាយភូមិ ៤) ដែលហៅថា ភង្គក្ខណសមង្គីរបស់បញ្ចវោការតិហេតុកចុតិចិត្ត ៩ ចេតសិក ៣៥ កម្មជរូបដែលកំពុងរលត់គ្រាចុងក្រោយ(បរិនិព្វុត្តដោយត្រង់)។

✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) ហើយនឹងមិនកើតក្នុងភូមិដែលខ្ជួនកើតនៅទៀត ដែលហៅថា ភង្គក្ខណសមង្គីរបស់បញ្ចវោការចុតិចិត្ត ១៥ ចេតសិក ៣៥ កម្មជរូបដែលកំពុងរលត់គ្រាចុងក្រោយ (បរិនិព្វុត្តដោយអម)។

✳ សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ១ ហើយនឹងមិនកើតក្នុងអសញ្ញសត្តភូមិទៀត ដែលហៅថា កន្ទក្ខណសមង្គីរបស់ជីវិតនវកកលាបដែលកំពុងរលត់គ្រាចុងក្រោយ (បរិនិព្វានដោយអម)។

តិហេតុកបុថុជ្ជន ១ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ៤។

អរូប ⑊ ៤ /

បញ្ចវោ. ⑊ ២៦ ២១(-៥) /

## ❁ នាមក្ខន្ធនឹងរលត់

- ភូមិដែលមាននាមក្ខន្ធ ពួកបុគ្គលដែលកំពុងកើត នាមក្ខន្ធនឹងរលត់នៅពេលស្លាប់ ពួកបុគ្គលដែលកំពុងស្លាប់ នាមក្ខន្ធនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត។

៙ អន្តធម៌ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៦, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត។

- អរូប. ៤ //

និ ✳

## ❁ នាមក្ខន្ធនឹងមិនរលត់

- អសញ្ញី. ⑊ សុ.១ //

- បញ្ចវោ. ២៦ // - ភូមិដែលមាននាមក្ខន្ធ នាមក្ខន្ធនឹងមិនរលត់ បាន (និ. ✳)

និ ✳ - ភូមិដែលមិនមាន នាមក្ខន្ធ បានទាំងអស់មិនមានសល់។

៙ អន្តធម៌ បានដល់អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) ដែលហៅថា កន្ទក្ខណសមង្គីរបស់តិហេតុកចុតិចិត្ត ១៣ ចេតសិក ៣៥ កម្មជរូបដែលកំពុងរលត់គ្រាចុងក្រោយ (បរិនិព្វានដោយត្រង់)។

* *បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) ហើយនឹងមិនកើតក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា កន្ធក្ខណសមង្គីរបស់ចុតិចិត្ត ១៩ ចេតសិក ៣៥ កម្មជរូបដែលកំពុងរលត់ គ្រាចុងក្រោយ(បរិនិព្វុត្តដោយអម)។*

*សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ១។*

## បវត្តិវារៈ និរោធវារៈ អនាគតវារៈ អនុលោម បុគ្គលោកាសវារៈ

### (វំ. និ. ៣ នុ. លោ.)

### ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ, តស្ស តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតីតិ? *រូបក្ខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អសញ្ញសត្តានំ តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតិ, បញ្ចវោការានំ តេសំ តត្ថ រូបក្ខន្ធោ ច និរុជ្ឈិស្សតិ វេទនាខន្ធោ ច និរុជ្ឈិស្សតិ។ *ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធនឹងរលត់ តែវេទនាខន្ធនឹងមិនរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងបញ្ចវោការភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធក៏នឹងរលត់ វេទនាខន្ធក៏នឹងរលត់។*

**បដិលោមបុច្ឆា៖** យស្ស វា បន យត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, តស្ស តត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា៖** អរូបានំ តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ, បញ្ចវោការានំ តេសំ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈិស្សតិ។ *ពួកបុគ្គលដែលកើតនៅក្នុងអរូបភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធនឹងរលត់ តែរូបក្ខន្ធនឹងមិនរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងបញ្ចវោការភូមិ ក្នុងភូមិនោះ វេទនាខន្ធ ក៏នឹងរលត់ រូបក្ខន្ធក៏នឹងរលត់។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ *ជាសន្និដ្ឋានបទ។*

តស្ស តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទ។*

*១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ហើយនឹងកើតក្នុងអសញ្ញសត្តភូមិទៀត និងអសញ្ញសត្តភូមិ ១,*

**និង** *បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ និងបញ្ចវោការភូមិ ២៦, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។*

*១ អត្ថធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ និងបញ្ចវោការភូមិ ២៦, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។*

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា រូបក្ខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែង ដោយការលើកយក សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ហើយនឹងកើតក្នុងអស-ញ្ញសត្តភូមិទៀត និងអសញ្ញសត្តភូមិ ១ ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អសញ្ញសត្តានំ តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ** ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ និងបញ្ចវោការភូមិ ២៦, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោ-ការានំ តេសំ តត្ថ រូបក្ខន្ធោ ច និរុជ្ឈិស្សតិ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិភង្គដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ** ជាសំសយបទ។

๑ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងអរូបភូមិ ៤,

និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ និងបញ្ចវោការភូមិ ២៦, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ

ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាស-ភូមិ ៥)ៗ

១ អគ្គធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ និងបញ្ចវោការភូមិ ២៦, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះៗ

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងអរូបភូមិ ៤ ដែលជាអគ្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អរូបានំ តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈិស្សតិ** ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ និងបញ្ចវោការភូមិ ២៦, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអគ្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការានំ តេសំ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈិស្សតិ** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិគ្គហៈដោយត្រង់ៗ

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, តស្ស តត្ថ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតីតិ? *វេទនាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

**បដិលោមបុច្ឆាៈ** យស្ស វា បន យត្ថ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ, តស្ស តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ *ជាសន្និដ្ឋានបទ។*

តស្ស តត្ថ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៦, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។*

*៙ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចុប្បន្នបញ្ហា សួរថា វេទនាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌*

របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៦, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏នឹងរលត់ផង។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតិ** ជាសំសយបទ។

១ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៦, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។

១ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចុបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៦, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងក្នុងភូមិដែលខ្លួនកើតនៅទៀត និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធ ក៏នឹងរលត់ផង។

**(មូលី មូលៈ ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ បុគ្គលោកាសវារៈ)**

(ចប់ និរោធវារៈ អនាគតវារៈ អនុលោម)

❋❋❋

# បវត្តិវារៈ និរោធវារៈ អនាគតវារៈ បច្ចនីកៈ បុគ្គលវារៈ

(វំ. និ. ៣ ប. ឈ.)

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា:** យស្ស រូបក្ខន្ធោ ន និរុជ្ឈិស្សតិ, តស្ស វេទនាក្ខន្ធោ ន និរុជ្ឈិស្សតីតិ? *រូបក្ខន្ធនឹងមិនរលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** បច្ឆិមភវិកានំ អរូបំ ឧបបជ្ជន្តានំ យេ ច អរូបំ ឧបបជ្ជិត្វា បរិនិព្ពាយិស្សន្តិ តេសំ ចវន្តានំ តេសំ រូបក្ខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ, បរិនិព្ពន្តានំ តេសំ រូបក្ខន្ធោ ច ន និរុជ្ឈិស្សតិ វេទនាក្ខន្ធោ ច ន និរុជ្ឈិស្សតិ។ *ពួកបច្ឆិមភវិកបុគ្គលដែលកំពុងកើតក្នុងអរូបភូមិក្តី ពួកបុគ្គលណា នឹងទៅកើតក្នុងអរូបភូមិ ហើយបរិនិព្វាន ពួកបុគ្គលនោះកំពុងស្លាប់ក្តី រូបក្ខន្ធ នឹងមិនរលត់ តែវេទនាខន្ធនឹងរលត់ដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វាន ក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ រូបក្ខន្ធក៏នឹងមិនរលត់ វេទនាខន្ធក៏នឹងមិនរលត់។*

**បដិលោមបុច្ឆា:** យស្ស វា បន វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ, តស្ស រូបក្ខន្ធោ ន និរុជ្ឈិស្សតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** អាមន្តា *មែន។*

# ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

# ក្នុងអនុលោមបុច្ឆា

យស្ស រូបក្ខន្ធោ ន និរុជ្ឈិស្សតិ ជាសន្និដ្ឋានបទ។

តស្ស វេទនាខន្ធោ ន និរុជ្ឈិស្សតិ ជាសំសយបទ។

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមកភវិកៈ ដែលកំពុងកើតក្នុងអរូបភូមិ ដែលហៅថា។ល។, ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩ (វៀរចតុត្ថជ្ឈានភូមិ ៧) ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន ដែលហៅថា។ល។, ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងអរូបភូមិទៀត (វៀរភូមិដែលទាបជាងខ្លួន) បរិនិព្វាន,

និង អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។

៙ អត្ថធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា រូបក្ខន្ធនឹងមិនរលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមកភវិកៈ ដែលកំពុងកើតក្នុងអរូបភូមិ ដែលហៅថា។ល។, ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងកាមសុគតិភូមិ ៧ រូបភូមិ ៩ (វៀរចតុត្ថជ្ឈានភូមិ ៧) ហើយនឹងទៅកើតក្នុងអរូបភូមិ បរិនិព្វាន ដែលហៅថា។ល។, ផលសេក្ខបុគ្គល ៣ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងកើតក្នុងអរូបភូមិទៀត (វៀរភូមិដែលទាបជាងខ្លួន) បរិនិព្វាន ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ បានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **បច្ឆិមភវិកានំ អរូបំ ឧបបជ្ជន្តានំ យេ ច អរូបំ ឧបបជ្ជិត្វា បរិនិព្វាយិស្សន្តិ តេសំ ចវន្តានំ តេសំ រូបក្ខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ វេទនាខន្ធោ ន និរុជ្ឈិស្សតិ,** ហើយទ្រង់លើកយក

អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ចិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បរិនិព្វន្តានំ តេសំ រូបក្ខន្ធោ ច ន និរុជ្ឈិស្សតិ វេទនាក្ខន្ធោ ច ន និរុជ្ឈិស្សតិ,** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកង្គដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស រូបក្ខន្ធោ ន និរុជ្ឈិស្សតិ** ជាសំសយបទ។

១ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។

១ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ **បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ រូបក្ខន្ធក៏នឹងមិនរលត់ផង។

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. ទេសនាខន្ធមូល:

## ១. វេទនាខន្ធមូល: សញ្ញាខន្ធមូលីយមក:

**អនុលោមបុច្ឆា:** យស្ស វេទនាខន្ធោ ន និរុជ្ឈិស្សតិ, តស្ស សញ្ញាខន្ធោ ន និរុជ្ឈិស្សតីតិ? *វេទនាខន្ធនឹងមិនរលត់ដល់បុគ្គលណា, សញ្ញាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** អាមន្តា *មែនៗ*

**បដិលោមបុច្ឆា:** យស្ស វា បន សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ, តស្ស វេទនាខន្ធោ ន និរុជ្ឈិស្សតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** អាមន្តា *មែនៗ*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាស:

## ក្នុងអនុលោមបុច្ឆា

យស្ស វេទនាខន្ធោ ន និរុជ្ឈិស្សតិ *ជាសន្និដ្ឋានបទ។*

តស្ស សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ *ជាសំសយបទ។*

*◉ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។*

*◉ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ឆាបញ្ហា សួរថា វេទនាខន្ធនឹងមិនរលត់ដល់បុគ្គលណា, សញ្ញាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ* ***បដិវចនវិសជ្ជនាថា អាមន្តា*** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ*

ដែលហៅថា។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏នឹងមិនរលត់ផង។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស វេទនាខន្ធោ ន និរុជ្ឈិស្សតិ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។

៙ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏នឹងមិនរលត់ផង។

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ បុគ្គលវារៈ)**

# បវត្តិវារៈ និរោធវារៈ អនាគតវារៈ បច្ចនីកៈ ឱកាសវារៈ

## (វ. និ. ៣ ច. ឱ.)

## ក. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យត្ថ រូបក្ខន្ធោ ន និរុជ្ឈិស្សតិ, តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតីតិ? *រូបក្ខន្ធនឹងមិនរលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងមិនរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** និរុជ្ឈិស្សតិ *នឹងរលត់ៗ*

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា វេទនាខន្ធមិនមែនកំពុងរលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា ។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាងទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធ សំសយបទ ដូចបានសំដែងថា **ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈតិ នោ ច តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិត្ថ** ហើយទ្រង់លើកយក អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ដែលជាអង្គធម៌របស់ សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការ បដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសំ ឧបបជ្ជន្តានំ អសញ្ញសត្តានំ តេសំ តត្ថ វេទនាខន្ធោ ច ន និរុជ្ឈតិ សញ្ញាខន្ធោ ច ន និរុជ្ឈិត្ថ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្ប ដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាខន្ធោ ន និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ វេទនាខន្ធោ ន និរុជ្ឈតិ** ជាសំសយបទ។

๑ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥។

និង អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥ , សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១។

៙ អង្គធម៌របស់សំសយបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនមែនកំពុងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥ ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសេ បរិនិព្វន្តានំ តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈតិ,** ហើយទ្រង់លើកយកអនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និងសំសយបទ បានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសំ ឧបបជ្ជន្តានំ អសញ្ញសត្តានំ តេសំ តត្ថ សញ្ញាខន្ធោ ច ន និរុជ្ឈិត្ថ វេទនាខន្ធោ ច ន និរុជ្ឈតិ,** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិគ្គហដោយត្រង់។

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលោកាសវារៈ)**

## (ចប់ និរោធវារៈ បច្ចុប្បន្នាតីតវារៈ បច្ចនីកៈ)

# បវត្តិវារៈ និរោធវារៈ បច្ចុប្បន្នានាគតវារៈ អនុលោម បុគ្គលវារៈ

## (វ. និ. ៥(១+៣) នុ. ឈ.)

## គ. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយចកៈ

**អនុលោមបុច្ឆា:** យស្ស រូបក្ខន្ធោ និរុជ្ឈតិ, តស្ស វេទនាក្ខន្ធោ និរុជ្ឈិស្សតីតិ? *រូបក្ខន្ធកំពុងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** បញ្ចវោការេ បរិនិព្វន្តានំ តេសំ រូបក្ខន្ធោ និរុជ្ឈតិ នោ ច តេសំ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, ឥតរេសំ បញ្ចវោការា ចវន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ រូបក្ខន្ធោ ច និរុជ្ឈតិ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ។ *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិនោះ រូបក្ខន្ធកំពុងរលត់ តែវេទនាខន្ធនឹងមិនរលត់ដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិដែលក្រៅពីបរិនិព្វុតបុគ្គល និង ពួកបុគ្គលដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិនោះ រូបក្ខន្ធក៏កំពុងរលត់ វេទនាខន្ធក៏នឹងរលត់។*

**បដិលោមបុច្ឆា:** យស្ស វា បន វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, តស្ស រូបក្ខន្ធោ និរុជ្ឈតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏កំពុងរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** សព្វេសំ ឧបបជ្ជន្តានំ អរូបា ចវន្តានំ តេសំ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ រូបក្ខន្ធោ និរុជ្ឈតិ, បញ្ចវោការា ចវន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈតិ។ *ពួកបុគ្គលទាំងអស់ដែលកំពុងកើត និង ពួកបុគ្គលដែលកំពុងស្លាប់ក្នុងអរូបភូមិនោះ វេទនាខន្ធនឹងរលត់ តែរូបក្ខន្ធ*

មិនមែនកំពុងរលត់ដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ និង អសញ្ញសត្តភូមិនោះ វេទនាខន្ធក៏នឹងរលត់ រូបក្ខន្ធក៏កំពុងរលត់ៗ

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

**យស្ស រូបក្ខន្ធោ និរុជ្ឈតិ** ជាសន្និដ្ឋានបទៗ

**តស្ស វេទនាក្ខន្ធោ និរុជ្ឈិស្សតិ** ជាសំសយបទៗ

๑ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ ដែលហៅថាៗលៗ

និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ដែលហៅថាៗលៗ, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថាៗលៗ

๑ អន្តធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ដែលហៅថាៗលៗ, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថាៗលៗ ប៉ុណ្ណោះៗ

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា រូបក្ខន្ធកំពុងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ ដែលហៅថាៗលៗ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការេ បរិនិព្ពន្តានំ តេសំ រូបក្ខន្ធោ និរុជ្ឈតិ នោ ច តេសំ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ** ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ដែលហៅថាៗលៗ, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថាៗលៗ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **ឥតរេសំ បញ្ចវោការា**

ចវត្តានំ អសញ្ញសត្តា ចវត្តានំ តេសំ រូបក្ខន្ធោ ច និរុជ្ឈតិ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភត្តិដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន វេទនាក្ខន្ធោ និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស រូបក្ខន្ធោ និរុជ្ឈតិ** ជាសំសយបទ។

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ ដែលហៅថា ។ល។, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ដែលហៅថា ។ល។,

និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ដែលហៅថា ។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា ។ល។

៙ អត្ថធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ដែលហៅថា ។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា ។ល។ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏កំពុងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ ដែលហៅថា ។ល។, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ដែលហៅថា ។ល។ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **សព្វេសំ ឧបបជ្ជន្តានំ អរូបា ចវន្តានំ តេសំ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ រូបក្ខន្ធោ និរុជ្ឈតិ** ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ដែលហៅថា ។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុង

*អសញ្ញសត្តភូមិ ដែលហៅថាៗលៗ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទ បានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* បញ្ចវោការា ចវន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ វេទនាខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈតិ *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកន្តដោយត្រង់ៗ*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស វេទនាខន្ធោ និរុជ្ឈតិ, តស្ស សញ្ញាខន្ធោ និរុជ្ឈិស្សតីតិ? *វេទនាខន្ធកំពុងរលត់ដល់បុគ្គលណា, សញ្ញាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** បរិនិព្វន្តានំ តេសំ វេទនាខន្ធោ និរុជ្ឈតិ នោ ច តេសំ សញ្ញាខន្ធោ និរុជ្ឈិស្សតិ, ឥតរេសំ ចតុវោការា បញ្ចវោការា ចវន្តានំ តេសំ វេទនាខន្ធោ ច និរុជ្ឈតិ សញ្ញាខន្ធោ ច និរុជ្ឈិស្សតិ *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ វេទនាខន្ធកំពុងរលត់ តែសញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិដែលក្រៅពីបរិនិព្វន្តបុគ្គលនោះ វេទនាខន្ធក៏កំពុងរលត់ សញ្ញាខន្ធ ក៏នឹងរលត់ៗ*

**បដិលោមបុច្ឆាៈ** យស្ស វា បន សញ្ញាខន្ធោ និរុជ្ឈិស្សតិ, តស្ស វេទនាខន្ធោ និរុជ្ឈតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏កំពុងរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** *សព្វេសំ* **ឧបបជ្ជន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ វេទនាក្ខន្ធោ និរុជ្ឈតិ, ចតុវោការា បញ្ចវោការា ចវន្តានំ តេសំ សញ្ញាក្ខន្ធោ ច និរុជ្ឈិស្សតិ វេទនាក្ខន្ធោ ច និរុជ្ឈតិ។** *ពួកបុគ្គលទាំងអស់ដែលកំពុងកើត និង ពួកបុគ្គលដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិនោះ សញ្ញាខន្ធនឹងរលត់ តែ វេទនាខន្ធមិនមែនកំពុងរលត់ដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលកំពុងស្លាប់ក្នុង ចតុវោការភូមិ បញ្ចវោការភូមិនោះ សញ្ញាខន្ធ ក៏នឹងរលត់ វេទនាខន្ធក៏កំពុងរលត់។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

**យស្ស វេទនាក្ខន្ធោ និរុជ្ឈតិ** *ជាសន្និដ្ឋានបទ។*

**តស្ស សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ** *ជាសំសយបទ។*

*๏ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។*

*និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោ-ការភូមិ ដែលហៅថា។ល។*

*๏ អត្ថធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែល កំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា***បរិបុណ្ណបញ្ហា** *សួរថា វេទនាខន្ធកំពុងរលត់ដល់ បុគ្គលណា, សញ្ញាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការ លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **បរិនិព្វន្តានំ តេសំ វេទនាក្ខន្ធោ និរុជ្ឈតិ នោ ច តេសំ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ** *ហើយទ្រង់លើកយក*

*បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **ឥតរេសំ ចតុវោការេ បញ្ចវោការេ ចវន្តានំ តេសំ វេទនាក្ខន្ធោ ច និរុជ្ឈតិ សញ្ញាក្ខន្ធោ ច និរុជ្ឈិស្សតិ** *ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។*

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ** *ជាសន្និដ្ឋានបទ។*

**តស្ស វេទនាក្ខន្ធោ និរុជ្ឈតិ** *ជាសំសយបទ។*

*๑ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ ដែលហៅថា។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។*

*និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។*

*๑ អត្ថធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏កំពុងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ ដែលហៅថា។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **សព្វេសំ ឧបបជ្ជន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ វេទនាក្ខន្ធោ និរុជ្ឈតិ** *ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខ បុគ្គល*

៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **ចតុវោការេ បញ្ចវោការេ ចវន្តានំ តេសំ សញ្ញាខន្ធោ ច និរុជ្ឈិស្សតិ វេទនាខន្ធោ ច និរុជ្ឈតិ** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភត្តិដោយត្រង់។

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលវារៈ)**

# បវត្តិវារៈ និរោធវារៈ បច្ចុប្បន្នានាគតវារៈ អនុលោម ឱកាសវារៈ

**(វំ. និ. ៥(១+៣) នុ. ឱ.)**

## ក. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** **យត្ថ រូបក្ខន្ធោ និរុជ្ឈតិ, តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតីតិ?** *រូបក្ខន្ធកំពុងរលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ។*

**វិសជ្ជនាៈ** *អសញ្ញសត្តេ* **តត្ថ រូបក្ខន្ធោ និរុជ្ឈតិ នោ ច តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតិ, បញ្ចវោការេ តត្ថ រូបក្ខន្ធោ ច និរុជ្ឈតិ វេទនាខន្ធោ ច និរុជ្ឈិស្សតិ។** *ក្នុងអសញ្ញសត្តភូមិនោះ រូបក្ខន្ធកំពុងរលត់ តែវេទនាខន្ធនឹងមិនរលត់ក្នុងភូមិនោះ, ក្នុងបញ្ចវោការភូមិនោះ រូបក្ខន្ធក៏កំពុងរលត់ វេទនាខន្ធក៏នឹងរលត់។*

**បដិលោមបុច្ឆា:** យត្ថ វា បន វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, តត្ថ រូបក្ខន្ធោ និរុជ្ឈតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ក្នុងភូមិណា, រូបខន្ធ ក៏កំពុងរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** អរូបេ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, នោ ច តត្ថ រូបក្ខន្ធោ និរុជ្ឈតិ, បញ្ចវោការេ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈតិ។ *ក្នុងអរូបភូមិនោះ វេទនាខន្ធនឹងរលត់ តែរូបខន្ធមិនមែនកំពុងរលត់ក្នុងភូមិនោះ, ក្នុងបញ្ចវោការភូមិនោះ វេទនាខន្ធក៏នឹងរលត់ រូបខន្ធក៏កំពុងរលត់។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យត្ថ រូបក្ខន្ធោ និរុជ្ឈតិ *ជាសន្និដ្ឋានបទ។*

តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទ។*

*◉ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបខន្ធតែម្យ៉ាង,*

*និង បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*◉ អត្ថធម៌របស់សំសយបទ បានដល់ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា រូបខន្ធកំពុងរលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយកអសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបខន្ធតែម្យ៉ាង ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាស: មានការបដិសេធសំសយបទ ដូចបានសំដែងថា* អសញ្ញសត្តេ តត្ថ រូបក្ខន្ធោ និរុជ្ឈតិ នោ ច តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ *ហើយទ្រង់លើកយក បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥*

*ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ចិមកោដ្ឋាស: មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **បញ្ចវោការេ តត្ថ រូបក្ខន្ធោ ច និរុជ្ឈតិ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ** *ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆា នេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកន្តដោយត្រង់ៗ*

## ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន វេទនាក្ខន្ធោ និរុជ្ឈិស្សតិ** *ជាសន្និដ្ឋានបទ។*

**តត្ថ រូបក្ខន្ធោ និរុជ្ឈតិ** *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤។ និង បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*៙ អន្តធម៌របស់សំសយបទ បានដល់ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ក្នុងភូមិណា, រូបក្ខន្ធក៏កំពុងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ បានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាស: មានការបដិសេធសំសយបទ ដូចបានសំដែងថា* **អរូបេ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តត្ថ រូបក្ខន្ធោ និរុជ្ឈតិ** *ហើយទ្រង់លើកយកបញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ចិមកោដ្ឋាស: មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **បញ្ចវោការេ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈតិ** *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកន្តដោយត្រង់ៗ*

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. បេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យត្ថ វេទនាក្ខន្ធោ និរុជ្ឈតិ, តត្ថ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតីតិ? *វេទនាខន្ធកំពុងរលត់ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

**បដិលោមបុច្ឆាៈ** យត្ថ វា បន សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ, តត្ថ វេទនាក្ខន្ធោ និរុជ្ឈតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ក្នុងភូមិណា, វេទនាខន្ធក៏កំពុងរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យត្ថ វេទនាក្ខន្ធោ និរុជ្ឈតិ *ជាសន្និដ្ឋានបទ។*

តត្ថ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទ។*

*๏ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*๏ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចុប្បន្នបញ្ហា សួរថា វេទនាខន្ធកំពុងរលត់ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏នឹងរលត់ផង។*

## ក្នុងបដិលោមបុច្ឆា

យត្ថ វា បន សញ្ញាខន្ធោ និរុជ្ឈិស្សតិ *ជាសន្និដ្ឋានបទ។*

តត្ថ វេទនាខន្ធោ និរុជ្ឈតិ *ជាសំសយបទ។*

*◉ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*◉ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ក្នុងភូមិណា, វេទនាខន្ធក៏កំពុងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ* **បដិវចនវិសជ្ជនាថា អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏កំពុងរលត់ផង។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ និកាសវារៈ)**

---

## បវត្តិវារៈ និរោធវារៈ បច្ចុប្បន្នានាគតវារៈ អនុលោម បុគ្គលោកាសវារៈ

**(វ. និ. ៥(១+៣) នុ. លោ.)**

## ក. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ រូបក្ខន្ធោ និរុជ្ឈតិ, តស្ស តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតីតិ? *រូបក្ខន្ធកំពុងរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិស្សជ្ជនា៖** បញ្ចវោការេ បរិនិព្វន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈតិ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, ឥតរេសំ បញ្ចវោការា ចវន្តានំ តេសំ តត្ថ រូបក្ខន្ធោ ច និរុជ្ឈតិ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ។ *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ និង ពួកបុគ្គលដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធកំពុងរលត់ តែវេទនាខន្ធនឹងមិនរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ដែលក្រៅពីបរិនិព្វន្តបុគ្គលនោះ ក្នុងភូមិនោះ រូបក្ខន្ធក៏កំពុងរលត់ វេទនាខន្ធក៏នឹងរលត់ៗ*

**បដិលោមបុច្ឆា៖** យស្ស វា បន យត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, តស្ស តត្ថ រូបក្ខន្ធោ និរុជ្ឈតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏កំពុងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិស្សជ្ជនា៖** បញ្ចវោការំ ឧបបជ្ជន្តានំ អរូបានំ តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈតិ, បញ្ចវោការា ចវន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈតិ។ *ពួកបុគ្គលដែលកំពុងកើតក្នុងបញ្ចវោការភូមិ និង ពួកបុគ្គលដែលកើតនៅក្នុងអរូបភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធនឹងរលត់ តែរូបក្ខន្ធមិនមែនកំពុងរលត់ ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធក៏នឹងរលត់ រូបក្ខន្ធក៏កំពុងរលត់ៗ*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ រូបក្ខន្ធោ និរុជ្ឈតិ *ជាសន្និដ្ឋានបទៗ*

តស្ស តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទៗ*

๏ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វន្តដោយត្រង់),

✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) (បរិនិព្វន្តដោយអម),

សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១,

និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងកើតក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។

๏ អន្តធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា ។ល។ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា រូបក្ខន្ធកំពុងរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វន្តដោយត្រង់), បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) (បរិនិព្វន្តដោយអម), សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និ-ដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាស: មានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការេ បរិនិព្វន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈតិ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ**

ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា ។ល។ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **ឥតរេសំ បញ្ចវោការានំ តេសំ តត្ថ រូបក្ខន្ធោ ច និរុជ្ឈតិ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភត្តដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ រូបក្ខន្ធោ និរុជ្ឈតិ** ជាសំសយបទ។

១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថា ។ល។ និងបញ្ចវោការភូមិ ២៦, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងអរូបភូមិ ៤,

**និង** បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា ។ល។ និងបញ្ចវោការភូមិ ២១(វៀរសុទ្ធាវាសភូមិ ៥)

១ អត្ថធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា ។ល។ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏កំពុងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុង

*កើតក្នុងបញ្ចវោការភូមិ ដែលហៅថា ។ល។ និងបញ្ចវោការភូមិ ២៦, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ, តិហេតុកបុថុជ្ជន ១ ផលសេក្ខ-បុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងអរូបភូមិ ៤ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **បញ្ចវោការំ ឧបបជ្ជន្តានំ អរូបានំ តេសំ តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈតិ** *ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា ។ល។ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **បញ្ចវោការា ចវន្តានំ តេសំ តត្ថ វេទនាខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈតិ** *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភត្តិដោយត្រង់ៗ*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ២. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ វេទនាខន្ធោ និរុជ្ឈតិ, តស្ស តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតីតិ? *វេទនាខន្ធកំពុងរលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** បរិនិព្វន្តានំ តេសំ តត្ថ វេទនាខន្ធោ និរុជ្ឈតិ នោ ច តេសំ តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ, ឥតរេសំ ចតុវោការា បញ្ចវោការា ចវន្តានំ តេសំ តត្ថ វេទនាខន្ធោ ច និរុជ្ឈតិ

សញ្ញាខន្ធោ ច និរុជ្ឈិស្សតិ។ *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ក្នុងភូមិនោះ វេទនាខន្ធកំពុងរលត់ តែសញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលក្រៅពីបរិនិព្វុតបុគ្គលនោះ ក្នុងភូមិនោះ វេទនាខន្ធក៏កំពុងរលត់ សញ្ញាខន្ធក៏នឹងរលត់។*

**បដិលោមបុច្ឆា:** យស្ស វា បន យត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ, តស្ស តត្ថ វេទនាខន្ធោ និរុជ្ឈតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏កំពុងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ វេទនាខន្ធោ និរុជ្ឈតិ, ចតុវោការា បញ្ចវោការា ចវន្តានំ តេសំ តត្ថ សញ្ញាខន្ធោ ច និរុជ្ឈិស្សតិ វេទនាខន្ធោ ច និរុជ្ឈតិ។ *ពួកបុគ្គលដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ ក្នុងភូមិនោះ សញ្ញាខន្ធនឹងរលត់ តែវេទនាខន្ធមិនមែនកំពុងរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ ក្នុងភូមិនោះ សញ្ញាខន្ធក៏នឹងរលត់ វេទនាខន្ធក៏កំពុងរលត់។*

## ការសំដែងអង្គធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ វេទនាខន្ធោ និរុជ្ឈតិ *ជាសន្និដ្ឋានបទ។*

តស្ស តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទ។*

*១ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា ។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វុតដោយត្រង់),*

✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា ។ល។ និង ចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) (អន្តធម៌ដោយអម)។

និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និង ចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។

๑ អន្តធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា វេទនាខន្ធកំពុងរលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វុតដោយត្រង់), បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) (បរិនិព្វុតដោយអម) ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **បរិនិព្វន្តានំ តេសំ តត្ថ វេទនាខន្ធោ និរុជ្ឈតិ នោ ច តេសំ តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ** ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **ឥតរេសំ ចតុវោការា បញ្ច-**

វោការា ចវត្ថានំ តេសំ តត្ថ វេទនាខន្ធោ ច និរុជ្ឈតិ សញ្ញាខន្ធោ ច និរុជ្ឈិស្សតិ *ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរុបទស្សនវិសជ្ជនា ដែលមានវិកប្ពដោយត្រង់ៗ*

## ក្នុងបដិលោមបុច្ឆា

យស្ស វា បន យត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ *ជាសន្និដ្ឋានបទ។*

តស្ស តត្ថ វេទនាខន្ធោ និរុជ្ឈតិ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៦,*

*និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។*

*៙ អត្ថធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១(វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា***បរិបុណ្ណបញ្ហា** *សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏កំពុងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៦ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ វេទនាខន្ធោ និរុជ្ឈតិ *ហើយទ្រង់លើកយកបុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣*

*ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាស: មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **ចតុវោការា បញ្ចវោការា ចវន្តានំ តេសំ តត្ថ សញ្ញាក្ខន្ធោ ច និរុជ្ឈិស្សតិ វេទនាក្ខន្ធោ ច និរុជ្ឈតិ** *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្ពដោយត្រង់ៗ*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលោកាសវារៈ)**

## (ចប់ និរោធវារៈ បច្ចុប្បន្នានាគតវារៈ អនុលោម)

## បវត្តិវារៈ និរោធវារៈ បច្ចុប្បន្នានាគតវារៈ បច្ចនីកៈ បុគ្គលវារៈ

**(វំ. និ. ៥(១+៣) ច. ឈ.)**

## ក. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា:** យស្ស រូបក្ខន្ធោ ន និរុជ្ឈតិ, តស្ស វេទនាក្ខន្ធោ ន និរុជ្ឈិស្សតីតិ? *រូបក្ខន្ធមិនមែនកំពុងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** *សព្វេសំ* ឧបបជ្ជន្តានំ *អរូបា* ចវន្តានំ តេសំ *រូបក្ខន្ធោ* ន និរុជ្ឈតិ នោ ច តេសំ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ, *អរូបេ* បរិនិព្វន្តានំ តេសំ *រូបក្ខន្ធោ* ច ន និរុជ្ឈតិ វេទនាក្ខន្ធោ ច ន

និរុជ្ឈិស្សតិ។ ពួកបុគ្គលទាំងអស់ដែលកំពុងកើត និង ពួកបុគ្គលដែលកំពុងស្លាប់ក្នុងអរូបភូមិនោះ រូបក្ខន្ធមិនមែនកំពុងរលត់ តែវេទនាខន្ធនឹងរលត់ដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងអរូបភូមិនោះ រូបក្ខន្ធក៏មិនមែនកំពុងរលត់ វេទនាខន្ធក៏នឹងមិនរលត់។

**បដិលោមបុច្ឆា:** យស្ស វា បន វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ, តស្ស រូបក្ខន្ធោ ន និរុជ្ឈតីតិ? ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏មិនមែនកំពុងរលត់ដល់បុគ្គលនោះឬ?

**វិសជ្ជនា:** បញ្ចវោការេ បរិនិព្វន្តានំ តេសំ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ រូបក្ខន្ធោ ន និរុជ្ឈតិ, អរូបេ បរិនិព្វន្តានំ តេសំ វេទនាក្ខន្ធោ ច ន និរុជ្ឈិស្សតិ រូបក្ខន្ធោ ច ន និរុជ្ឈតិ។ ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិនោះ វេទនាខន្ធនឹងមិនរលត់ តែរូបក្ខន្ធកំពុងរលត់ដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងអរូបភូមិនោះ វេទនាខន្ធក៏នឹងមិនរលត់ រូបក្ខន្ធក៏មិនមែនកំពុងរលត់។

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ
## ក្នុងអនុលោមបុច្ឆា

យស្ស រូបក្ខន្ធោ ន និរុជ្ឈតិ ជាសន្និដ្ឋានបទ។

តស្ស វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ ជាសំសយបទ។

๑ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ ដែលហៅថា។ល។, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ដែលហៅថា។ល។,

និង អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា។ល។

๑ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា។ល។ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា រូបក្ខន្ធមិនមែនកំពុងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយកបុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ ដែលហៅថា ។ល។, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ដែលហៅថា ។ល។ ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **សព្វេសំ ឧបបជ្ជន្តានំ អរូបា ចវន្តានំ តេសំ រូបក្ខន្ធោ ន និរុជ្ឈតិ នោ ច តេសំ វេទនាខន្ធោ ន និរុជ្ឈិស្សតិ** ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា ។ល។ ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **អរូបេ បរិនិព្វន្តានំ តេសំ រូបក្ខន្ធោ ច ន និរុជ្ឈតិ វេទនាខន្ធោ ច ន និរុជ្ឈិស្សតិ**, ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភង្គដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន វេទនាខន្ធោ ន និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស រូបក្ខន្ធោ ន និរុជ្ឈតិ** ជាសំសយបទ។

៙ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ ដែលហៅថា ។ល។,

និង អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា ។ល។

៙ អង្គធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា ។ល។ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏មិនមែនកំពុងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ

*ដែលហៅថា។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **បញ្ចវោការេ បរិនិព្វន្តានំ តេសំ វេទនាខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ រូបក្ខន្ធោ ន និរុជ្ឈតិ** *ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុង អរូបភូមិ ដែលហៅថា។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទ បានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **អរូបេ បរិនិព្វន្តានំ តេសំ វេទនាខន្ធោ ច ន និរុជ្ឈិស្សតិ រូបក្ខន្ធោ ច ន និរុជ្ឈតិ** *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកន្តដោយត្រង់។*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលះ)**

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យស្ស វេទនាខន្ធោ ន និរុជ្ឈតិ, តស្ស សញ្ញាខន្ធោ ន និរុជ្ឈិស្សតីតិ? *វេទនាខន្ធមិនមែនកំពុងរលត់ដល់បុគ្គលណា, សញ្ញាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** និរុជ្ឈិស្សតិ *នឹងរលត់។*

**បដិលោមបុច្ឆាៈ** យស្ស វា បន សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ, តស្ស វេទនាខន្ធោ ន និរុជ្ឈតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលណា, វេទនាខន្ធ ក៏មិនមែនកំពុងរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** និរុជ្ឈតិ *កំពុងរលត់។*

# ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

**យស្ស វេទនាខន្ធោ ន និរុជ្ឈតិ** *ជាសន្និដ្ឋានបទ។*

**តស្ស សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ** *ជាសំសយបទ។*

*១ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ ដែលហៅថា។លៗ, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។លៗ*

*១ អន្តធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា វេទនាខន្ធមិនមែនកំពុងរលត់ដល់បុគ្គលណា, សញ្ញាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ* **បាឡិគតិវិសជ្ជនាថា និរុជ្ឈិស្សតិ** *ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ ដែលហៅថា។លៗ, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។លៗ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីវេទនាខន្ធមិនមែនកំពុងរលត់ តែសញ្ញាខន្ធនឹងរលត់។*

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ** *ជាសន្និដ្ឋានបទ។*

**តស្ស វេទនាខន្ធោ ន និរុជ្ឈតិ** *ជាសំសយបទ។*

*១ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។លៗ*

*១ អន្តធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលណា, វេទនាខន្ធ ក៏មិនមែនកំពុងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់*

*សំដែងដោយបាឡិគតិវិសជ្ជនាថា* និរុជ្ឈតិ *ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថាឬលុ។ ដែលជាអគ្គធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីសញ្ញាខន្ធ នឹងមិនរលត់ តែវេទនាខន្ធកំពុងរលត់។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលវារៈ)**

## បវត្តិវារៈ និរោធវារៈ បច្ចុប្បន្នានាគតវារៈ បច្ចនីកៈ ឱកាសវារៈ

**(វំ. និ. ៥ (១+៣) ច. ឱ.)**

## ត. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា:** យត្ថ រូបក្ខន្ធោ ន និរុជ្ឈតិ, តត្ថ វេទនាខន្ធោ ន និរុជ្ឈិស្សតីតិ? *រូបក្ខន្ធមិនមែនកំពុងរលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងមិនរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** និរុជ្ឈិស្សតិ *នឹងរលត់។*

**បដិលោមបុច្ឆា:** យត្ថ វា បន វេទនាខន្ធោ ន និរុជ្ឈិស្សតិ, តត្ថ រូបក្ខន្ធោ ន និរុជ្ឈតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ក្នុងភូមិណា, រូបក្ខន្ធក៏មិនមែនកំពុងរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** និរុជ្ឈតិ *កំពុងរលត់។*

# ការសំដែងអង្គធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

**យត្ថ រូបក្ខន្ធោ ន និរុជ្ឈតិ** *ជាសន្និដ្ឋានបទ។*

**តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ** *ជាសំសយបទ។*

*៙ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤។*

*៙ អង្គធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា រូបក្ខន្ធមិនមែនកំពុងរលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងមិនរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ***បាឡិគតិវិសជ្ជនា** *ថា* **និរុជ្ឈិស្សតិ** *ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីរូបក្ខន្ធមិនមែនកំពុងរលត់ តែវេទនាខន្ធនឹងរលត់។*

## ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ** *ជាសន្និដ្ឋានបទ។*

**តត្ថ រូបក្ខន្ធោ ន និរុជ្ឈតិ** *ជាសំសយបទ។*

*៙ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។*

*៙ អង្គធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ក្នុងភូមិណា, រូបក្ខន្ធក៏មិនមែនកំពុងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបាឡិគតិវិសជ្ជនាថា* **និរុជ្ឈតិ** *ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីវេទនាខន្ធនឹងមិនរលត់ តែរូបក្ខន្ធកំពុងរលត់។*

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. ទេសនាខន្ធមូល:

## ១. វេទនាខន្ធមូល: សញ្ញាខន្ធមូលីយមក:

**អនុលោមបុច្ឆា:** យត្ថ វេទនាខន្ធោ ន និរុជ្ឈតិ, តត្ថ សញ្ញា-ខន្ធោ ន និរុជ្ឈិស្សតីតិ? *វេទនាខន្ធមិនមែនកំពុងរលត់ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងមិនរលត់ ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** អាមន្តា *មែន។*

**បដិលោមបុច្ឆា:** យត្ថ វា បន សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ, តត្ថ វេទនាខន្ធោ ន និរុជ្ឈតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ក្នុងភូមិណា, វេទនាខន្ធក៏មិនមែនកំពុងរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** អាមន្តា *មែន។*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាស:

### ក្នុងអនុលោមបុច្ឆា

យត្ថ វេទនាខន្ធោ ន និរុជ្ឈតិ *ជាសន្និដ្ឋានបទ។*

តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។*

*៙ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា វេទនាខន្ធមិនមែនកំពុងរលត់ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងមិនរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏នឹងមិនរលត់ផង។*

## ក្នុងបដិលោមបុច្ឆា

យត្ថ វា បន សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ *ជាសន្និដ្ឋានបទ។*

តត្ថ វេទនាខន្ធោ ន និរុជ្ឈតិ *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។*

*៙ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ក្នុងភូមិណា, វេទនាខន្ធក៏មិនមែនកំពុងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏មិនមែនកំពុងរលត់ផង។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ និកាសវារៈ)**

## បវត្តិវារៈ និរោធវារៈ បច្ចុប្បន្នានាគតវារៈ បច្ចនីកៈ បុគ្គលោកាសវារៈ

**(វំ. និ. ៥(១+៣) ច. លោ.)**

## ក. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ រូបក្ខន្ធោ ន និរុជ្ឈតិ, តស្ស តត្ថ វេទនាខន្ធោ ន និរុជ្ឈិស្សតីតិ? *រូបក្ខន្ធមិនមែនកំពុងរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា** បញ្ចវោការេ ឧបបជ្ជន្តានំ អរូបានំ តេសំ តត្ថ រូបក្ខន្ធោ ន និរុជ្ឈតិ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ, អរូបេ បរិនិព្វន្តានំ អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ តត្ថ រូបក្ខន្ធោ ច ន និរុជ្ឈតិ វេទនាក្ខន្ធោ ច ន និរុជ្ឈិស្សតិ។ *ពួកបុគ្គលដែលកំពុងកើតក្នុងបញ្ចវោការភូមិ និង ពួកបុគ្គលដែលកើតនៅក្នុងអរូបភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធមិនមែនកំពុងរលត់ តែវេទនាខន្ធនឹងរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងអរូបភូមិ និង ពួកបុគ្គលដែលកំពុងកើតក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធក៏មិនមែនកំពុងរលត់ វេទនាខន្ធក៏នឹងមិនរលត់។*

**បដិលោមបុច្ឆា** យស្ស វា បន យត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ, តស្ស តត្ថ រូបក្ខន្ធោ ន និរុជ្ឈតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏មិនមែនកំពុងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា** បញ្ចវោការេ បរិនិព្វន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ ន និរុជ្ឈតិ, អរូបេ បរិនិព្វន្តានំ អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ច ន និរុជ្ឈិស្សតិ រូបក្ខន្ធោ ច ន និរុជ្ឈតិ។ *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ និង ពួកបុគ្គលដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធនឹងមិនរលត់ តែរូបក្ខន្ធកំពុងរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងអរូបភូមិ និង ពួកបុគ្គលដែលកំពុងកើតក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធក៏នឹងមិនរលត់ រូបក្ខន្ធក៏មិនមែន កំពុងរលត់។*

# ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

# ក្នុងអនុលោមបុច្ឆា

**យស្ស យត្ថ រូបក្ខន្ធោ ន និរុជ្ឈតិ** *ជាសន្និដ្ឋានបទ។*

**តស្ស តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ** *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២៦,*

*តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងអរូបភូមិ ៤,*

*និង អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា ។ល។ និងអរូបភូមិ ៤ (បរិនិព្វន្តដោយត្រង់),*

*✳ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងអរូបភូមិ ៤ (បរិនិព្វន្តដោយអម),*

*សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១,។*

*៙ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា។ល។ និងអរូបភូមិ ៤ (បរិនិព្វន្តដោយត្រង់),*

*✳ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងអរូបភូមិ ៤ (អន្តធម៌ដោយអម),*

*សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១, ប៉ុណ្ណោះ។*

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា រូបក្ខន្ធមិនមែនកំពុងរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថា ។ល។ និងបញ្ចវោការភូមិ ២៦, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងអរូបភូមិ ៤ ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធ សំសយបទ ដូចបានសំដែងថា **បញ្ចវោការំ ឧបបជ្ជន្តានំ អរូបានំ តេសំ តត្ថ រូបក្ខន្ធោ ន និរុជ្ឈតិ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ** ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុង អរូបភូមិ ដែលហៅថា ។ល។ និងអរូបភូមិ ៤ (បរិនិព្វុតដោយត្រង់), តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា ។ល។ និងអរូបភូមិ ៤ (បរិនិព្វុតដោយអម), សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា ។ល។ និងអសញ្ញសត្តភូមិ ១, ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និងសំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិន មានការបដិសេធសំសយបទ ដូចបានសំដែងថា **អរូបេ បរិនិព្វន្តានំ អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ តត្ថ រូបក្ខន្ធោ ច ន និរុជ្ឈតិ វេទនាក្ខន្ធោ ច ន និរុជ្ឈិស្សតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិភត្តដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ រូបក្ខន្ធោ ន និរុជ្ឈតិ** ជាសំសយបទ។

៙ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វុត្តដោយត្រង់),

✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹង មិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា ។ល។ និងវោការភូមិ ២៥ (វៀរ អកនិដ្ឋកភូមិ ១) (បរិនិព្វុត្តដោយអម),

សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១,

**និង** អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា ។ល។ និងអរូបភូមិ ៤ (បរិនិព្វុត្តដោយត្រង់),

✳ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយ នឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងអរូបភូមិ ៤ (អង្គធម៌ ដោយអម),

សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១,។

៙ អង្គធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងអរូបភូមិ ដែលហៅថា។ល។ និងអរូបភូមិ ៤ (អង្គធម៌ដោយត្រង់),

✳ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយ នឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងអរូបភូមិ ៤ (បរិនិព្វុត្ត ដោយអម),

សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១, ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងមិន រលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏មិនមែនកំពុងរលត់ដល់បុគ្គលនោះ ក្នុងភូមិ នោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលកំពុង

បរិនិព្វានក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២២(វៀរអបាយភូមិ ៤) (បរិនិព្វន្តដោយត្រង់), បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) (បរិនិព្វន្តដោយអម), សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការេ បរិនិព្វន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ ន និរុជ្ឈតិ** ហើយទ្រង់លើកយកអរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុង អរូបភូមិ ដែលហៅថា។ល។ និងអរូបភូមិ ៤ (បរិនិព្វន្តដោយត្រង់), តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងអរូបភូមិ ៤ (បរិនិព្វន្តដោយអម), សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **អរូបេ បរិនិព្វន្តានំ អសញ្ញសត្តានំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ច ន និរុជ្ឈិស្សតិ រូបក្ខន្ធោ ច ន និរុជ្ឈតិ** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ វេទនាខន្ធោ ន និរុជ្ឈតិ, តស្ស តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតីតិ? *វេទនាខន្ធមិនមែនកំពុងរលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈតិ នោ ច តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ, អសញ្ញសត្តានំ តេសំ តត្ថ វេទនាខន្ធោ ច ន និរុជ្ឈតិ សញ្ញាខន្ធោ ច ន និរុជ្ឈិស្សតិ។ *ពួកបុគ្គលដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធមិនមែនកំពុងរលត់ តែសញ្ញាខន្ធនឹងរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធ ក៏មិនមែនកំពុងរលត់ សញ្ញាខន្ធក៏នឹងមិនរលត់។*

**បដិលោមបុច្ឆាៈ** យស្ស វា បន យត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ, តស្ស តត្ថ វេទនាខន្ធោ ន និរុជ្ឈតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនមែនកំពុងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** បរិនិព្វន្តានំ តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈតិ, អសញ្ញសត្តានំ តេសំ តត្ថ សញ្ញាខន្ធោ ច ន និរុជ្ឈិស្សតិ វេទនាខន្ធោ ច ន និរុជ្ឈតិ។ *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ ក្នុងភូមិនោះ សញ្ញាខន្ធ នឹងមិនរលត់ តែវេទនាខន្ធកំពុងរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ,*

*ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ សញ្ញាខន្ធក៏នឹងមិនរលត់ វេទនាខន្ធក៏មិនមែនកំពុងរលត់ៗ*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

**យស្ស យត្ថ វេទនាខន្ធោ ន និរុជ្ឈតិ** *ជាសន្និដ្ឋានបទៗ*

**តស្ស តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ** *ជាសំសយបទៗ*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថាៗលៗ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៦,*

*និង សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ៗ*

*៙ អត្ថធម៌របស់សំសយបទ បានដល់ សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ប៉ុណ្ណោះៗ*

*ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា វេទនាខន្ធមិនមែនកំពុងរលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអដ្ឋកថាទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថាៗលៗ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៦ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈតិ នោ ច តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ** *ហើយទ្រង់លើកយក សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ* មិនមាន

ការបដិសេធសំសយបទ ដូចបានសំដែងថា **អសញ្ញសត្តានំ តេសំ តត្ថ វេទនាខន្ធោ ច ន និរុជ្ឈតិ សញ្ញាខន្ធោ ច ន និរុជ្ឈិស្សតិ,** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្ដដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទៗ

**តស្ស តត្ថ វេទនាខន្ធោ ន និរុជ្ឈតិ** ជាសំសយបទៗ

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថាៗលៗ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វុតដោយត្រង់),

✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថាៗលៗ និង ចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) (អន្តធម៌ដោយអម),

**និង** សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញ-សត្តភូមិ និងអសញ្ញសត្តភូមិ ១ៗ

៙ អន្តធម៌របស់សំសយបទ បានដល់ សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ប៉ុណ្ណោះៗ

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនមែនកំពុងរលត់ដល់បុគ្គលនោះក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថាៗលៗ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វុតដោយត្រង់), បុថុជ្ជន ៤ ផល-សេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថាៗលៗ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) (បរិនិព្វុតដោយអម) ដែលជាអន្តធម៌របស់សន្និដ្ឋានបទបាន តែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ

ដូចបានសំដែងថា **បរិនិព្វន្តានំ តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈតិ** ហើយទ្រង់លើកយក សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ដែលជា អន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមាន ការបដិសេធសំសយបទ ដូចបានសំដែងថា **អសញ្ញសត្តានំ តេសំ តត្ថ សញ្ញាខន្ធោ ច ន និរុជ្ឈិស្សតិ វេទនាខន្ធោ ច ន និរុជ្ឈតិ,** ពាក្យ វិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមាន វិកប្បដោយត្រង់ៗ

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ បុគ្គលោកាសវារៈ)**

## (ចប់ និរោធវារៈ បច្ចុប្បន្នានាគតវារៈ បច្ចនីកៈ)

## បវត្តិវារៈ និរោធវារៈ អតីតានាគតវារៈ អនុលោម បុគ្គលវារៈ

**(វ. និ. ៦(២+៣) នុ. ឈ.)**

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស រូបក្ខន្ធោ និរុជ្ឈិត្ថ, តស្ស វេទនាខន្ធោ និរុជ្ឈិស្សតីតិ? *រូបក្ខន្ធធ្លាប់រលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គល នោះឬ?*

**វិសជ្ជនាៈ** បរិនិព្វន្តានំ តេសំ រូបក្ខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ វេទនាខន្ធោ និរុជ្ឈិស្សតិ, ឥតរេសំ តេសំ រូបក្ខន្ធោ ច

និរុជ្ឈិត្ថ វេទនាខន្ធោ ច និរុជ្ឈិស្សតិ។ ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ រូបក្ខន្ធធ្លាប់រលត់ តែវេទនាខន្ធនឹងមិនរលត់ដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលនៅសល់ក្រៅពីបរិនិព្វុតបុគ្គលនោះ រូបក្ខន្ធក៏ធ្លាប់រលត់ វេទនាខន្ធក៏នឹងរលត់។

**បដិលោមបុច្ឆា:** យស្ស វា បន វេទនាខន្ធោ និរុជ្ឈិស្សតិ, តស្ស រូបក្ខន្ធោ និរុជ្ឈិត្ថាតិ? ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះឬ?

**វិសជ្ជនា:** អាមន្តា មែន។

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស រូបក្ខន្ធោ និរុជ្ឈិត្ថ ជាសន្និដ្ឋានបទ។

តស្ស វេទនាខន្ធោ និរុជ្ឈិស្សតិ ជាសំសយបទ។

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។,

និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអសញ្ញសត្តភូមិ ១)។

៙ អត្ថធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអសញ្ញសត្តភូមិ ១) ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា រូបក្ខន្ធធ្លាប់រលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយកអរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា ។ល។ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **បរិនិព្វន្តានំ តេសំ រូបក្ខន្ធោ និរុជ្ឈិត្ថ**

នោ ច តេសំ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ ១) ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **ឥតរេសំ តេសំ រូបក្ខន្ធោ ច និរុជ្ឈិត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន វេទនាក្ខន្ធោ និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទៗ

**តស្ស រូបក្ខន្ធោ និរុជ្ឈិត្ថ** ជាសំសយបទៗ

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ១)ៗ

៙ អត្ថធម៌របស់សំសយបទ ដូចគ្នាៗ

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចុប្បន្នបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ ១) ដែលជាអត្ថធម៌ របស់សន្និដ្ឋានបទទាំងនោះ រូបក្ខន្ធក៏ធ្លាប់រលត់ផងៗ

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស វេទនាក្ខន្ធោ និរុជ្ឈិត្ថ, តស្ស សញ្ញាក្ខន្ធោ និរុជ្ឈិស្សតីតិ? *វេទនាខន្ធធ្លាប់រលត់ដល់បុគ្គលណា, សញ្ញាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** បរិនិព្វន្តានំ តេសំ វេទនាក្ខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ, ឥតរេសំ តេសំ វេទនាក្ខន្ធោ ច និរុជ្ឈិត្ថ សញ្ញាក្ខន្ធោ ច និរុជ្ឈិស្សតិ។ *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ វេទនាខន្ធធ្លាប់រលត់ តែសញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលនៅសល់ក្រៅពីបរិនិព្វន្តបុគ្គលនោះ វេទនាខន្ធក៏ធ្លាប់រលត់ សញ្ញាខន្ធក៏នឹងរលត់។*

**បដិលោមបុច្ឆាៈ** យស្ស វា បន សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ, តស្ស វេទនាក្ខន្ធោ និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ដល់បុគ្គលណា, វេទនាខន្ធ ក៏ធ្លាប់រលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស វេទនាក្ខន្ធោ និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទ។*

*១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។*

និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ ១)។

៙ អង្គធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ១) ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា វេទនាខន្ធធ្លាប់រលត់ដល់បុគ្គលណា, សញ្ញាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **បរិនិព្វន្តានំ តេសំ វេទនាខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ សញ្ញាខន្ធោ និរុជ្ឈិស្សតិ** ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ(វៀរអកនិដ្ឋកភូមិ ១) ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **ឥតរេសំ តេសំ វេទនាខន្ធោ ច និរុជ្ឈិត្ថ សញ្ញាខន្ធោ ច និរុជ្ឈិស្សតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆា នេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិភង្គដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន សញ្ញាខន្ធោ និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស វេទនាខន្ធោ និរុជ្ឈិត្ថ** ជាសំសយបទ។

៙ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ ១)។

៙ អង្គធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុង ៣១ ភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង ៣០ ភូមិ (វៀរអកនិដ្ឋកភូមិ ១) ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏ធ្លាប់រលត់ផង។

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលវារៈ)**

## បវត្តិវារៈ និរោធវារៈ អតីតានាគតវារៈ អនុលោម ឱកាសវារៈ

**(រំ.និ. ៦(២+៣) នុ. ឱ.)**

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា:** យត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ, តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតីតិ? *រូបក្ខន្ធធ្លាប់រលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** អសញ្ញសត្តេ តត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ នោ ច តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, បញ្ចវោការេ តត្ថ រូបក្ខន្ធោ ច និរុជ្ឈិត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ។ *ក្នុងអសញ្ញសត្តភូមិនោះ រូបក្ខន្ធធ្លាប់រលត់ តែវេទនាខន្ធនឹងមិនរលត់ក្នុងភូមិនោះ, ក្នុងបញ្ចវោការភូមិនោះ រូបក្ខន្ធក៏ធ្លាប់រលត់ វេទនាខន្ធក៏នឹងរលត់។*

**បដិលោមបុច្ឆា:** យត្ថ វា បន វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, តត្ថ

រូបក្ខន្ធោ និរុជ្ឈិត្ថាតិ? ម្យ៉ាងទៀត វេទនាខន្ធ នឹងរលត់ក្នុងភូមិណា, រូបក្ខន្ធក៏ធ្លាប់រលត់ក្នុងភូមិនោះឬ?

**វិសជ្ជនា:** អរូបេ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ, បញ្ចវោការេ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈិត្ថ។ ក្នុងអរូបភូមិនោះ វេទនាខន្ធនឹងរលត់ តែរូបក្ខន្ធមិនធ្លាប់រលត់ក្នុងភូមិនោះ, ក្នុងបញ្ចវោការភូមិនោះ វេទនាខន្ធក៏នឹងរលត់ រូបក្ខន្ធក៏ធ្លាប់រលត់។

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាស:

## ក្នុងអនុលោមបុច្ឆា

យត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ ជាសន្និដ្ឋានបទ។

តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ ជាសំសយបទ។

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង,

និង បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។

៙ អត្ថធម៌របស់សំសយបទ បានដល់ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា រូបក្ខន្ធធ្លាប់រលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាស: មានការបដិសេធសំសយបទ ដូចបានសំដែងថា **អសញ្ញសត្តេ តត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ នោ ច តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ** ហើយទ្រង់លើកយក បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាស: មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការេ តត្ថ រូបក្ខន្ធោ**

ច និរុជ្ឈិត្ថ វេទនាខន្ធោ ច និរុជ្ឈិស្សតិ ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្ប៍ដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

យត្ថ វា បន វេទនាខន្ធោ និរុជ្ឈិស្សតិ ជាសន្និដ្ឋានបទៗ

តត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ ជាសំសយបទៗ

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤, និង បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ៗ

៙ អត្ថធម៌របស់សំសយបទ បានដល់ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ប៉ុណ្ណោះៗ

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ក្នុងភូមិណា, រូបក្ខន្ធក៏ធ្លាប់រលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា អរូបេ តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតិ នោ ច តត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ ហើយទ្រង់លើកយក បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា បញ្ចវោការេ តត្ថ វេទនាខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈិត្ថ ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្ប៍ដោយត្រង់ៗ

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលះ)**

# ខ. ទេសនាខន្ធមូល:

## ១. វេទនាខន្ធមូល: សញ្ញាខន្ធមូលីយមក:

**អនុលោមបុច្ឆា:** យត្ថ វេទនាខន្ធោ និរុជ្ឈិត្ថ, តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតីតិ? *វេទនាខន្ធធ្លាប់រលត់ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** អាមន្តា *មែន។*

**បដិលោមបុច្ឆា:** យត្ថ វា បន សញ្ញាខន្ធោ និរុជ្ឈិស្សតិ, តត្ថ វេទនាខន្ធោ និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ក្នុងភូមិណា, វេទនាខន្ធក៏ធ្លាប់រលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** អាមន្តា *មែន។*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាស:

### ក្នុងអនុលោមបុច្ឆា

យត្ថ វេទនាខន្ធោ និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*៙ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចុប្បញ្ញា សួរថា វេទនាខន្ធធ្លាប់រលត់ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏នឹងរលត់ផង។*

## ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ** *ជាសន្និដ្ឋានបទ។*

**តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ** *ជាសំសយបទ។*

*◉ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*◉ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ក្នុងភូមិណា, វេទនាខន្ធក៏ធ្លាប់រលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ* **បដិវចនវិសជ្ជនាថា អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏ធ្លាប់រលត់ផង។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ ឱកាសវារៈ)**

---

### បវត្តិវារៈ និរោធវារៈ អតីតានាគតវារៈ អនុលោម បុគ្គលោកាសវារៈ

### (វ. និ. ៦(២+៣) នុ. លោ.)

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ, តស្ស តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតីតិ? *រូបក្ខន្ធធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** បញ្ចវោការេ បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, ឥតរេសំ បញ្ចវោការានំ តេសំ តត្ថ រូបក្ខន្ធោ ច និរុជ្ឈិត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ។ *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ និង ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធធ្លាប់រលត់ តែវេទនាខន្ធ នឹងមិនរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងបញ្ចវោការភូមិ ដែលក្រៅពីបរិនិព្វុតបុគ្គលនោះ ក្នុងភូមិនោះ រូបក្ខន្ធក៏ធ្លាប់រលត់ វេទនាខន្ធក៏នឹងរលត់។*

**បដិលោមបុច្ឆា:** យស្ស វា បន យត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ, តស្ស តត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** សុទ្ធាវាសំ ឧបបជ្ជន្តានំ អរូបានំ តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ, ឥតរេសំ បញ្ចវោការានំ តេសំ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈិត្ថ។ *ពួកបុគ្គលដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ និង ពួកបុគ្គលដែលកើតនៅក្នុងអរូបភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធនឹងរលត់ តែរូបក្ខន្ធមិនធ្លាប់រលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងបញ្ចវោការភូមិ ដែលក្រៅពីសុទ្ធាវាសភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធក៏នឹងរលត់ រូបក្ខន្ធក៏ធ្លាប់រលត់។*

## ការសំដែងអគ្គធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទ។*

*៙ អគ្គធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន*

ក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។ និងបញ្ចវោការភូមិ ១៧ (វៀរសុទ្ធាវាសភូមិ ៥, អបាយភូមិ ៤) (បរិនិព្វានដោយត្រង់),

✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២១(វៀរសុទ្ធាវាសភូមិ ៥) (បរិនិព្វានដោយអម),

សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១,

**និង** បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។

◉ អត្ថធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា រូបក្ខន្ធដាច់រលត់ដល់បុគ្គលណាក្នុងភូមិណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយកអរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។ បញ្ចវោការភូមិ ១៧ (វៀរសុទ្ធាវាសភូមិ ៥, អបាយភូមិ ៤) (បរិនិព្វានដោយត្រង់), បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ បញ្ចវោការភូមិ ២១(វៀរសុទ្ធាវាសភូមិ ៥) (បរិនិព្វានដោយអម), សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុង អសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការេ បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈតិ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ**, ហើយទ្រង់

លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និង បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបាន សំដែងថា **ឥតរេសំ បញ្ចវោការានំ តេសំ តត្ថ រូបក្ខន្ធោ ច និរុជ្ឈិត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិស្សតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភត្តដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ វេទនាក្ខន្ធោ និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ** ជាសំសយបទ។

◉ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា ។លៗ សុទ្ធាវាសភូមិ ៥, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែល កំពុងកើតក្នុងអរូបភូមិ, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងអរូបភូមិ ៤,

**និង** បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)។

◉ អន្តធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះ

*អគ្គទ្រង់សំដែងដោយការលើកយក អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងអរូបភូមិ ៤ ដែលជាអគ្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **សុទ្ធាវាសំ ឧបបជ្ជន្តានំ អរូបានំ តេសំ តត្ថ វេទនាខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ និរុជ្ឈិត្ថ,** *ហើយទ្រង់លើកយកបុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអគ្គធម៌របស់ សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធ សំសយបទ ដូចបានសំដែងថា* **ឥតរេសំ បញ្ចវោការានំ តេសំ តត្ថ វេទនាខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច និរុជ្ឈិត្ថ** *ពាក្យវិសជ្ជនាក្នុង បដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** **យស្ស យត្ថ វេទនាខន្ធោ និរុជ្ឈិត្ថ, តស្ស តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតីតិ?** *វេទនាខន្ធធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** បរិនិព្វន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ តត្ថ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ, ឥតរេសំ ចតុវោការានំ បញ្ចវោការានំ តេសំ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិត្ថ សញ្ញាក្ខន្ធោ ច និរុជ្ឈិស្សតិ។ *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធធ្លាប់រលត់ តែសញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលក្រៅពីបរិនិព្វុតបុគ្គលនោះ ក្នុងភូមិនោះ វេទនាខន្ធក៏ធ្លាប់រលត់ សញ្ញាខន្ធក៏នឹងរលត់។*

**បដិលោមបុច្ឆា:** យស្ស វា បន យត្ថ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ, តស្ស តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** សុទ្ធាវាសំ ឧបបជ្ជន្តានំ តេសំ តត្ថ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ, ឥតរេសំ ចតុវោការានំ បញ្ចវោការានំ តេសំ តត្ថ សញ្ញាក្ខន្ធោ ច និរុជ្ឈិស្សតិ វេទនាក្ខន្ធោ ច និរុជ្ឈិត្ថ។ *ពួកបុគ្គលដែលកំពុងកើតក្នុងសុទ្ធាវាសភូមិនោះ ក្នុងភូមិនោះ សញ្ញាខន្ធនឹងរលត់ តែវេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកើតនៅក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលក្រៅពីសុទ្ធាវាសភូមិនោះ ក្នុងភូមិនោះ សញ្ញាខន្ធក៏នឹងរលត់ វេទនាខន្ធក៏ធ្លាប់រលត់។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស តត្ថ សញ្ញាក្ខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន*

ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ១៧ (វៀរសុទ្ធាវាសភូមិ ៥, អបាយភូមិ ៤) (បរិនិព្វន្តដោយត្រង់) ,

✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) (បរិនិព្វន្តដោយអម),

និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥),

៙ អង្គធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា វេទនាខន្ធធ្លាប់រលត់ដល់បុគ្គលណាក្នុងភូមិណា, សញ្ញាខន្ធក៏នឹងរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ១៧ (វៀរសុទ្ធាវាសភូមិ ៥, អបាយភូមិ ៤) (បរិនិព្វន្តដោយត្រង់), បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) (បរិនិព្វន្តដោយអម) ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាងទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **បរិនិព្វន្តានំ តេសំ តត្ថ វេទនាខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ** ហើយទ្រង់លើកយកបុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុង

ចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និង ចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអត្ថធម៌របស់ សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធ សំសយបទ ដូច បានសំដែងថា **ឥតរេសំ ចតុវោការានំ បញ្ចវោការានំ តេសំ តត្ថ វេទនាខន្ធោ ច និរុជ្ឈិត្ថ សញ្ញាខន្ធោ ច និរុជ្ឈិស្សតិ** ពាក្យវិសជ្ជនា ក្នុងអនុលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្ប ដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ វេទនាខន្ធោ និរុជ្ឈិត្ថ** ជាសំសយបទ។

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុង សុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥,

និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយ នឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរ សុទ្ធាវាសភូមិ ៥)។

៙ អត្ថធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែល កំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែល កំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងរលត់ ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុង សុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ

*បានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **សុទ្ធាវាសំ ឧបបជ្ជន្តានំ តេសំ តត្ថ សញ្ញាខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ វេទនាខន្ធោ និរុជ្ឈិត្ថ** *ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ, បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុង បច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **ឥតរេសំ ចតុវោការានំ បញ្ចវោការានំ តេសំ តត្ថ សញ្ញាខន្ធោ ច និរុជ្ឈិស្សតិ វេទនាខន្ធោ ច និរុជ្ឈិត្ថ** *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បជោយត្រង់ៗ*

**(មូលី មូលៈ ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលោកាសវារៈ)**

## (ចប់ និរោធវារៈ អតីតានាគតវារៈ អនុលោម)

# បវត្តិវារៈ និរោធវារៈ អតីតានាគតវារៈ បច្ចនីកៈ បុគ្គលវារៈ

**(វ. និ. ៦(២+៣) ច. ឈ.)**

## ក. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស រូបក្ខន្ធោ ន និរុជ្ឈិត្ថ, តស្ស វេទនាខន្ធោ ន និរុជ្ឈិស្សតីតិ? *រូបក្ខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, វេទនាខន្ធ*

*ក៏នឹងមិនរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** នត្ថិ *មិនមាន។*

**បដិលោមបុច្ឆា:** យស្ស វា បន វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ, តស្ស រូបក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** និរុជ្ឈិត្ថ *ធ្លាប់រលត់។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស រូបក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ មិនមាន កាលបើអត្ថធម៌របស់សន្និដ្ឋានបទមិនមានហើយ អត្ថធម៌របស់សំសយបទ ក៏មិនមានដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជា**មោឃបញ្ហា** សួរថា រូបក្ខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, វេទនាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិក្ខេបវិសជ្ជនា**ថា* **នត្ថិ** *ដែលជាពាក្យវិសជ្ជនាហាមអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា ពួកបុគ្គលដែលរូបក្ខន្ធមិនធ្លាប់រលត់ក្នុងភពផ្សេងៗនោះមិនមាន មានតែពួកបុគ្គលដែលរូបក្ខន្ធធ្លាប់រលត់មកហើយ ទាំងអស់។*

## ក្នុងបដិលោមបុច្ឆា

យស្ស វា បន វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ *ជាសន្និដ្ឋានបទ។*

តស្ស រូបក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។*

*៙ អត្ថធម៌របស់សំសយបទ មិនមាន*

*ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបាឡិគតិវិសជ្ជនាថា* និរុជ្ឈិត្ថ *ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីវេទនាខន្ធនឹងមិនរលត់ តែរូបក្ខន្ធធ្លាប់រលត់។*

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលះ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយចកៈ

**អនុលោមបុច្ឆា:** យស្ស វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ, តស្ស សញ្ញាក្ខន្ធោ ន និរុជ្ឈិស្សតីតិ? *វេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, សញ្ញាខន្ធ ក៏នឹងមិនរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** នត្ថិ *មិនមាន។*

**បដិលោមបុច្ឆា:** យស្ស វា បន សញ្ញាក្ខន្ធោ ន និរុជ្ឈិស្សតិ, តស្ស វេទនាក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** និរុជ្ឈិត្ថ *ធ្លាប់រលត់។*

## ការសំដែងអង្គធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស សញ្ញាក្ខន្ធោ ន និរុជ្ឈិស្សតិ *ជាសំសយបទ។*

៙ អន្តធម៌របស់សន្និដ្ឋានបទ មិនមាន កាលបើអន្តធម៌របស់សន្និដ្ឋានបទ មិនមានហើយ អន្តធម៌របស់សំសយបទ ក៏មិនមានដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាមោឃបញ្ហា សួរថា វេទនាខន្ធមិនធ្លាប់រលត់ ដល់បុគ្គលណា, សញ្ញាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ **បដិក្ខេបវិសជ្ជនាថា នត្ថិ** ដែលជាពាក្យវិសជ្ជនាហាមអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា ពួកបុគ្គលដែលវេទនាខន្ធមិនធ្លាប់រលត់ក្នុងភពផ្សេងៗនោះ មិនមាន មានតែពួកបុគ្គលដែលវេទនាខន្ធធ្លាប់រលត់មកហើយទាំងអស់។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស វេទនាខន្ធោ ន និរុជ្ឈិត្ថ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។

៙ អន្តធម៌របស់សំសយបទ មិនមាន។

ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បាឡិគតិវិសជ្ជនាថា និរុជ្ឈិត្ថ** ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីសញ្ញាខន្ធនឹងមិនរលត់ តែវេទនាខន្ធធ្លាប់រលត់។

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ បុគ្គលវារៈ)**

# បវត្តិវារៈ និរោធវារៈ អតីតានាគតវារៈ បច្ចនីកៈ ឱកាសវារៈ

## (វ. និ. ៦(២+៣) ច. ឱ.)

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាក្ខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ, តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតីតិ? *រូបក្ខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងមិនរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** និរុជ្ឈិស្សតិ *នឹងរលត់ៗ*

**បដិលោមបុច្ឆាៈ** យត្ថ វា បន វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ, តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ក្នុងភូមិណា, រូបក្ខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** និរុជ្ឈិត្ថ *ធ្លាប់រលត់ៗ*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

### ក្នុងអនុលោមបុច្ឆា

យត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទៗ*

តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ *ជាសំសយបទៗ*

*◉ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ៗ*

*◉ អត្ថធម៌របស់សំសយបទ មិនមានៗ*

*ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា រូបក្ខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, វេទនាខន្ធក៏នឹងមិនរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបាឡិគតិវិសជ្ជនាថា* **និរុជ្ឈិស្សតិ** *ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អរូបភូមិ ៤ ដែល*

ជាទីកើតនៃនាមក្ខន្ធ ៤ ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីរូបក្ខន្ធមិនធ្លាប់រលត់ តែវេទនាខន្ធនឹងរលត់ ។

## ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន វេទនាខន្ធោ ន និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ ។

**តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ** ជាសំសយបទ ។

៙ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ។

៙ អង្គធម៌របស់សំសយបទ មិនមាន ។

ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ក្នុងភូមិណា, រូបក្ខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបាឡិគតិវិសជ្ជនាថា **និរុជ្ឈិត្ថ** ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីវេទនាខន្ធនឹងមិនរលត់ តែរូបក្ខន្ធធ្លាប់រលត់ ។

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ, តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតីតិ? *វេទនាខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, សញ្ញាខន្ធ ក៏នឹងមិនរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន ។*

**បដិលោមបុច្ឆា៖** យត្ថ វា បន សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ, តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា៖** អាមន្តា *មែន។*

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសះ

## ក្នុងអនុលោមបុច្ឆា

យត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ *ជាសំសយបទ។*

*๏ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។*

*๏ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា វេទនាខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងមិនរលត់ក្នុងភូមិនោះឬ?*

*ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* អាមន្តា *ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏នឹងមិនរលត់ផង។*

## ក្នុងបដិលោមបុច្ឆា

យត្ថ វា បន សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ *ជាសន្និដ្ឋានបទ។*

តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ *ជាសំសយបទ។*

*๏ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។*

*๏ អន្តធម៌របស់សំសយបទ ដូចគ្នា។*

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏មិនធ្លាប់រលត់ផងៗ

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ និកាសវារៈ)**

## បវត្តិវារៈ និរោធវារៈ អតីតានាគតវារៈ បច្ចនីកៈ បុគ្គលោកាសវារៈ

**(វ. និ. ៦(២+៣) ច. លោ.)**

## ក. រូបក្ខន្ធមូល

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ, តស្ស តត្ថ វេទនាខន្ធោ ន និរុជ្ឈិស្សតីតិ? *រូបក្ខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** សុទ្ធាវាសំ ឧបបជ្ជន្តានំ អរូបានំ តេសំ តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈិស្សតិ, សុទ្ធាវាសេ បរិនិព្វន្តានំ អរូបេ បរិនិព្វន្តានំ តេសំ តត្ថ រូបក្ខន្ធោ ច ន និរុជ្ឈិត្ថ វេទនាខន្ធោ ច ន និរុជ្ឈិស្សតិ។ *ពួកបុគ្គលដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ និង ពួកបុគ្គលដែលកើតនៅក្នុងអរូបភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធមិនធ្លាប់រលត់ តែវេទនាខន្ធនឹងរលត់ដល់បុគ្គលពួកនោះ*

*ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ អរូបភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធ ក៏មិនជាប់រលត់ វេទនាខន្ធ ក៏នឹងមិនរលត់ៗ*

**បដិលោមបុច្ឆា:** យស្ស វា បន យត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ, តស្ស តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏មិនជាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** បញ្ចវោការេ បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ, សុទ្ធាវាសេ បរិនិព្វន្តានំ អរូបេ បរិនិព្វន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ច ន និរុជ្ឈិស្សតិ រូបក្ខន្ធោ ច ន និរុជ្ឈិត្ថ។ *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងបញ្ចវោការភូមិ និង ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធនឹងមិនរលត់ តែរូបក្ខន្ធជាប់រលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ អរូបភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធក៏នឹង មិនរលត់ រូបក្ខន្ធក៏មិនជាប់រលត់ៗ*

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទៗ*

តស្ស តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ *ជាសំសយបទៗ*

*๑ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថាៗលៗ និងសុទ្ធាវាសភូមិ ៥,*

*តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងស្លាប់ក្នុងភូមិដែល ខ្លួនកើតនៅទៀត និងអរូបភូមិ ៤,*

និង អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និង សុទ្ធាវាសភូមិ ៥,

អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា។ល។ និង អរូបភូមិ ៤ (បរិនិព្វុទ្ធដោយត្រង់),

✳ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយ នឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងអរូបភូមិ ៤ (បរិនិព្វុទ្ធ ដោយអម)។

๑ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងសុទ្ធាវាសភូមិ, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរ អកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥,

អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា។ល។ និងអរូបភូមិ ៤ (បរិនិព្វុទ្ធដោយត្រង់),

✳ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយ នឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងអរូបភូមិ ៤ (បរិនិព្វុទ្ធ ដោយអម) ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា រូបក្ខន្ធមិនធ្លាប់រលត់ដល់ បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើប ព្រះអង្គទ្រង់សំដែងដោយការលើកយក អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវា-សភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុង ស្លាប់ក្នុងអរូបភូមិ ហើយនឹងស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត និងអរូបភូមិ ៤ ដែលជា អន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធ សំសយបទ ដូចបានសំដែងថា **សុទ្ធាវាសំ ឧបបជ្ជន្តានំ អរូបានំ តេសំ តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ ន**

និរុជ្ឈិស្សតិ, ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា ។ល។ និងសុទ្ធាវាសភូមិ ៥, អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា។ល។ និងអរូបភូមិ ៤ (បរិនិព្វុត្ត - ដោយត្រង់), តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងអរូបភូមិ ៤ (បរិនិព្វុត្តដោយអម) ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធ សំសយបទ ដូចបានសំដែងថា **សុទ្ធាវាសេ បរិនិព្វន្តានំ អរូបេ បរិនិព្វន្តានំ តេសំ តត្ថ រូបក្ខន្ធោ ច ន និរុជ្ឈិត្ថ វេទនាក្ខន្ធោ ច ន និរុជ្ឈិស្សតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ** ជាសំសយបទ។

៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។ និងបញ្ចវោការភូមិ ១៧ (វៀរសុទ្ធាវាសភូមិ៥, អបាយភូមិ ៤) (បរិនិព្វុត្តដោយត្រង់),

✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ហើយនឹង មិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២១(វៀរ សុទ្ធាវាសភូមិ ៥) (បរិនិព្វុត្តដោយអម),

សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១,

និង អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និង សុទ្ធាវាសភូមិ ៥,

អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា។ល។ និង អរូបភូមិ ៤ (បរិនិព្វានដោយត្រង់),

✳ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយ នឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងអរូបភូមិ ៤ (បរិនិព្វាន ដោយអម)។

៙ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងសុទ្ធាវាសភូមិ, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរ អកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥,

អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា។ល។ និង អរូបភូមិ ៤ (បរិនិព្វានដោយត្រង់),

✳ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយ នឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងអរូបភូមិ ៤(បរិនិព្វាន ដោយអម) ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងមិន រលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។ និងបញ្ចវោការភូមិ ១៧(វៀរសុទ្ធាវាសភូមិ ៥, អបាយភូមិ ៤) (បរិនិព្វានដោយត្រង់), បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ ក្នុងបញ្ចវោការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២១(វៀរសុទ្ធាវាសភូមិ ៥)(បរិនិព្វានដោយអម), សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ បានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា

បញ្ចវោការេ បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ ន និរុជ្ឈិត្ថ *ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥ , អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងអរូបភូមិ ដែលហៅថា។ល។ និងអរូបភូមិ ៤(បរិនិព្វានដោយត្រង់), តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងអរូបភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងអរូបភូមិ ៤ (បរិនិព្វានដោយអម) ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* សុទ្ធាវាសេ បរិនិព្វន្តានំ អរូបេ បរិនិព្វន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ច ន និរុជ្ឈិស្សតិ រូបក្ខន្ធោ ច ន និរុជ្ឈិត្ថ *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។*

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ, តស្ស តត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិស្សតីតិ? *វេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** សុទ្ធាវាសំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិស្សតិ, សុទ្ធាវាសេ បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ច

ន និរុជ្ឈិត្ថ សញ្ញាខន្ធោ ច ន និរុជ្ឈិស្សតិ។ *ពួកបុគ្គលដែលកំពុងកើតក្នុងសុទ្ធាវាសភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធមិនធ្លាប់រលត់ តែសញ្ញាខន្ធ នឹងរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និងពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធក៏មិនធ្លាប់រលត់ សញ្ញាខន្ធក៏នឹងមិនរលត់។*

**បដិលោមបុច្ឆា:** យស្ស វា បន យត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ, តស្ស តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថាតិ? *ម្យ៉ាងទៀត សញ្ញាខន្ធ នឹងមិនរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** បរិនិព្វន្តានំ តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ, សុទ្ធាវាសេ បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ សញ្ញាខន្ធោ ច ន និរុជ្ឈិស្សតិ វេទនាខន្ធោ ច ន និរុជ្ឈិត្ថ។ *ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ ក្នុងភូមិនោះ សញ្ញាខន្ធនឹងមិនរលត់ តែវេទនាខន្ធធ្លាប់រលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និង ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ សញ្ញាខន្ធក៏នឹងមិនរលត់ វេទនាខន្ធក៏មិនធ្លាប់រលត់។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ *ជាសំសយបទ។*

*១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥,*

និង អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១។

៙ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា វេទនាខន្ធ មិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអដ្ឋកថាទ្រង់សំដែងដោយការលើកយក អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ** ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសេ បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ វេទនាខន្ធោ ច ន និរុជ្ឈិត្ថ សញ្ញាខន្ធោ ច ន និរុជ្ឈិស្សតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិគ្គហដោយត្រង់។

# ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ** ជាសំសយបទ។

๑ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ១៧ (វៀរសុទ្ធាវាសភូមិ ៥, អបាយភូមិ ៤) (បរិនិព្វុតដោយត្រង់),

✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោ-ការភូមិ ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុ-វោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) (បរិនិព្វុតដោយអម)។

និង អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា ។ល។ និងសុទ្ធាវាសភូមិ ៥,

សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១។

๑ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥,

សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ១៧ (វៀរសុទ្ធាវាសភូមិ ៥, អបាយភូមិ ៤) (បរិនិព្វុតដោយត្រង់), បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ

*ហើយនឹងមិនស្លាប់ក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) (បរិនិព្វានដោយអម) ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធ សំសយបទដូចបានសំដែងថា* **បរិនិព្វន្តានំ តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ** *ហើយទ្រង់លើកយកអរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និងសំសយបទបានទាំង ២ ទុក ក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទដូចបានសំដែងថា* **សុទ្ធាវាសេ បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ សញ្ញាខន្ធោ ច ន និរុជ្ឈិស្សតិ វេទនាខន្ធោ ច ន និរុជ្ឈិត្ថ**

*ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ*

*ជាសរូបទស្សនវិសជ្ជនា ដែលមានវិភង្គដោយត្រង់។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលោកាសវារៈ)**

## (ចប់ និរោធវារៈ អតីតានាគតវារៈ បច្ចនីកៈ)

# បវត្តិវារៈ ឧប្បាទនិរោធវារៈ បច្ចុប្បន្នវារៈ អនុលោម បុគ្គលវារៈ

**(វ. ឧនិ. ១ នុ. ឈ.)**

## ក. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយចកៈ

**អនុលោមបុច្ឆា:** យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស វេទនាក្ខន្ធោ និរុជ្ឈតីតិ? *រូបក្ខន្ធកំពុងកើតដល់បុគ្គលណា, វេទនាខន្ធក៏កំពុងរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** នោ *មិនមែនទេ។*

**បដិលោមបុច្ឆា:** យស្ស វា បន វេទនាក្ខន្ធោ និរុជ្ឈតិ, តស្ស រូបក្ខន្ធោ ឧប្បជ្ជតីតិ? *មួយវិញទៀត វេទនាខន្ធកំពុងរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏កំពុងកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** នោ *មិនមែនទេ។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ *ជាសន្និដ្ឋានបទ។*

តស្ស វេទនាក្ខន្ធោ និរុជ្ឈតិ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។*

*៙ អត្ថធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជា*មោឃបញ្ហា *សួរថា រូបក្ខន្ធកំពុងកើតដល់បុគ្គលណា, វេទនាខន្ធក៏កំពុងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធ-វិសជ្ជនាថា នោ ដែលជាពាក្យវិសជ្ជនា បដិសេធអត្ថធម៌របស់សំសយបទ ព្រោះថា*

*បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីរូបក្ខន្ធកំពុងកើត តែវេទនាខន្ធមិនមែនកំពុងរលត់។*

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន វេទនាក្ខន្ធោ និរុជ្ឈតិ** *ជាសន្និដ្ឋានបទ។*

**តស្ស រូបក្ខន្ធោ ឧប្បជ្ជតិ** *ជាសំសយបទ។*

*๏ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។*

*๏ អត្ថធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជាមោឃបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធកំពុងរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏កំពុងកើតដល់បុគ្គលនោះឬ? ទើបព្រះអដ្ឋកថាទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា* **នោ** *ដែលជាពាក្យវិសជ្ជនា បដិសេធអត្ថធម៌របស់សំសយបទ ព្រោះថា បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីវេទនាខន្ធកំពុងរលត់ តែរូបក្ខន្ធមិនមែនកំពុងកើត។*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលះ)**

## ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស វេទនាក្ខន្ធោ ឧប្បជ្ជតិ, តស្ស សញ្ញាក្ខន្ធោ និរុជ្ឈតីតិ? *វេទនាខន្ធកំពុងកើតដល់បុគ្គលណា, សញ្ញាខន្ធក៏កំពុងរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា៖** នោ *មិនមែនទេ។*

**បដិលោមបុច្ឆា៖** យស្ស វា បន សញ្ញាខន្ធោ និរុជ្ឈតិ, តស្ស វេទនាខន្ធោ ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធកំពុងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏កំពុងកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនា៖** នោ *មិនមែនទេ។*

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស វេទនាខន្ធោ ឧប្បជ្ជតិ *ជាសន្និដ្ឋានបទ។*

តស្ស សញ្ញាខន្ធោ និរុជ្ឈតិ *ជាសំសយបទ។*

*๏ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។*

*๏ អន្តធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជា***មោឃបញ្ហា** *សួរថា វេទនាខន្ធកំពុងកើតដល់បុគ្គលណា, សញ្ញាខន្ធក៏កំពុងរលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ***បដិសេធ-វិសជ្ជនា***ថា* នោ *ដែលជាពាក្យវិសជ្ជនា បដិសេធអន្តធម៌របស់សំសយបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា ។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីវេទនាខន្ធកំពុងកើត តែសញ្ញាខន្ធមិនមែនកំពុងរលត់។*

## ក្នុងបដិលោមបុច្ឆា

យស្ស វា បន សញ្ញាខន្ធោ និរុជ្ឈតិ *ជាសន្និដ្ឋានបទ។*

តស្ស វេទនាខន្ធោ ឧប្បជ្ជតិ *ជាសំសយបទ។*

*๏ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។*

*១ អន្តធម៌របស់សំសយបទ មិនមានៗ*

*ដូច្នេះ ពាក្យសួរបទនេះ ជាមោឃបញ្ហា សួរថា មួយវិញទៀត សញ្ញាខន្ធកំពុងរលត់ដល់បុគ្គលណា, វេទនាខន្ធក៏កំពុងកើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា* នោ *ដែលជាពាក្យវិសជ្ជនា បដិសេធអន្តធម៌របស់សំសយបទ ព្រោះថា បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថាៗលៗ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ, សូម្បីសញ្ញាខន្ធកំពុងរលត់ តែវេទនាខន្ធមិនមែនកំពុងកើតៗ*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលវារៈ)**

## បវត្តិវារៈ ឧប្បាទនិរោធវារៈ បច្ចុប្បន្នវារៈ អនុលោម ឱកាសវារៈ

**(វំ. ឧនិ. ១ នុ. ឱ.)**

## ក. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា** យត្ថ *រូបក្ខន្ធោ* ឧប្បជ្ជតិ, តត្ថ វេទនាក្ខន្ធោ និរុជ្ឈតីតិ? *រូបក្ខន្ធកំពុងកើតក្នុងភូមិណា, វេទនាខន្ធក៏កំពុងរលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា** *អសញ្ញសត្តេ* តត្ថ *រូបក្ខន្ធោ* ឧប្បជ្ជតិ នោ ច តត្ថ វេទនាក្ខន្ធោ និរុជ្ឈតិ, បញ្ចវោការេ តត្ថ *រូបក្ខន្ធោ* ច ឧប្បជ្ជតិ វេទនាក្ខន្ធោ ច និរុជ្ឈតិៗ *ក្នុងអសញ្ញសត្តភូមិនោះ រូបក្ខន្ធកំពុងកើត តែ*

*វេទនាខន្ធមិនមែនកំពុងរលត់ក្នុងភូមិនោះ, ក្នុងបញ្ចវោការភូមិនោះ រូបក្ខន្ធក៏កំពុងកើត វេទនាខន្ធក៏កំពុងរលត់ ។*

**បដិលោមបុច្ឆា:** យត្ថ វា បន វេទនាក្ខន្ធោ និរុជ្ឈតិ, តត្ថ រូបក្ខន្ធោ ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត វេទនាខន្ធកំពុងរលត់ក្នុងភូមិណា, រូបក្ខន្ធក៏កំពុងកើតក្នុងភូមិនោះឬ?*

**វិសជ្ជនា:** អរូបេ តត្ថ វេទនាក្ខន្ធោ និរុជ្ឈតិ នោ ច តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ, បញ្ចវោការេ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈតិ រូបក្ខន្ធោ ច ឧប្បជ្ជតិ។ *ក្នុងអរូបភូមិនោះ វេទនាខន្ធកំពុងរលត់ តែរូបក្ខន្ធមិនមែនកំពុងកើតក្នុងភូមិនោះ, ក្នុងបញ្ចវោការភូមិនោះ វេទនាខន្ធក៏កំពុងរលត់ រូបក្ខន្ធក៏កំពុងកើត ។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ *ជាសន្និដ្ឋានបទ ។*

តត្ថ វេទនាក្ខន្ធោ និរុជ្ឈតិ *ជាសំសយបទ ។*

*◉ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង និង បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ។*

*◉ អត្ថធម៌របស់សំសយបទ បានដល់ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ប៉ុណ្ណោះ ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា***បរិបុណ្ណបញ្ហា** *សួរថា រូបក្ខន្ធកំពុងកើតក្នុងភូមិណា, វេទនាខន្ធក៏កំពុងរលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ*

បានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អសញ្ញសត្តេ តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ នោ ច តត្ថ វេទនាក្ខន្ធោ និរុជ្ឈតិ** ហើយទ្រង់លើកយក បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការេ តត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ វេទនាក្ខន្ធោ ច និរុជ្ឈតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន វេទនាក្ខន្ធោ និរុជ្ឈតិ** ជាសន្និដ្ឋានបទ។

**តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ** ជាសំសយបទ។

៙ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោ-ការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វុត្តដោយត្រង់), បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនកើតក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) (បរិនិព្វុត្តដោយអម), សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ហើយនឹងមិនកើតក្នុងអសញ្ញសត្តភូមិទៀត និងអសញ្ញសត្តភូមិ ១ ប៉ុណ្ណោះ (បរិនិព្វុត្តដោយអម)។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធនឹងមិនរលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏នឹងមិនកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ហើយនឹងកើតក្នុងអសញ្ញសត្តភូមិទៀត និងអស-ញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អសញ្ញសត្តានំ តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈិស្សតិ នោ ច តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជិស្សតិ** ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វុត្តដោយត្រង់), បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែល

*កំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនកើតក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា ។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) (បរិនិព្វានដោយអម), សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ហើយនឹងមិនកើតក្នុងអសញ្ញសត្តភូមិទៀត និងអសញ្ញសត្តភូមិ ១ (បរិនិព្វានដោយអម) ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាស: មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* បរិនិព្វន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ច ន និរុជ្ឈិស្សតិ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ*

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលះ)**

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ, តស្ស តត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិស្សតីតិ? *វេទនាខន្ធនឹងមិនកើតដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** បច្ឆិមភវិកានំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ នោ ច តេសំ តត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិស្សតិ, បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ច ឧប្បជ្ជិស្សតិ សញ្ញាក្ខន្ធោ ច ន និរុជ្ឈិស្សតិ។ *ពួកបច្ឆិមភវិកបុគ្គលដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធនឹងមិនកើត តែសញ្ញាខន្ធនឹងរលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ*

*បញ្ចវោការភូមិ និង ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធក៏នឹងមិនកើត សញ្ញាខន្ធក៏នឹងមិនរលត់។*

**បដិលោមបុច្ឆា:** យស្ស វា បន យត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ, តស្ស តត្ថ វេទនាខន្ធោ នុប្បជ្ជិស្សតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងមិនកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** អាមន្តា *មែន។*

## ការសំដែងអត្ថធម៌ និង ការចែកគោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ វេទនាខន្ធោ នុប្បជ្ជិស្សតិ *ជាសន្និដ្ឋានបទ។*

តស្ស តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ *ជាសំសយបទ។*

*๑ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមកភវិកៈ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២(វៀរអបាយភូមិ ៤)(បច្ឆិមកភវិកៈដោយត្រង់),*

*✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនកើតក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋភូមិ ១) (បច្ឆិមកភវិកៈដោយអម),*

*និង អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) ដែលហៅថា។ល។ (បរិនិព្វុតដោយត្រង់),*

*✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនកើតក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋភូមិ ១) (បរិនិព្វុតដោយអម),*

*សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និង អសញ្ញសត្តភូមិ ១។*

៙ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា ។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វន្តដោយត្រង់),

✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនកើតក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា ។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) (បរិនិព្វន្តដោយអម),

សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ប៉ុណ្ណោះ ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា វេទនាខន្ធនឹងមិនកើតដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏នឹងមិនរលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលជាបច្ឆិមភវិកៈ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា ។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បច្ឆិមភវិកៈដោយត្រង់), បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនកើតក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា ។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) (បច្ឆិមភវិកៈដោយអម) ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **បច្ឆិមភវិកានំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាខន្ធោ នុប្បជ្ជិស្សតិ នោ ច តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតិ** ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា ។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វន្តដោយត្រង់), បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនកើតក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថា ។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ ១) (បរិនិព្វន្តដោយអម), សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុង

អសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ច ឧប្បជ្ជិស្សតិ សញ្ញាក្ខន្ធោ ច ន និរុជ្ឈិស្សតិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិភង្គដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិស្សតិ** ជាសន្និដ្ឋានបទ

**តស្ស តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ** ជាសំសយបទៗ

๏ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថាៗលៗ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វន្តដោយត្រង់),

✳ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនកើតក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថាៗលៗ និង ចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥(វៀរអកនិដ្ឋកភូមិ ១) (បរិនិព្វន្តដោយអម),

សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និង អសញ្ញសត្តភូមិ ១ៗ

๏ អន្តធម៌របស់សំសយបទ ដូចគ្នាៗ

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចបញ្ហា** សួរថា ម្យ៉ាងទៀត សញ្ញាខន្ធនឹងមិនរលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏នឹងមិនកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថាៗលៗ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២២ (វៀរអបាយភូមិ ៤) (បរិនិព្វន្តដោយត្រង់), បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ហើយនឹងមិនកើតក្នុងភូមិដែលខ្លួនកើតនៅទៀត ដែលហៅថាៗលៗ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២៥ (វៀរអកនិដ្ឋកភូមិ

*១) (បរិនិព្វុតដោយអម), សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ ក្នុងអសញ្ញសត្តភូមិ ១ ដែលជាអគ្គធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏នឹងមិនកើតផង។*

(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)

(ចប់ បុគ្គលោកាសវារៈ)

## (ចប់ ឧប្បាទនិរោធវារៈ អនាគតវារៈ បច្ចនីកៈ)

## បវត្តិវារៈ ឧប្បាទនិរោធវារៈ បច្ចុប្បន្នាតីតវារៈ អនុលោម បុគ្គលវារៈ

**(វ. ឧនិ. ៤ (១+២) នុ. ឈ.)**

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស វេទនាក្ខន្ធោ និរុជ្ឈិត្ថាតិ? *រូបក្ខន្ធកំពុងកើតដល់បុគ្គលណា, វេទនាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

**បដិលោមបុច្ឆាៈ** យស្ស វា បន វេទនាក្ខន្ធោ និរុជ្ឈិត្ថ, តស្ស រូបក្ខន្ធោ ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត វេទនាខន្ធធ្លាប់រលត់ដល់បុគ្គលណា, រូបក្ខន្ធក៏កំពុងកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនាៈ** សព្វេសំ ចវន្តានំ អរូបំ ឧបបជ្ជន្តានំ តេសំ វេទនាក្ខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ រូបក្ខន្ធោ ឧប្បជ្ជតិ, បញ្ចវោការំ ឧបបជ្ជន្តានំ អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ វេទនាក្ខន្ធោ ច និរុជ្ឈិត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ។ *ពួកបុគ្គលទាំងអស់ដែលកំពុងស្លាប់ និង ពួកបុគ្គលដែលកំពុងកើតក្នុងអរូបភូមិនោះ វេទនាខន្ធធ្លាប់រលត់ តែរូបក្ខន្ធមិនមែនកំពុងកើតដល់*

បុគ្គលពួកនោះ, ពួកបុគ្គលដែលកំពុងកើតក្នុងបញ្ចវោការភូមិ អសញ្ញសត្តភូមិនោះ វេទនាខន្ធក៏ជាប់រលត់ រូបក្ខន្ធក៏កំពុងកើត។

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

**យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ** ជាសន្និដ្ឋានបទ។

**តស្ស វេទនាខន្ធោ និរុជ្ឈិត្ថ** ជាសំសយបទ។

១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។

១ អត្ថធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បុច្ឆាបញ្ហា** សួរថា រូបក្ខន្ធកំពុងកើតដល់បុគ្គលណា, វេទនាខន្ធក៏ជាប់រលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏ជាប់រលត់ផង។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន វេទនាខន្ធោ និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទ។

**តស្ស រូបក្ខន្ធោ ឧប្បជ្ជតិ** ជាសំសយបទ។

១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុង ៣១ ភូមិ ដែលហៅថា។ល។, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ ដែលហៅថា។ល។,

**និង** បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។

៙ អន្តធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធធ្លាប់រលត់ដល់បុគ្គលណា, រូបក្ខន្ធក៏កំពុងកើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុង ៣១ ភូមិ ដែលហៅថា។ល។, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ ដែលហៅថា។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **សព្វេសំ ចវន្តានំ អរូបំ ឧបបជ្ជន្តានំ តេសំ វេទនាខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ រូបក្ខន្ធោ ឧប្បជ្ជតិ** ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទ បានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការំ ឧបបជ្ជន្តានំ អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ វេទនាខន្ធោ ច និរុជ្ឈិត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. ចេតនាខន្ធមូល:

## ១. វេទនាខន្ធមូលះ សញ្ញាខន្ធមូលីយមកះ

**អនុលោមបុច្ឆា:** យស្ស វេទនាខន្ធោ ឧប្បជ្ជតិ, តស្ស សញ្ញាខន្ធោ និរុជ្ឈិស្សតីតិ? *វេទនាខន្ធកំពុងកើតដល់បុគ្គលណា, សញ្ញាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** អាមន្តា *មែន។*

**បដិលោមបុច្ឆា:** យស្ស វា បន សញ្ញាខន្ធោ និរុជ្ឈិត្ថ, តស្ស វេទនាខន្ធោ ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធធ្លាប់រលត់ដល់បុគ្គលណា, វេទនាខន្ធក៏កំពុងកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនា:** សព្វេសំ ចវន្តានំ អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ សញ្ញាខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ វេទនាខន្ធោ ឧប្បជ្ជតិ, ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ សញ្ញាខន្ធោ ច និរុជ្ឈិត្ថ វេទនាខន្ធោ ច ឧប្បជ្ជតិ។ *ពួកបុគ្គលទាំងអស់ដែលកំពុងស្លាប់ និង ពួកបុគ្គលដែលកំពុងកើតក្នុងអសញ្ញសត្តភូមិនោះ សញ្ញាខន្ធធ្លាប់រលត់ តែ វេទនាខន្ធមិនមែនកំពុងកើតដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលកំពុងកើតក្នុង ចតុវោការភូមិ បញ្ចវោការភូមិនោះ សញ្ញាខន្ធ ក៏ធ្លាប់រលត់ វេទនាខន្ធក៏កំពុងកើត។*

## ការសំដែងអង្គធម៌ និង ការចែកកោដ្ឋាសះ

## ក្នុងអនុលោមបុច្ឆា

យស្ស វេទនាខន្ធោ ឧប្បជ្ជតិ *ជាសន្និដ្ឋានបទ។*

តស្ស សញ្ញាខន្ធោ និរុជ្ឈិត្ថ *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។*

*៙ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា វេទនាខន្ធកំពុងកើតដល់បុគ្គលណា, សញ្ញាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះឬ?*

*ទើបព្រះអង្គទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏ធ្លាប់រលត់ផង។*

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន សញ្ញាខន្ធោ និរុជ្ឈិត្ថ** *ជាសន្និដ្ឋានបទ។*

**តស្ស វេទនាខន្ធោ ឧប្បជ្ជតិ** *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុង ៣១ ភូមិ ដែលហៅថា។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។,*

***និង** បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។*

*៙ អន្តធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត សញ្ញាខន្ធធ្លាប់រលត់ដល់បុគ្គលណា, វេទនាខន្ធក៏កំពុងកើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុង ៣១ ភូមិ ដែលហៅថា។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈមានការបដិសេធសំសយបទ ដូចបានសំដែងថា **សព្វេសំ ចវន្តានំ អសញ្ញសត្តំ***

ឧបបជ្ជន្តានំ តេសំ សញ្ញាខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ វេទនាខន្ធោ ឧប្បជ្ជតិ *ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថាឃលៗ ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ សញ្ញាខន្ធោ ច និរុជ្ឈិត្ថ វេទនាខន្ធោ ច ឧប្បជ្ជតិ *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលវារៈ)**

**បវត្តិវារៈ ឧប្បាទនិរោធវារៈ បច្ចុប្បន្នាតីតវារៈ អនុលោម ឱកាសវារៈ**

**(វំ. ឧនិ. ៤(១+២) នុ. ឱ.)**

## ក. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ, តត្ថ វេទនាខន្ធោ និរុជ្ឈិត្ថាតិ? *រូបក្ខន្ធកំពុងកើតក្នុងភូមិណា, វេទនាខន្ធក៏ធ្លាប់រលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អសញ្ញសត្តេ តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ នោ ច តត្ថ វេទនាខន្ធោ និរុជ្ឈិត្ថ, បញ្ចវោការេ តត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ វេទនាខន្ធោ ច និរុជ្ឈិត្ថ។ *ក្នុងអសញ្ញសត្តភូមិនោះ រូបក្ខន្ធកំពុងកើត តែវេទនាខន្ធមិនធ្លាប់រលត់ក្នុងភូមិនោះ, ក្នុងបញ្ចវោការភូមិនោះ រូបក្ខន្ធក៏កំពុងកើត វេទនាខន្ធក៏ធ្លាប់រលត់ៗ*

**បដិលោមបុច្ឆា:** យត្ថ វា បន វេទនាក្ខន្ធោ និរុជ្ឈិត្ថ, តត្ថ រូបក្ខន្ធោ ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត វេទនាខន្ធធ្លាប់រលត់ក្នុងភូមិណា, រូបក្ខន្ធក៏កំពុងកើតក្នុងភូមិនោះឬ?*

**វិសជ្ជនា:** អរូបេ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ នោ ច តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ, បញ្ចវោការេ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ។ *ក្នុងអរូបភូមិនោះ វេទនាខន្ធធ្លាប់រលត់ តែរូបក្ខន្ធមិនមែនកំពុងកើតក្នុងភូមិនោះ, ក្នុងបញ្ចវោការភូមិនោះ វេទនាខន្ធក៏ធ្លាប់រលត់ រូបក្ខន្ធក៏កំពុងកើត។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ *ជាសន្និដ្ឋានបទ។*

តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។*

*និង បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*៙ អត្ថធម៌របស់សំសយបទ បានដល់ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា***បរិបុណ្ណបញ្ហា** *សួរថា រូបក្ខន្ធកំពុងកើតក្នុងភូមិណា, វេទនាខន្ធក៏ធ្លាប់រលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយកអសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **អសញ្ញសត្តេ តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ នោ ច តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ** *ហើយទ្រង់លើកយកបញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជា*

អង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការេ តត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ វេទនាក្ខន្ធោ ច និរុជ្ឈិត្ថ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន វេទនាក្ខន្ធោ និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទ។

**តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ** ជាសំសយបទ។

◉ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ និង បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។

◉ អង្គធម៌របស់សំសយបទ បានដល់ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធធ្លាប់រលត់ក្នុងភូមិណា, រូបក្ខន្ធក៏កំពុងកើតក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយកអរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អរូបេ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ នោ ច តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ** ហើយទ្រង់លើកយក បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការេ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ

**(មូលី ដែលនៅសល់សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. ចេទនាខន្ធមូល:

## ១. វេទនាក្ខន្ធមូលៈ សញ្ញាក្ខន្ធមូលីយមកៈ

**អនុលោមបុច្ឆា:** យត្ថ វេទនាក្ខន្ធោ ឧប្បជ្ជតិ, តត្ថ សញ្ញាក្ខន្ធោ និរុជ្ឈិត្ថាតិ? *វេទនាខន្ធកំពុងកើតក្នុងភូមិណា, សញ្ញាខន្ធក៏ធ្លាប់រលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** អាមន្តា *មែន។*

**បដិលោមបុច្ឆា:** យត្ថ វា បន សញ្ញាក្ខន្ធោ និរុជ្ឈិត្ថ, តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធធ្លាប់រលត់ក្នុងភូមិណា, វេទនាខន្ធក៏កំពុងកើតក្នុងភូមិនោះឬ?*

**វិសជ្ជនា:** អាមន្តា *មែន។*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យត្ថ វេទនាក្ខន្ធោ ឧប្បជ្ជតិ *ជាសន្និដ្ឋានបទ។*

តត្ថ សញ្ញាក្ខន្ធោ និរុជ្ឈិត្ថ *ជាសំសយបទ។*

*◉ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*◉ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចុប្បន្នបញ្ហា សួរថា វេទនាខន្ធកំពុងកើតក្នុងភូមិណា, សញ្ញាខន្ធក៏ធ្លាប់រលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏ធ្លាប់រលត់ផង។*

# ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន សញ្ញាខន្ធោ និរុជ្ឈតិ** *ជាសន្និដ្ឋានបទ។*

**តត្ថ វេទនាខន្ធោ ឧប្បជ្ជតិ** *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥។*

*៙ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធធ្លាប់រលត់ក្នុងភូមិណា, វេទនាខន្ធក៏កំពុងកើតក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ* **បដិវចនវិសជ្ជនាថា អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា ចតុវោការភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ បញ្ចវោការភូមិ ២៦ ដែលជាទីកើតនៃខន្ធ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏កំពុងកើតផង។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ និកាសវារៈ)**

## បវត្តិវារៈ ឧប្បាទនិរោធវារៈ បច្ចុប្បន្នាតីតវារៈ អនុលោម បុគ្គលោកាសវារៈ

## (រំ. ឧនិ. ៤ (១+២) នុ. លោ.)

## ខ. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា:** យស្ស យត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថាតិ? *រូបក្ខន្ធកំពុងកើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** សុទ្ធាវាសំ ឧបបជ្ជន្តានំ អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ, ឥតរេសំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ តត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ វេទនាក្ខន្ធោ ច និរុជ្ឈិត្ថ។ *ពួកបុគ្គលដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ អសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធកំពុងកើត តែវេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងកើតក្នុងបញ្ចវោការភូមិដែលក្រៅពីសុទ្ធាវាសភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធក៏កំពុងកើត វេទនាខន្ធក៏ធ្លាប់រលត់។*

**បដិលោមបុច្ឆា:** យស្ស វា បន យត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ, តស្ស តត្ថ រូបក្ខន្ធោ ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត វេទនាខន្ធធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏កំពុងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** បញ្ចវោការា ចវន្តានំ អរូបានំ តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ, បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ច និរុជ្ឈិត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ។ *ពួកបុគ្គលដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ និងពួកបុគ្គលដែលកើតនៅក្នុងអរូបភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធធ្លាប់រលត់ តែរូបក្ខន្ធ*

មិនមែន កំពុងកើតដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងកើតក្នុងបញ្ចវោការភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធក៏ជាប់រលត់ រូបក្ខន្ធក៏កំពុងកើតៗ

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

**យស្ស យត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ** ជាសន្និដ្ឋានបទៗ

**តស្ស តត្ថ វេទនាខន្ធោ និរុជ្ឈិត្ថ** ជាសំសយបទៗ

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថាៗលៗ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថាៗលៗ និងអសញ្ញសត្តភូមិ ១,

និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថាៗលៗ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)

៙ អន្តធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថាៗលៗ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធា-វាសភូមិ ៥) ប៉ុណ្ណោះៗ

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា រូបក្ខន្ធកំពុងកើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏ជាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថាៗលៗ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថាៗលៗ និងអសញ្ញសត្តភូមិ ១, ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសំ ឧបបជ្ជន្តានំ អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ នោ ច តេសំ តត្ថ វេទនាខន្ធោ និរុជ្ឈិត្ថ** ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថាៗលៗ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌

របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **ឥតរេសំ បញ្ចវោការេ ឧបបជ្ជន្តានំ តេសំ តត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ វេទនាក្ខន្ធោ ច និរុជ្ឈិត្ថ**, ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភត្តដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទៗ

**តស្ស តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ** ជាសំសយបទៗ

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ដែលហៅថាៗលៗ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥), តិហេតុកបុថុជ្ជន ១ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ និងអរូបភូមិ ៤,

និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថាៗលៗ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥)

៙ អន្តធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថាៗលៗ និងបញ្ចវោការភូមិ ២១(វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះៗ

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏កំពុងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ដែលហៅថាៗលៗ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥), តិហេតុកបុថុជ្ជន ១ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ និងអរូបភូមិ ៤ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការា ចវន្តានំ អរូបានំ តេសំ តត្ថ វេទនាក្ខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ តត្ថ រូបក្ខន្ធោ**

ឧប្បជ្ជតិ *ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ចិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាខន្ធោ ច និរុជ្ឈិត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ, *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ វេទនាខន្ធោ ឧប្បជ្ជតិ, តស្ស តត្ថ សញ្ញាខន្ធោ និរុជ្ឈិត្ថាតិ? *វេទនាខន្ធកំពុងកើតដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** សុទ្ធាវាសំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាខន្ធោ ឧប្បជ្ជតិ នោ ច តេសំ តត្ថ សញ្ញាខន្ធោ និរុជ្ឈិត្ថ, ឥតរេសំ ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាខន្ធោ ច ឧប្បជ្ជតិ សញ្ញាខន្ធោ ច និរុជ្ឈិត្ថ។ *ពួកបុគ្គលដែលកំពុងកើតក្នុងសុទ្ធាវាសភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធកំពុងកើត តែសញ្ញាខន្ធមិនធ្លាប់រលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលក្រៅពីសុទ្ធាវាសភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធក៏កំពុងកើត សញ្ញាខន្ធក៏ធ្លាប់រលត់។*

**បដិលោមបុច្ឆា៖** យស្ស វា បន យត្ថ សញ្ញាខន្ធោ និរុជ្ឈិត្ថ, តស្ស តត្ថ វេទនាខន្ធោ ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏កំពុងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា៖** ចតុវោការា បញ្ចវោការា ចវន្តានំ តេសំ តត្ថ សញ្ញាខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ តត្ថ វេទនាខន្ធោ ឧប្បជ្ជតិ, ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ តត្ថ សញ្ញាខន្ធោ ច និរុជ្ឈិត្ថ វេទនាខន្ធោ ច ឧប្បជ្ជតិ។ *ពួកបុគ្គលដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ ក្នុងភូមិនោះ សញ្ញាខន្ធធ្លាប់រលត់ តែវេទនាខន្ធមិនមែនកំពុងកើតដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ ក្នុងភូមិនោះ សញ្ញាខន្ធក៏ធ្លាប់រលត់ វេទនាខន្ធក៏កំពុងកើត។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យស្ស យត្ថ វេទនាខន្ធោ ឧប្បជ្ជតិ *ជាសន្និដ្ឋានបទ។*

តស្ស តត្ថ សញ្ញាខន្ធោ និរុជ្ឈិត្ថ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥*

*និង បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១(វៀរសុទ្ធាវាសភូមិ ៥)។*

*៙ អត្ថធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា ។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា វេទនាខន្ធកំពុងកើតដល់បុគ្គលណា*

*ក្នុងភូមិណា, សញ្ញាខន្ធក៏ធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអដ្ឋកថាទ្រង់សំដែងដោយការលើកយក អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាស: មានការបដិសេធសំសយបទ ដូចបានសំដែងថា* **សុទ្ធាវាសំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាខន្ធោ ឧប្បជ្ជតិ នោ ច តេសំ តត្ថ សញ្ញាខន្ធោ និរុជ្ឈិត្ថ** *ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និងសំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាស: មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **ឥតរេសំ ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាខន្ធោ ច ឧប្បជ្ជតិ សញ្ញាខន្ធោ ច និរុជ្ឈិត្ថ,** *ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។*

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាខន្ធោ និរុជ្ឈិត្ថ** *ជាសន្និដ្ឋានបទ។*

**តស្ស តត្ថ វេទនាខន្ធោ ឧប្បជ្ជតិ** *ជាសំសយបទ។*

*๑ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោ-ការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ។*

**និង** *បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១(វៀរសុទ្ធាវាសភូមិ ៥)។*

*๑ អត្ថធម៌របស់សំសយបទ បានដល់ បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ច-វោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏កំពុងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និងចតុវោការភូមិ ៤ បញ្ចវោ-ការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាងទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **ចតុវោការា បញ្ចវោការា ចវន្តានំ តេសំ តត្ថ សញ្ញាខន្ធោ និរុជ្ឈិត្ថ នោ ច តេសំ តត្ថ វេទនាខន្ធោ ឧប្បជ្ជតិ** *ហើយទ្រង់លើកយក បុថុជ្ជន ៤ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា ។ល។ និងចតុវោការភូមិ ៤ បញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ តេសំ តត្ថ សញ្ញាខន្ធោ ច និរុជ្ឈិត្ថ វេទនាខន្ធោ ច ឧប្បជ្ជតិ,** *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលោកាសវារៈ)**

## (ចប់ ឧប្បាទនិរោធវារៈ បច្ចុប្បន្នាតីតវារៈ អនុលោម)

## បវត្តិវារៈ ឧប្បាទនិរោធវារៈ បច្ចុប្បន្នាតីតវារៈ បច្ចនីកៈ បុគ្គលវារៈ

## (វ. ឧនិ. ៤ (១+២) ច. ឍ.)

## ក. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាក្ខន្ធមូលីយមកៈ

**អនុលោមបុច្ឆា** យស្ស រូបក្ខន្ធោ នុប្បជ្ជតិ, តស្ស វេទនាក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *រូបក្ខន្ធមិនមែនកំពុងកើតដល់បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា** និរុជ្ឈិត្ថ *ធ្លាប់រលត់ៗ*

**បដិលោមបុច្ឆា** យស្ស វា បន វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ, តស្ស រូបក្ខន្ធោ នុប្បជ្ជតីតិ? *ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់រលត់ដល់ បុគ្គលណា, រូបក្ខន្ធក៏មិនមែនកំពុងកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនា** នត្ថិ *មិនមានៗ*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស រូបក្ខន្ធោ នុប្បជ្ជតិ *ជាសន្និដ្ឋានបទៗ*

តស្ស វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសំសយបទៗ*

*๏ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុង ៣១ ភូមិ ដែលហៅថា ចុតិ, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ ដែលហៅថា ចុតិៗ*

*๏ អត្ថធម៌របស់សំសយបទ មិនមានៗ*

*ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា រូបក្ខន្ធមិនមែនកំពុងកើតដល់*

បុគ្គលណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ **បាឡិគតិវិសជ្ជនាថា និរុជ្ឈិត្ថ** ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុង ៣១ ភូមិ ដែលហៅថា។ល។, តិហេតុកបុថុជ្ជន ១ ផលសេក្ខបុគ្គល ៣ ដែលកំពុងកើតក្នុងអរូបភូមិ ដែលហៅថា។ល។ ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីរូបក្ខន្ធមិនមែនកំពុងកើត តែវេទនាខន្ធធ្លាប់រលត់។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទ។

**តស្ស រូបក្ខន្ធោ ឧប្បជ្ជតិ** ជាសំសយបទ។

៙ អង្គធម៌របស់សន្និដ្ឋានបទ មិនមាន កាលបើអង្គធម៌របស់សន្និដ្ឋានបទមិនមាន- ហើយ អង្គធម៌របស់សំសយបទ ក៏មិនមានដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**មោឃបញ្ហា** សួរថា ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, រូបក្ខន្ធក៏មិនមែនកំពុងកើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិក្ខេបវិសជ្ជនាថា **នត្ថិ** ដែលជាពាក្យវិសជ្ជនាហាមអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា ពួកបុគ្គលដែលវេទនាខន្ធមិនធ្លាប់រលត់ក្នុងភពផ្សេងៗនោះមិនមាន មានតែពួកបុគ្គលដែលវេទនាខន្ធធ្លាប់រលត់មកហើយទាំងអស់។

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** **យស្ស វេទនាក្ខន្ធោ ឧប្បជ្ជតិ, តស្ស សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថាតិ?** វេទនាខន្ធមិនមែនកំពុងកើតដល់បុគ្គលណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ?

**វិសជ្ជនា៖** និរុជ្ឈិត្ថ *ធ្លាប់រលត់។*

**បដិលោមបុច្ឆា៖** យស្ស វា បន សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថ តស្ស វេទនាក្ខន្ធោ ន ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, វេទនាខន្ធក៏មិនមែនកំពុងកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនា៖** នត្ថិ *មិនមាន។*

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស វេទនាក្ខន្ធោ ឧប្បជ្ជតិ *ជាសន្និដ្ឋានបទ។*

តស្ស សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសំសយបទ។*

*១ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុង ៣១ ភូមិ ដែលហៅថា។ល។, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។*

*១ អន្តធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា វេទនាខន្ធមិនមែនកំពុងកើតដល់បុគ្គលណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ* បាឡិគតិវិសជ្ជនាថា និរុជ្ឈិត្ថ *ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុង ៣១ ភូមិ ដែលហៅថា។ល។, សុគតិហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីវេទនាខន្ធមិនមែនកំពុងកើត តែសញ្ញាខន្ធធ្លាប់រលត់។*

## ក្នុងបដិលោមបុច្ឆា

យស្ស វា បន សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថ *ជាសន្និដ្ឋានបទ។*

តស្ស វេទនាក្ខន្ធោ ឧប្បជ្ជតិ *ជាសំសយបទ។*

៙ អន្តធម៌របស់សន្និដ្ឋានបទ មិនមាន កាលបើអន្តធម៌របស់សន្និដ្ឋានបទមិនមាន-ហើយ អន្តធម៌របស់សំសយបទ ក៏មិនមានដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាមោឃបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា, វេទនាខន្ធក៏មិនមែនកំពុងកើតដល់បុគ្គលនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិក្ខេបវិសជ្ជនាថា នត្ថិ ដែលជាពាក្យវិសជ្ជនាហាមអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា ពួកបុគ្គលដែលសញ្ញាខន្ធមិនធ្លាប់រលត់ក្នុងភពផ្សេងៗនោះមិនមាន មានតែពួកបុគ្គលដែលសញ្ញាខន្ធធ្លាប់រលត់មកហើយទាំងអស់។

**(មូលី មូលៈ ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលវារៈ)**

## បវត្តិវារៈ ឧប្បាទនិរោធវារៈ បច្ចុប្បន្នាតីតវារៈ បច្ចនីកៈ ឱកាសវារៈ

**(រ. ឧនិ. ៤ (១+២) ច..ឱ)**

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា៖** យត្ថ *រូបក្ខន្ធោ* ឧប្បជ្ជតិ, តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *រូបក្ខន្ធមិនមែនកំពុងកើតក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនា៖** និរុជ្ឈិត្ថ *ធ្លាប់រលត់។*

**បដិលោមបុច្ឆា៖** យត្ថ វា បន វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ, តត្ថ *រូបក្ខន្ធោ* ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, រូបក្ខន្ធក៏មិនមែនកំពុងកើតក្នុងភូមិនោះឬ?*

**វិសជ្ជនា៖** ឧប្បជ្ជតិ *កំពុងកើត។*

# ការសំដែងអង្គធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

**យត្ថ រូបក្ខន្ធោ នុប្បជ្ជតិ** ជាសន្និដ្ឋានបទ។

**តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ** ជាសំសយបទ។

៙ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤។

៙ អង្គធម៌របស់សំសយបទ មិនមាន។

ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា រូបក្ខន្ធមិនមែនកំពុងកើតក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ?

ទើបព្រះអង្គទ្រង់សំដែងដោយបាឡិគតិវិសជ្ជនាថា **និរុជ្ឈិត្ថ**, ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អរូបភូមិ ៤ ដែលជាទីកើតនៃនាមក្ខន្ធ ៤ ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីរូបក្ខន្ធមិនមែនកំពុងកើត តែវេទនាខន្ធធ្លាប់រលត់។

## ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទ។

**តត្ថ រូបក្ខន្ធោ នុប្បជ្ជតិ** ជាសំសយបទ។

៙ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។

៙ អង្គធម៌របស់សំសយបទ មិនមាន។

ដូច្នេះ ពាក្យសួរបទនេះ ជាបុរេបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, រូបក្ខន្ធក៏មិនមែនកំពុងកើតក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបាឡិគតិវិសជ្ជនាថា **ឧប្បជ្ជតិ** ដែលជាពាក្យវិសជ្ជនាផ្ទុយពីពាក្យសួរ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីវេទនាខន្ធមិនធ្លាប់រលត់ តែរូបក្ខន្ធកំពុងកើត។

**(មូលី ដែលនៅសេសសំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យត្ថ វេទនាខន្ធោ នុប្បជ្ជតិ, តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិស្សតីតិ? *វេទនាខន្ធមិនមែនកំពុងកើតក្នុងភូមិណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

**បដិលោមបុច្ឆាៈ** យត្ថ វា បន សញ្ញាខន្ធោ ន និរុជ្ឈិត្ថ, តត្ថ វេទនាខន្ធោ នុប្បជ្ជតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, វេទនាខន្ធក៏មិនមែនកំពុងកើតក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យត្ថ វេទនាខន្ធោ នុប្បជ្ជតិ *ជាសន្និដ្ឋានបទ។*

តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិត្ថ *ជាសំសយបទ។*

*๏ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។*

*๏ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា វេទនាខន្ធមិនមែនកំពុងកើតក្នុងភូមិណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សញ្ញាខន្ធក៏មិនធ្លាប់រលត់ផង។*

# ក្នុងបដិលោមបុច្ឆា

**យត្ថ វា បន សញ្ញាខន្ធោ ន និរុជ្ឈិត្ថ** *ជាសន្និដ្ឋានបទ។*

**តត្ថ វេទនាខន្ធោ នុប្បជ្ជតិ** *ជាសំសយបទ។*

*๑ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង។*

*๑ អង្គធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់រលត់ក្នុងភូមិណា, វេទនាខន្ធក៏មិនមែនកំពុងកើតក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយ* **បដិវចនវិសជ្ជនាថា អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា អសញ្ញសត្តភូមិ ១ ដែលជាទីកើតនៃរូបក្ខន្ធតែម្យ៉ាង ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ វេទនាខន្ធក៏មិនមែនកំពុងកើតផង។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**( ចប់ និកាសវារៈ)**

# ត. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យស្ស យត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *រូបក្ខន្ធមិនមែនកំពុងកើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** បញ្ចវោការា ចវន្តានំ អរូបានំ តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ, សុទ្ធាវាសេ បរិនិព្វន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ តត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ វេទនាក្ខន្ធោ ច ន និរុជ្ឈិត្ថ។ *ពួកបុគ្គលដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ និង ពួកបុគ្គលដែលកើតនៅក្នុងអរូបភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធមិនមែនកំពុងកើត តែវេទនាខន្ធធ្លាប់រលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និង ពួកបុគ្គលដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ រូបក្ខន្ធក៏មិនមែនកំពុងកើត វេទនាខន្ធក៏មិនធ្លាប់រលត់។*

**បដិលោមបុច្ឆាៈ** យស្ស វា បន យត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ, តស្ស តត្ថ រូបក្ខន្ធោ ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏មិនមែនកំពុងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនាៈ** សុទ្ធាវាសំ ឧបបជ្ជន្តានំ អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ, សុទ្ធាវាសេ បរិនិព្វន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ តត្ថ

*វេទនាខន្ធោ ច ន និរុជ្ឈិត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ។ ពួកបុគ្គលដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ អសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធមិនធ្លាប់រលត់ តែរូបក្ខន្ធកំពុងកើតដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និង ពួកបុគ្គលដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធ ក៏មិនធ្លាប់រលត់ រូបក្ខន្ធក៏មិនមែនកំពុងកើត។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

**យស្ស យត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ** *ជាសន្និដ្ឋានបទ។*

**តស្ស តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ** *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុងបញ្ចវោការភូមិ ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២១(វៀរសុទ្ធាវាសភូមិ ៥), តិហេតុកបុថុជ្ជន ១ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ និង អរូបភូមិ ៤,*

*និង អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១។*

*៙ អត្ថធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា រូបក្ខន្ធមិនមែនកំពុងកើតដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុង*

បញ្ចវោការភូមិ ដែលហៅថា។ល។ និងបញ្ចវោការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥), តិហេតុកបុថុជ្ជន ១ ផលបុគ្គល ៤ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអរូបភូមិ និង អរូបភូមិ ៤ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **បញ្ចវោការេ ចវន្តានំ អរូបានំ តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ** ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥ អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និង សុទ្ធាវាសភូមិ ៥ , សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និង អសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទ បានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសេ បរិនិព្វន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ តត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ វេទនាក្ខន្ធោ ច ន និរុជ្ឈិត្ថ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆា នេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិភង្គដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ វេទនាក្ខន្ធោ ន និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ** ជាសំសយបទ។

๑ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១។

និង អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។

និង សុទ្ធាវាសភូមិ ៥ , សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និង អសញ្ញសត្តភូមិ ១។

៙ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វាន ក្នុងសុទ្ធាវាសភូមិ ៥ អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត វេទនាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, រូបក្ខន្ធក៏មិនមែនកំពុងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើតក្នុងអសញ្ញសត្តភូមិ ដែលហៅថា ។ល។ និងអសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសំ ឧបបជ្ជន្តានំ អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ តត្ថ វេទនាខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ រូបក្ខន្ធោ ឧប្បជ្ជតិ** ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ ដែលហៅថា។ល។ និងអសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធ សំសយបទ ដូចបានសំដែងថា **សុទ្ធាវាសេ បរិនិព្វន្តានំ អសញ្ញសត្តា ចវន្តានំ តេសំ តត្ថ វេទនាខន្ធោ ច ន និរុជ្ឈិត្ថ រូបក្ខន្ធោ ច ឧប្បជ្ជតិ** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមាន វិកន្តដោយត្រង់។

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលិយមកៈ

**អនុលោមបុច្ឆា:** យស្ស យត្ថ វេទនាក្ខន្ធោ ឧប្បជ្ជតិ, តស្ស តត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថាតិ? *វេទនាខន្ធមិនមែនកំពុងកើតដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ?*

**វិសជ្ជនា:** ចតុវោការា បញ្ចវោការា ចវន្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជតិ នោ ច តេសំ តត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថ, សុទ្ធាវាសេ បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ វេទនាក្ខន្ធោ ច ឧប្បជ្ជតិ សញ្ញាក្ខន្ធោ ច ន និរុជ្ឈិត្ថ។ *ពួកបុគ្គលដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធមិនមែនកំពុងកើត តែសញ្ញាខន្ធធ្លាប់រលត់ដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និង ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិនោះ ក្នុងភូមិនោះ វេទនាខន្ធក៏មិនមែនកំពុងកើត សញ្ញាខន្ធក៏មិនធ្លាប់រលត់។*

**បដិលោមបុច្ឆា:** យស្ស វា បន យត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថ, តស្ស តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត សញ្ញាខន្ធមិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនមែនកំពុងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ ?*

**វិសជ្ជនា:** សុទ្ធាវាសំ ឧបបជ្ជន្តានំ តេសំ តត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ ឧប្បជ្ជតិ, សុទ្ធាវាសេ បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ សញ្ញាក្ខន្ធោ ច ន និរុជ្ឈិត្ថ

វេទនាខន្ធោ ច ឧប្បជ្ជតិ។ ពួកបុគ្គលដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ក្នុងភូមិនោះ សញ្ញាខន្ធមិនធ្លាប់រលត់ តែវេទនាខន្ធកំពុងកើតដល់បុគ្គលពួកនោះ ក្នុងភូមិនោះ, ពួកបុគ្គលដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ និង ពួកបុគ្គលដែលកើតនៅក្នុងអសញ្ញសត្តភូមិ ក្នុងភូមិនោះ សញ្ញាខន្ធក៏មិនធ្លាប់រលត់ វេទនាខន្ធក៏មិនមែន - កំពុងកើត។

## ការសំដែងអន្តធម៌ និង ការចែកគោជ្ឈាសៈ ក្នុងអនុលោមបុច្ឆា

**យស្ស យត្ថ វេទនាខន្ធោ ឧប្បជ្ជតិ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិត្ថ** ជាសំសយបទ។

๏ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និង ចតុវោការភូមិ ៤ បញ្ចវោ-ការភូមិ ២១ (វៀរសុទ្ធាវាសភូមិ ៥),

និង អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និង សុទ្ធាវាសភូមិ ៥ , សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និង អសញ្ញសត្តភូមិ ១។

๏ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា វេទនាខន្ធមិនមែនកំពុងកើតដល់បុគ្គលណា ក្នុងភូមិណា, សញ្ញាខន្ធក៏មិនធ្លាប់រលត់ដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក បុថុជ្ជន ៤ ផលបុគ្គល ៤ ដែលកំពុងស្លាប់ក្នុងចតុវោការភូមិ បញ្ចវោការភូមិ ដែលហៅថា។ល។ និង ចតុវោការភូមិ ៤ បញ្ចវោការភូមិ

២១ (វៀរសុទ្ធាវាសភូមិ ៥) ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែ ម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **ចតុវោការេ បញ្ចវោការេ ចវន្តានំ តេសំ តត្ថ វេទនាខន្ធោ ឧប្បជ្ជតិ នោ ច តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិត្ថ** ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសេ បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ វេទនាខន្ធោ ច ឧប្បជ្ជតិ សញ្ញាខន្ធោ ច ន និរុជ្ឈិត្ថ** ពាក្យវិសជ្ជនា ក្នុងអនុលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកន្តដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

**យស្ស វា បន យត្ថ សញ្ញាខន្ធោ ន និរុជ្ឈិត្ថ** ជាសន្និដ្ឋានបទ។

**តស្ស តត្ថ វេទនាខន្ធោ ឧប្បជ្ជតិ** ជាសំសយបទ។

๑ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥,

**និង** អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១។

๑ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤(វៀរ

អកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត សញ្ញាខន្ធ មិនធ្លាប់រលត់ដល់បុគ្គលណា ក្នុងភូមិណា, វេទនាខន្ធក៏មិនមែនកំពុងកើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អនាគាមីបុគ្គល ១ ដែលកំពុងកើតក្នុងសុទ្ធាវាសភូមិ ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥ ដែលជាអង្គធម៌របស់សន្និដ្ឋានបទ បានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសំ ឧបបជ្ជន្តានំ តេសំ តត្ថ សញ្ញាខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ វេទនាខន្ធោ ឧប្បជ្ជតិ,** ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ ដែលកំពុងបរិនិព្វានក្នុងសុទ្ធាវាសភូមិ ៥, អនាគាមីបុគ្គល ១ ដែលកំពុងស្លាប់ក្នុងសុទ្ធាវាសភូមិ ៤ (វៀរអកនិដ្ឋកភូមិ ១) ដែលហៅថា។ល។ និងសុទ្ធាវាសភូមិ ៥, សុគតិអហេតុកបុគ្គល ១ ដែលកំពុងកើត និង កំពុងស្លាប់ក្នុង ក្នុងអសញ្ញសត្តភូមិ និងអសញ្ញសត្តភូមិ ១ ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និងសំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិន មានការបដិសេធសំសយបទ ដូចបានសំដែងថា **សុទ្ធាវាសេ បរិនិព្វន្តានំ អសញ្ញសត្តានំ តេសំ តត្ថ សញ្ញាខន្ធោ ច ន និរុជ្ឈិត្ថ វេទនាខន្ធោ ច ឧប្បជ្ជតិ** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមាន វិកប្បដោយត្រង់។

**(មូលី មូលៈ ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បុគ្គលោកាសវារៈ)**

## (ចប់ ឧប្បាទនិរោធវារៈ បច្ចុប្បន្នាតីតវារៈ បច្ចនីកៈ)

## បវត្តិវារៈ ឧប្បាទនិរោធវារៈ បច្ចុប្បន្នានាគតវារៈ អនុលោម បុគ្គលវារៈ

## (វ. ឧនិ. ៥(១+៣) នុ. ឈ.)

## ក. រូបក្ខន្ធមូលៈ

## ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា** យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ, តស្ស វេទនាខន្ធោ និរុជ្ឈិស្សតីតិ? *រូបក្ខន្ធកំពុងកើតដល់បុគ្គលណា, វេទនាខន្ធក៏នឹងរលត់ដល់បុគ្គលនោះឬ?*

**វិសជ្ជនា** អាមន្តា *មែន។*

**បដិលោមបុច្ឆា** យស្ស វា បន វេទនាខន្ធោ និរុជ្ឈិស្សតិ, តស្ស រូបក្ខន្ធោ ឧប្បជ្ជតីតិ? *ម្យ៉ាងទៀត វេទនាខន្ធនឹងរលត់ដល់បុគ្គលណា, រូបក្ខន្ធក៏កំពុងកើតដល់បុគ្គលនោះឬ?*

**វិសជ្ជនា** សព្វេសំ ចវន្តានំ អរូបំ ឧបបជ្ជន្តានំ តេសំ វេទនាខន្ធោ និរុជ្ឈិស្សតិ នោ ច តេសំ រូបក្ខន្ធោ ឧប្បជ្ជតិ, បញ្ចវោការំ ឧបបជ្ជន្តានំ អសញ្ញសត្តំ ឧបបជ្ជន្តានំ តេសំ វេទនាខន្ធោ ច និរុជ្ឈិស្សតិ រូបក្ខន្ធោ ច ឧប្បជ្ជតិ។ *ពួកបុគ្គលទាំងអស់ដែលកំពុងស្លាប់ និង ពួកបុគ្គលដែលកំពុងកើតក្នុងអរូបភូមិនោះ វេទនាខន្ធនឹងរលត់ តែរូបក្ខន្ធមិនមែនកំពុងកើតដល់បុគ្គលពួកនោះ, ពួកបុគ្គលដែលកំពុងកើតក្នុងបញ្ចវោការភូមិ និង អសញ្ញសត្តភូមិនោះ វេទនាខន្ធក៏នឹងរលត់ រូបក្ខន្ធក៏កំពុងកើត។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ *ជាសន្និដ្ឋានបទ។*

តស្ស វេទនាខន្ធោ និរុជ្ឈិស្សតិ *ជាសំសយបទ។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ឆាបញ្ហា សួរថាម្យ៉ាងទៀត បុគ្គលណា មិនមែនកំពុងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា ភព្វបុថុជ្ជន ១ អភព្វបុថុជ្ជន ១ អរិយបុគ្គល ៧ (វៀរអរហត្តមគ្គបុគ្គល ១) ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធផងៗ*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

## (ចប់ បច្ចុប្បន្នវារៈ បច្ចនីកៈ)

# អតីតវារៈ អនុលោម បុគ្គលវារៈ

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យោ *រូបក្ខន្ធំ* បរិជានិត្ថ, សោ វេទនាក្ខន្ធំ បរិជានិត្ថាតិ? *បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនាៈ** *អាមន្តា មែនៗ*

**បដិលោមបុច្ឆាៈ** យោ វា បន វេទនាក្ខន្ធំ បរិជានិត្ថ, សោ *រូបក្ខន្ធំ* បរិជានិត្ថាតិ? *ម្យ៉ាងទៀត បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ?*

**វិសជ្ជនាៈ** *អាមន្តា មែនៗ*

# ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

**យោ រូបក្ខន្ធំ បរិជានិត្ត** *ជាសន្និដ្ឋានបទ។*

**សោ វេទនាខន្ធំ បរិជានិត្ត** *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១។*

*៙ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា បុគ្គលណា ជ្ញាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏ជ្ញាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អរហត្តផលបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏ជ្ញាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធផង។*

## ក្នុងបដិលោមបុច្ឆា

**យោ វា បន វេទនាខន្ធំ បរិជានិត្ត** *ជាសន្និដ្ឋានបទ។*

**សោ រូបក្ខន្ធំ បរិជានិត្ត** *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១។*

*៙ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណា ជ្ញាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏ជ្ញាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អរហត្តផលបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏ជ្ញាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធផង។*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យោ វេទនាខន្ធំ បរិជានិត្ត, សោ សញ្ញាខន្ធំ បរិជានិត្តាតិ? *បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

**បដិលោមបុច្ឆាៈ** យោ វា បន សញ្ញាខន្ធំ បរិជានិត្ត, សោ វេទនាខន្ធំ បរិជានិត្តាតិ? *ម្យ៉ាងទៀត បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យោ វេទនាខន្ធំ បរិជានិត្ត *ជាសន្និដ្ឋានបទ។*

សោ សញ្ញាខន្ធំ បរិជានិត្ត *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១។*

*៙ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចុប្បញ្ញា សួរថា បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា អរហត្តផលបុគ្គល ១ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធផង។*

## ក្នុងបដិលោមបុច្ឆា

យោ វា បន សញ្ញាខន្ធំ បរិជានិត្ថ *ជាសន្និដ្ឋានបទ។*

សោ វេទនាខន្ធំ បរិជានិត្ថ *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១។*

*៙ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អរហត្តផលបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធផង។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

## (ចប់ អតីតវារៈ អនុលោម)

# អតីតវារៈ បច្ចនីកៈ បុគ្គលវារៈ

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យោ *រូបក្ខន្ធំ* ន បរិជានិត្ថ, សោ វេទនាខន្ធំ ន បរិជានិត្ថាតិ? *បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនាៈ** *អាមន្តា មែន។*

**បដិលោមបុច្ឆា៖** យោ វា បន វេទនាខន្ធំ ន បរិជានាតិ, សោ រូបក្ខន្ធំ ន បរិជានាតីតិ? *ម្យ៉ាងទៀត បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ?*

**វិសជ្ជនា៖** អាមន្តា *មែន។*

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

### ក្នុងអនុលោមបុច្ឆា

យោ រូបក្ខន្ធំ ន បរិជានាតិ *ជាសន្និដ្ឋានបទ។*

សោ វេទនាខន្ធំ ន បរិជានាតិ *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កព្វបុថុជ្ជន ១ អកព្វបុថុជ្ជន ១ អរិយបុគ្គល ៧ (វៀរអរហត្តផលបុគ្គល ១)។*

*៙ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា កព្វបុថុជ្ជន ១ អកព្វបុថុជ្ជន ១ អរិយបុគ្គល ៧ (វៀរអរហត្តផលបុគ្គល ១) ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធផង។*

### ក្នុងបដិលោមបុច្ឆា

យោ វា បន វេទនាខន្ធំ ន បរិជានាតិ *ជាសន្និដ្ឋានបទ។*

សោ រូបក្ខន្ធំ ន បរិជានាតិ *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កព្វបុថុជ្ជន ១ អកព្វបុថុជ្ជន ១ អរិយបុគ្គល ៧ (វៀរអរហត្តផលបុគ្គល ១)។*

*៙ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ឆាបញ្ហា សួរថាម្យ៉ាងទៀត បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា ភព្វបុថុជ្ជន ១ អភព្វបុថុជ្ជន ១ អរិយបុគ្គល ៧ (វៀរអរហត្តផលបុគ្គល ១) ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធផង។*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលះ)**

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា:** យោ វេទនាក្ខន្ធំ ន បរិជានិត្ថ, សោ សញ្ញាក្ខន្ធំ ន បរិជានិត្ថាតិ? *បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ?*

**វិសជ្ជនា:** *អាមន្តា មែន។*

**បដិលោមបុច្ឆា:** យោ វា បន សញ្ញាក្ខន្ធំ ន បរិជានិត្ថ, សោ វេទនាក្ខន្ធំ ន បរិជានិត្ថាតិ? *ម្យ៉ាងទៀត បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនា:** *អាមន្តា មែន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យោ វេទនាក្ខន្ធំ ន បរិជានិត្ថ *ជាសន្និដ្ឋានបទ។*

សោ សញ្ញាក្ខន្ធំ ន បរិជានិត្ថ *ជាសំសយបទ។*

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កព្វបុថុជ្ជន ១ អកព្វបុថុជ្ជន ១ អរិយ-បុគ្គល ៧ (វៀរអរហត្តផលបុគ្គល ១)។

៙ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ? ទើបព្រះអដ្ឋកថាចារ្យទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា កព្វបុថុជ្ជន ១ អកព្វបុថុជ្ជន ១ អរិយបុគ្គល ៧ (វៀរអរហត្តផលបុគ្គល ១) ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធផង។

## ក្នុងបដិលោមបុច្ឆា

**យោ វា បន សញ្ញាក្ខន្ធំ ន បរិជានិត្ថ** ជាសន្និដ្ឋានបទ។

**សោ វេទនាក្ខន្ធំ ន បរិជានិត្ថ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កព្វបុថុជ្ជន ១ អកព្វបុថុជ្ជន ១ អរិយបុគ្គល ៧ (វៀរអរហត្តផលបុគ្គល ១)។

៙ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជា**បច្ចាបញ្ហា** សួរថា ម្យ៉ាងទៀត បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអដ្ឋកថាចារ្យទ្រង់សំដែងដោយ**បដិវចនវិសជ្ជនា**ថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា កព្វបុថុជ្ជន ១ អកព្វបុថុជ្ជន ១ អរិយបុគ្គល ៧ (វៀរអរហត្តផលបុគ្គល ១) ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធផង។

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ អតីតវារៈ បច្ចនីកៈ)**

# អនាគតវារៈ អនុលោម បុគ្គលវារៈ

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យោ រូបក្ខន្ធំ បរិជានិស្សតិ, សោ វេទនាក្ខន្ធំ បរិជានិស្សតីតិ? *បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

**បដិលោមបុច្ឆាៈ** យោ វា បន វេទនាក្ខន្ធំ បរិជានិស្សតិ, សោ រូបក្ខន្ធំ បរិជានិស្សតីតិ? *ម្យ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យោ រូបក្ខន្ធំ បរិជានិស្សតិ *ជាសន្និដ្ឋានបទ។*

សោ វេទនាក្ខន្ធំ បរិជានិស្សតិ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់បុគ្គលក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣។*

*៙ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* អាមន្តា *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់*

*សន្និដ្ឋានបទ ព្រោះថា កព្ទបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធផង។*

## ក្នុងបដិលោមបុច្ឆា

**យោ វា បន វេទនាខន្ធំ បរិជានិស្សតិ** *ជាសន្និដ្ឋានបទ។*

**សោ រូបក្ខន្ធំ បរិជានិស្សតិ** *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កព្ទបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ។*

*៙ អត្ថធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ឆាបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអត្ថធម៌របស់សន្និដ្ឋានបទ ព្រោះថា កព្ទបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏នឹងកំណត់ដឹងច្បាស់នូវរូបក្ខន្ធផង។*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលះ)**

# ខ. វេទនាខន្ធមូលះ

## ១. វេទនាខន្ធមូលះ សញ្ញាខន្ធមូលីយមកះ

**អនុលោមបុច្ឆាៈ** យោ វេទនាខន្ធំ បរិជានិស្សតិ, សោ សញ្ញាខន្ធំ បរិជានិស្សតីតិ? *បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ?*

**វិសជ្ជនាៈ** *អាមន្តា មែន។*

**បដិលោមបុច្ឆា:** យោ វា បន សញ្ញាក្ខន្ធំ បរិជានិស្សតិ, សោ វេទនាក្ខន្ធំ បរិជានិស្សតីតិ? *ម្យ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនា:** អាមន្តា *មែន។*

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យោ វេទនាក្ខន្ធំ បរិជានិស្សតិ *ជាសន្និដ្ឋានបទ។*

សោ សញ្ញាក្ខន្ធំ បរិជានិស្សតិ *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ។*

*៙ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ឆាបញ្ហា សួរថា បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា កព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធផង។*

## ក្នុងបដិលោមបុច្ឆា

យោ វា បន សញ្ញាក្ខន្ធំ បរិជានិស្សតិ *ជាសន្និដ្ឋានបទ។*

សោ វេទនាក្ខន្ធំ បរិជានិស្សតិ *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣។*

*៙ អន្តធម៌របស់សំសយបទ ដូចគ្នា។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា* **អាមន្តា** *ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា កព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធផង។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

## (ចប់ អនាគតវារៈ អនុលោម)

# អនាគតវារៈ បច្ចនីកៈ បុគ្គលវារៈ

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយចកៈ

**អនុលោមបុច្ឆា៖** យោ រូបក្ខន្ធំ ន បរិជានិស្សតិ, សោ វេទនាខន្ធំ ន បរិជានិស្សតីតិ? *បុគ្គលណា មិនមែននឹងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនា៖** អាមន្តា *មែន។*

**បដិលោមបុច្ឆា៖** យោ វា បន វេទនាខន្ធំ ន បរិជានិស្សតិ, សោ រូបក្ខន្ធំ ន បរិជានិស្សតីតិ? *ម្យ៉ាងទៀត បុគ្គលណា មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ?*

**វិសជ្ជនា៖** អាមន្តា *មែន។*

# ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

**យោ រូបក្ខន្ធំ ន បរិជានិស្សតិ** ជាសន្និដ្ឋានបទ។

**សោ វេទនាក្ខន្ធំ ន បរិជានិស្សតិ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អកព្វបុថុជ្ជន ១ អរហត្តមគ្គបុគ្គល ១ អរហត្តផលបុគ្គល ១។

៙ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា បុគ្គលណា មិនមែនទីងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះក៏មិនមែនទីងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អកព្វបុថុជ្ជន ១ អរហត្តមគ្គបុគ្គល ១ អរហត្តផលបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏មិនមែនទីងកំណត់ដឹងច្បាស់នូវវេទនាខន្ធផង។

## ក្នុងបដិលោមបុច្ឆា

**យោ វា បន វេទនាក្ខន្ធំ ន បរិជានិស្សតិ** ជាសន្និដ្ឋានបទ។

**សោ រូបក្ខន្ធំ ន បរិជានិស្សតិ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អកព្វបុថុជ្ជន ១ អរហត្តមគ្គបុគ្គល ១ អរហត្តផលបុគ្គល ១។

៙ អន្តធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណា មិនមែនទីងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនមែនទីងកំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអន្តធម៌របស់សន្និដ្ឋានបទ ព្រោះថា អកព្វបុថុជ្ជន ១ អរហត្តមគ្គបុគ្គល ១

*អរហត្តផលបុគ្គល ១ ដែលជាអគ្គធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវរូបក្ខន្ធផង។*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យោ វេទនាក្ខន្ធំ ន បរិជានិស្សតិ, សោ សញ្ញាក្ខន្ធំ ន បរិជានិស្សតីតិ? *បុគ្គលណា មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

**បដិលោមបុច្ឆាៈ** យោ វា បន សញ្ញាក្ខន្ធំ ន បរិជានិស្សតិ, សោ វេទនាក្ខន្ធំ ន បរិជានិស្សតីតិ? *ម្យ៉ាងទៀត បុគ្គលណា មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនាៈ** អាមន្តា *មែន។*

## ការសំដែងអគ្គធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យោ វេទនាក្ខន្ធំ ន បរិជានិស្សតិ *ជាសន្និដ្ឋានបទ។*

សោ សញ្ញាក្ខន្ធំ ន បរិជានិស្សតិ *ជាសំសយបទ។*

*៤ អគ្គធម៌របស់សន្និដ្ឋានបទ បានដល់ អកព្វបុថុជ្ជន ១ អរហត្តមគ្គបុគ្គល ១ អរហត្តផលបុគ្គល ១។*

*៤ អគ្គធម៌របស់សំសយបទ ដូចគ្នា។*

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា បុគ្គលណា មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា អកព្វបុថុជ្ជន ១ អរហត្តមគ្គបុគ្គល ១ អរហត្តផលបុគ្គល ១ ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធផង។

## ក្នុងបដិលោមបុច្ឆា

**យោ វា បន សញ្ញាខន្ធំ ន បរិជានិស្សតិ** ជាសន្និដ្ឋានបទ។

**សោ វេទនាខន្ធំ ន បរិជានិស្សតិ** ជាសំសយបទ។

๏ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អកព្វបុថុជ្ជន ១ អរហត្តមគ្គបុគ្គល ១ អរហត្តផលបុគ្គល ១។

๏ អង្គធម៌របស់សំសយបទ ដូចគ្នា។

ដូច្នេះ ពាក្យសួរបទនេះ ជាបច្ចាបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណា មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិវចនវិសជ្ជនាថា **អាមន្តា** ដែលជាពាក្យវិសជ្ជនាព្រមទទួលអង្គធម៌របស់សន្និដ្ឋានបទ ព្រោះថា អកព្វបុថុជ្ជន ១ អរហត្តមគ្គបុគ្គល ១ អរហត្តផលបុគ្គល ១ ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធផង។

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ អនាគតវារៈ បច្ចនីកៈ)**

# បច្ចុប្បន្នាតីតវារៈ អនុលោម បុគ្គលវារៈ

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា:** យោ រូបក្ខន្ធំ បរិជានាតិ, សោ វេទនាខន្ធំ បរិជានិត្ថាតិ? *បុគ្គលណា កំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនា:** នោ *មិនមែនទេ។*

**បដិលោមបុច្ឆា:** យោ វា បន វេទនាខន្ធំ បរិជានិត្ថ, សោ រូបក្ខន្ធំ បរិជានាតីតិ? *ម្យ៉ាងទៀត បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏កំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ?*

**វិសជ្ជនា:** នោ *មិនមែនទេ។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យោ រូបក្ខន្ធំ បរិជានាតិ *ជាសន្និដ្ឋានបទ។*

សោ វេទនាខន្ធំ បរិជានិត្ថ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តមគ្គបុគ្គល ១។*

*៙ អត្ថធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជា***មោឃបញ្ហា** *សួរថា បុគ្គលណា កំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា* នោ *ដែលជាពាក្យវិសជ្ជនា បដិសេធអត្ថធម៌របស់សំសយបទ ព្រោះថា អរហត្តមគ្គបុគ្គល ១ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ តែមិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ។*

## ក្នុងបដិលោមបុច្ឆា

យោ វា បន វេទនាក្ខន្ធំ បរិជានិត្ថ *ជាសន្និដ្ឋានបទ។*

សោ រូបក្ខន្ធំ បរិជានាតិ *ជាសំសយបទ។*

*๑ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១។*

*๑ អន្តធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជាមោឃបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏កំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា* នោ *ដែលជាពាក្យវិសជ្ជនា បដិសេធអន្តធម៌របស់សំសយបទ ព្រោះថា អរហត្តផលបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ តែមិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ។*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយចកៈ

**អនុលោមបុច្ឆាៈ** យោ វេទនាក្ខន្ធំ បរិជានាតិ, សោ សញ្ញាក្ខន្ធំ បរិជានិត្ថាតិ? *បុគ្គលណា កំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ?*

**វិសជ្ជនាៈ** នោ *មិនមែនទេ។*

**បដិលោមបុច្ឆាៈ** យោ វា បន សញ្ញាក្ខន្ធំ បរិជានិត្ថ, សោ វេទនាក្ខន្ធំ បរិជានាតីតិ? *ម្យ៉ាងទៀត បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏កំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនា៖** នោ មិនមែនទេ។

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាស៖

## ក្នុងអនុលោមបុច្ឆា

យោ វេទនាខន្ធំ បរិជានាតិ ជាសន្និដ្ឋានបទ។

សោ សញ្ញាខន្ធំ បរិជានិត្ថ ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តមគ្គបុគ្គល ១។

៙ អន្តធម៌របស់សំសយបទ មិនមាន។

ដូច្នេះ ពាក្យសួរបទនេះ ជា**មោឃបញ្ហា** សួរថា បុគ្គលណា កំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា **នោ** ដែលជាពាក្យវិសជ្ជនា បដិសេធអន្តធម៌របស់សំសយបទ ព្រោះថា អរហត្តមគ្គបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ តែមិនធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ។

## ក្នុងបដិលោមបុច្ឆា

យោ វា បន សញ្ញាខន្ធំ បរិជានិត្ថ ជាសន្និដ្ឋានបទ។

សោ វេទនាខន្ធំ បរិជានាតិ ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១។

៙ អន្តធម៌របស់សំសយបទ មិនមាន។

ដូច្នេះ ពាក្យសួរបទនេះ ជា**មោឃបញ្ហា** សួរថា ម្យ៉ាងទៀត បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏កំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា **នោ** ដែលជាពាក្យវិសជ្ជនាបដិសេធអន្តធម៌របស់សំសយបទ ព្រោះថា អរហត្តផលបុគ្គល ១ ដែលជាអន្តធម៌របស់

*សន្និដ្ឋានបទទាំងនោះ សូម្បីធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ តែមិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

## (ចប់ បច្ចុប្បន្នាតីតវារៈ អនុលោម)

# បច្ចុប្បន្នាតីតវារៈ បច្ចនីកៈ បុគ្គលវារៈ

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យោ រូបក្ខន្ធំ ន បរិជានាតិ, សោ វេទនាក្ខន្ធំ ន បរិជានិត្ថាតិ? *បុគ្គលណា មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនាៈ** *អរហា* រូបក្ខន្ធំ ន បរិជានាតិ នោ ច វេទនាក្ខន្ធំ ន បរិជានិត្ថ, *អគ្គមគ្គសមង្គិញ្ច អរហន្តញ្ច ឋបេត្វា អវសេសា* បុគ្គលា រូបក្ខន្ធញ្ច ន បរិជានន្តិ វេទនាក្ខន្ធញ្ច ន បរិជានិត្ថ។ *អរហត្តផលបុគ្គល មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ តែធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, វៀរលែង អរហត្តមគ្គបុគ្គល និង អរហត្តផលបុគ្គលចេញហើយ ពួកបុគ្គលដែលនៅសល់ ក្រៅពីនោះ មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធផង មិនធ្លាប់កំណត់ដឹងច្បាស់នូវ វេទនាខន្ធផង។*

**បដិលោមបុច្ឆាៈ** យោ វា បន វេទនាក្ខន្ធំ ន បរិជានិត្ថ, សោ រូបក្ខន្ធំ ន បរិជានាតីតិ? *ម្យ៉ាងទៀត បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ?*

**វិសជ្ជនា:** អគ្គមគ្គសមង្គី វេទនាខន្ធំ ន បរិជានិត្ត នោ ច រូបក្ខន្ធំ ន បរិជានាតិ, អគ្គមគ្គសមង្គិញ្ច អរហន្តញ្ច ឋបេត្វា អវសេសា បុគ្គលា វេទនាខន្ធញ្ច ន បរិជានិត្ត រូបក្ខន្ធញ្ច ន បរិជានន្តិ។ *អរហត្តមគ្គបុគ្គល មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ តែកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, វៀរលែង អរហត្តមគ្គបុគ្គល និង អរហត្តផលបុគ្គលចេញហើយ ពួកបុគ្គលដែលនៅសល់ក្រៅពីនោះ មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធផង មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធផង។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ
## ក្នុងអនុលោមបុច្ឆា

យោ រូបក្ខន្ធំ ន បរិជានាតិ *ជាសន្និដ្ឋានបទ។*

សោ វេទនាខន្ធំ ន បរិជានិត្ថ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១,*

**និង** *កព្វបុថុជ្ជន ១ អភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣។*

*៙ អត្ថធម៌របស់សំសយបទ បានដល់ កព្វបុថុជ្ជន ១ អភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជា**បរិបុណ្ណបញ្ហា** សួរថា បុគ្គលណា មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **អរហា រូបក្ខន្ធំ ន បរិជានាតិ នោ ច វេទនាខន្ធំ ន បរិជានិត្ថ** *ហើយទ្រង់លើកយក កព្វបុថុជ្ជន ១ អភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទ និង សំសយបទ*

បានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **អគ្គមគ្គសមង្គិញ្ច អរហន្តញ្ច ឋបេត្វា អវសេសា បុគ្គលា រូបក្ខន្ធញ្ច ន បរិជានន្តិ វេទនាខន្ធញ្ច ន បរិជានិត្ត** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជា *សរូបទស្សនវិសជ្ជនា* ដែលមានវិកន្តដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យោ វា បន វេទនាខន្ធំ ន បរិជានិត្ត** ជាសន្និដ្ឋានបទៗ

**សោ រូបក្ខន្ធំ ន បរិជានាតិ** ជាសំសយបទៗ

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តមគ្គបុគ្គល ១,

និង ភព្វបុថុជ្ជន ១ អភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ៗ

៙ អន្តធម៌របស់សំសយបទ បានដល់ ភព្វបុថុជ្ជន ១ អភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ប៉ុណ្ណោះៗ

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណាមិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តមគ្គបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អគ្គមគ្គសមង្គី វេទនាខន្ធំ ន បរិជានិត្ត នោ ច រូបក្ខន្ធំ ន បរិជានាតិ** ហើយទ្រង់លើកយក ភព្វបុថុជ្ជន ១ អភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **អគ្គមគ្គសមង្គិញ្ច អរហន្តញ្ច ឋបេត្វា អវសេសា បុគ្គលា វេទនាខន្ធញ្ច ន បរិជានិត្ត រូបក្ខន្ធញ្ច ន បរិជានន្តិ**, ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជា *សរូបទស្សនវិសជ្ជនា* ដែលមានវិកន្តដោយត្រង់ៗ

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលិយមកៈ

**អនុលោមបុច្ឆាៈ** យោ វេទនាក្ខន្ធំ ន បរិជានាតិ, សោ សញ្ញាក្ខន្ធំ ន បរិជានិត្ថាតិ? *បុគ្គលណា មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ?*

**វិសជ្ជនាៈ** អរហា វេទនាក្ខន្ធំ ន បរិជានាតិ នោ ច សញ្ញាក្ខន្ធំ ន បរិជានិត្ថ, អគ្គមគ្គសមង្គិញ្ច អរហន្តញ្ច ឋបេត្វា អវសេសា បុគ្គលា វេទនាក្ខន្ធញ្ច ន បរិជានន្តិ សញ្ញាក្ខន្ធញ្ច ន បរិជានិត្ថ។ *អរហត្តផលបុគ្គល មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ តែធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, វៀរលែងអរហត្តមគ្គបុគ្គល និង អរហត្តផលបុគ្គលចេញហើយ ពួកបុគ្គលដែលនៅសល់ក្រៅពីនោះ មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធផង មិនធ្លាប់ កំណត់ដឹងច្បាស់នូវសញ្ញាខន្ធផង។*

**បដិលោមបុច្ឆាៈ** យោ វា បន សញ្ញាក្ខន្ធំ ន បរិជានិត្ថ, សោ វេទនាក្ខន្ធំ ន បរិជានាតីតិ? *ម្យ៉ាងទៀត បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនាៈ** អគ្គមគ្គសមង្គី សញ្ញាក្ខន្ធំ ន បរិជានិត្ថ នោ ច វេទនាក្ខន្ធំ ន បរិជានាតិ, អគ្គមគ្គសមង្គិញ្ច អរហន្តញ្ច ឋបេត្វា អវសេសា បុគ្គលា សញ្ញាក្ខន្ធញ្ច ន បរិជានិត្ថ វេទនាក្ខន្ធញ្ច ន បរិជានន្តិ។ *អរហត្តមគ្គបុគ្គល មិនធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ តែកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, វៀរលែង អរហត្តមគ្គបុគ្គល និង អរហត្តផលបុគ្គល*

ចេញហើយ ពួកបុគ្គលដែលនៅសល់ក្រៅពីនោះ មិនធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធផង មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធផង។

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

**យោ វេទនាក្ខន្ធំ ន បរិជានាតិ** ជាសន្និដ្ឋានបទ។

**សោ សញ្ញាក្ខន្ធំ ន បរិជានិត្ថ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១,

និង ភព្វបុថុជ្ជន ១ អភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣។

៙ អន្តធម៌របស់សំសយបទ បានដល់ ភព្វបុថុជ្ជន ១ អភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា បុគ្គលណា មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អរហា វេទនាក្ខន្ធំ ន បរិជានាតិ នោ ច សញ្ញាក្ខន្ធំ ន បរិជានិត្ថ** ហើយទ្រង់លើកយក ភព្វបុថុជ្ជន ១ អភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និងសំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **អគ្គមគ្គសមង្គិញ្ច អរហន្តញ្ច ឋបេត្វា អវសេសា បុគ្គលា វេទនាក្ខន្ធញ្ច ន បរិជានន្តិ សញ្ញាក្ខន្ធញ្ច ន បរិជានិត្ថ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

**យោ វា បន សញ្ញាខន្ធំ ន បរិជានិត្ត** ជាសន្និដ្ឋានបទ។

**សោ វេទនាខន្ធំ ន បរិជានាតិ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តមគ្គបុគ្គល ១,

និង កព្វបុថុជ្ជន ១ អកព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣។

៙ អន្តធម៌របស់សំសយបទ បានដល់ កព្វបុថុជ្ជន ១ អកព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណាមិនធ្លាប់កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តមគ្គបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អគ្គមគ្គសមង្គី សញ្ញាខន្ធំ ន បរិជានិត្ត នោ ច វេទនាខន្ធំ ន បរិជានាតិ** ហើយទ្រង់លើកយក កព្វបុថុជ្ជន ១ អកព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **អគ្គមគ្គសមង្គិញ្ច អរហន្តញ្ច ឋបេត្វា អវសេសា បុគ្គលា សញ្ញាខន្ធញ្ច ន បរិជានិត្ត វេទនាខន្ធញ្ច ន បរិជានន្តិ** ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកន្តដោយត្រង់។

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ បច្ចុប្បន្នាតីតវារៈ បច្ចនីកៈ)**

# បច្ចុប្បន្នានាគតវារៈ អនុលោម បុគ្គលវារៈ

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាក្ខន្ធមូលីយមកៈ

**អនុលោមបុច្ឆា:** យោ រូបក្ខន្ធំ បរិជានាតិ, សោ វេទនាក្ខន្ធំ បរិជានិស្សតីតិ? *បុគ្គលណា កំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនា:** នោ *មិនមែនទេ។*

**បដិលោមបុច្ឆា:** យោ វា បន វេទនាក្ខន្ធំ បរិជានិស្សតិ, សោ រូបក្ខន្ធំ បរិជានាតីតិ? *ម្យ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏កំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ?*

**វិសជ្ជនា:** នោ *មិនមែនទេ។*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យោ រូបក្ខន្ធំ បរិជានាតិ *ជាសន្និដ្ឋានបទ។*

សោ វេទនាក្ខន្ធំ បរិជានិស្សតិ *ជាសំសយបទ។*

*◉ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តមគ្គបុគ្គល ១។*

*◉ អត្ថធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជា***មោឃបញ្ហា** *សួរថា បុគ្គលណា កំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា នោ ដែលជាពាក្យវិសជ្ជនាបដិសេធអត្ថធម៌របស់សំសយបទ ព្រោះថា អរហត្តមគ្គបុគ្គល ១, ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ តែមិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ។*

## ក្នុងបដិលោមបុច្ឆា

យោ វា បន វេទនាខន្ធំ បរិជានិស្សតិ ជាសន្និដ្ឋានបទ។

សោ រូបក្ខន្ធំ បរិជានាតិ ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ ភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣។

៙ អន្តធម៌របស់សំសយបទ មិនមាន។

ដូច្នេះ ពាក្យសួរបទនេះ ជាមោឃបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏កំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា នោ ដែលជាពាក្យវិសជ្ជនាបដិសេធ អន្តធម៌របស់សំសយបទ ព្រោះថា ភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សុម្បីនឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ តែមិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ។

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យោ វេទនាខន្ធំ បរិជានាតិ, សោ សញ្ញាខន្ធំ បរិជានិស្សតីតិ? បុគ្គលណា កំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ?

**វិសជ្ជនាៈ** នោ មិនមែនទេ។

**បដិលោមបុច្ឆា:** យោ វា បន សញ្ញាខន្ធំ បរិជានិស្សតិ, សោ វេទនាខន្ធំ បរិជានាតីតិ? ម្យ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏កំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?

**វិសជ្ជនា:** នោ មិនមែនទេ។

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យោ វេទនាខន្ធំ បរិជានាតិ ជាសន្និដ្ឋានបទ។

សោ សញ្ញាខន្ធំ បរិជានិស្សតិ ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តមគ្គបុគ្គល ១។

៙ អន្តធម៌របស់សំសយបទ មិនមាន។

ដូច្នេះ ពាក្យសួរបទនេះ ជាមោឃបញ្ហា សួរថា បុគ្គលណា កំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា នោ ដែលជាពាក្យវិសជ្ជនាបដិសេធអន្តធម៌របស់សំសយបទ ព្រោះថា អរហត្តមគ្គបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សុទ្ធតែកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ តែមិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ។

## ក្នុងបដិលោមបុច្ឆា

យោ វា បន សញ្ញាខន្ធំ បរិជានិស្សតិ ជាសន្និដ្ឋានបទ។

សោ វេទនាខន្ធំ បរិជានាតិ ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កល្យាណបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣។

៙ អន្តធម៌របស់សំសយបទ មិនមាន។

*ដូច្នេះ ពាក្យសួរបទនេះ ជាមោឃបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏កំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា នោ ដែលជាពាក្យវិសជ្ជនាបដិសេធ អង្គធម៌របស់សំសយបទ ព្រោះថា ភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអង្គធម៌របស់សន្និដ្ឋានបទទាំងនោះ សុទ្ធតែនឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ តែមិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

## (ចប់ បច្ចុប្បន្នានាគតវារៈ អនុលោម)

# បច្ចុប្បន្នានាគតវារៈ បច្ចនីកៈ បុគ្គលវារៈ

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា:** យោ រូបក្ខន្ធំ ន បរិជានាតិ, សោ វេទនាខន្ធំ ន បរិជានិស្សតីតិ? *បុគ្គលណា មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនា:** យេ មគ្គំ បដិលភិស្សន្តិ តេ រូបក្ខន្ធំ ន បរិជានន្តិ នោ ច វេទនាខន្ធំ ន បរិជានិស្សន្តិ, អរហា យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ រូបក្ខន្ធញ្ច ន បរិជានន្តិ វេទនាខន្ធញ្ច ន បរិជានិស្សន្តិ។ *ពួកបុគ្គលណា នឹងបានមគ្គ ពួកបុគ្គលនោះ មិនមែនកំពុង - កំណត់ដឹងច្បាស់ នូវរូបក្ខន្ធ តែនឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, អរហត្តផលបុគ្គលក្តី*

*ពួកបុថុជ្ជនណាទីងមិនបានមគ្គ ពួកបុថុជ្ជននោះក្តី មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធផង និង មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធផង។*

**បដិលោមបុច្ឆា:** យោ វា បន វេទនាក្ខន្ធំ ន បរិជានិស្សតិ, សោ រូបក្ខន្ធំ ន បរិជានាតីតិ? *ម្យ៉ាងទៀត បុគ្គលណា មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ?*

**វិសជ្ជនា:** អគ្គមគ្គសមង្គី វេទនាក្ខន្ធំ ន បរិជានិស្សតិ នោ ច រូបក្ខន្ធំ ន បរិជានាតិ, អរហា យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ វេទនាក្ខន្ធញ្ច ន បរិជានិស្សន្តិ រូបក្ខន្ធញ្ច ន បរិជានន្តិ។ *អរហត្តមគ្គបុគ្គល មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ តែកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, អរហត្តផលបុគ្គលក្តី ពួកបុថុជ្ជនណា ទីងមិនបានមគ្គ ពួកបុថុជ្ជននោះក្តី មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធផង និង មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធផង។*

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យោ រូបក្ខន្ធំ ន បរិជានាតិ *ជាសន្និដ្ឋានបទ។*

សោ វេទនាក្ខន្ធំ ន បរិជានិស្សតិ *ជាសំសយបទ។*

*៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ ភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣,*

*និង អរហត្តផលបុគ្គល ១ អភព្វបុថុជ្ជន ១។*

*៙ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ អភព្វបុថុជ្ជន ១ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា បុគ្គលណា មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក កព្វុបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **យេ មគ្គំ បដិលភិស្សន្តិ តេ រូបក្ខន្ធំ ន បរិជានន្តិ នោ ច វេទនាខន្ធំ ន បរិជានិស្សន្តិ** ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ អកព្វុបុថុជ្ជន ១ ដែលជាអង្គធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **អរហា យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ រូបក្ខន្ធញ្ច ន បរិជានន្តិ វេទនាខន្ធញ្ច ន បរិជានិស្សន្តិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

**យោ វា បន វេទនាខន្ធំ ន បរិជានិស្សតិ** ជាសន្និដ្ឋានបទៗ

**សោ រូបក្ខន្ធំ ន បរិជានាតិ** ជាសំសយបទៗ

៙ អង្គធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តមគ្គបុគ្គល ១, និង អរហត្តផលបុគ្គល ១ អកព្វុបុថុជ្ជន ១ៗ

៙ អង្គធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ អកព្វុបុថុជ្ជន ១ ប៉ុណ្ណោះៗ

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណាមិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនមែនកំពុងកំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តមគ្គបុគ្គល ១ ដែលជាអង្គធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **អគ្គមគ្គសមង្គី វេទនាខន្ធំ ន បរិជានិស្សតិ នោ ច រូបក្ខន្ធំ ន បរិជានាតិ** ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១

*អកព្វបុថុជ្ជន ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* អរហា យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ វេទនាខន្ធញ្ច ន បរិជានិស្សន្តិ រូបក្ខន្ធញ្ច ន បរិជានន្តិ *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះ ជា សរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

## ខ. វេទនាខន្ធមូលៈ

### ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា៖** យោ វេទនាខន្ធំ ន បរិជានាតិ, សោ សញ្ញាខន្ធំ ន បរិជានិស្សតីតិ? *បុគ្គលណា មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ?*

**វិសជ្ជនា៖** យេ មគ្គំ បដិលភិស្សន្តិ តេ វេទនាខន្ធំ ន បរិជានន្តិ នោ ច សញ្ញាខន្ធំ ន បរិជានិស្សន្តិ, អរហា យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ វេទនាខន្ធញ្ច ន បរិជានន្តិ សញ្ញាខន្ធញ្ច ន បរិជានិស្សន្តិ។ *ពួកបុគ្គលណា នឹងបានមគ្គ ពួកបុគ្គលនោះ មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ តែនឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, អរហត្តផលបុគ្គលក្តី ពួកបុថុជ្ជនណា នឹងមិនបានមគ្គ ពួកបុថុជ្ជននោះក្តី មិនមែនកំពុងកំណត់ ដឹងច្បាស់នូវវេទនាខន្ធផង និង មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធផង។*

**បដិលោមបុច្ឆា៖** យោ វា បន សញ្ញាខន្ធំ ន បរិជានិស្សតិ, សោ វេទនាខន្ធំ ន បរិជានាតីតិ? *ម្យ៉ាងទៀត បុគ្គលណា មិនមែននឹង*

*កំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនា:** អគ្គមគ្គសមង្គី សញ្ញាខន្ធំ ន បរិជានិស្សតិ នោ ច វេទនាខន្ធំ ន បរិជានាតិ, អរហា យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ សញ្ញាខន្ធញ្ច ន បរិជានិស្សន្តិ វេទនាខន្ធញ្ច ន បរិជានន្តិ។ *អរហត្តមគ្គបុគ្គល មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ តែកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, អរហត្តផលបុគ្គលក្តី ពួកបុថុជ្ជនណា នឹងមិនបានមគ្គ ពួកបុថុជ្ជននោះក្តី មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធផង និងមិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធផង។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យោ វេទនាខន្ធំ ន បរិជានាតិ *ជាសន្និដ្ឋានបទ។*

សោ សញ្ញាខន្ធំ ន បរិជានិស្សតិ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣,*

**និង** *អរហត្តផលបុគ្គល ១ អភព្វបុថុជ្ជន ១។*

*៙ អត្ថធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ អភព្វបុថុជ្ជន ១ ប៉ុណ្ណោះ។*

*ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា បុគ្គលណា មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក កព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* យេ មគ្គំ

បដិលភិស្សន្តិ តេ វេទនាខន្ធំ ន បរិជានន្តិ នោ ច សញ្ញាខន្ធំ ន បរិជានិស្សន្តិ ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ អកព្វបុថុជ្ជន ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា អរហា យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ វេទនាខន្ធញ្ច ន បរិជានន្តិ សញ្ញាខន្ធញ្ច ន បរិជានិស្សន្តិ ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកន្តដោយត្រង់ៗ

## ក្នុងបដិលោមបុច្ឆា

យោ វា បន សញ្ញាខន្ធំ ន បរិជានិស្សតិ ជាសន្និដ្ឋានបទៗ

សោ វេទនាខន្ធំ ន បរិជានាតិ ជាសំសយបទៗ

๑ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តមគ្គបុគ្គល ១,

និង អរហត្តផលបុគ្គល ១ អកព្វបុថុជ្ជន ១ៗ

๑ អន្តធម៌របស់សំសយបទ បានដល់ អរហត្តផលបុគ្គល ១ អកព្វបុថុជ្ជន ១ ប៉ុណ្ណោះៗ

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណា មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏មិនមែនកំពុងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តមគ្គបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា អគ្គមគ្គសមង្គី សញ្ញាខន្ធំ ន បរិជានិស្សតិ នោ ច វេទនាខន្ធំ ន បរិជានាតិ ហើយទ្រង់លើកយក អរហត្តផលបុគ្គល ១ អកព្វបុថុជ្ជន ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា អរហា យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ សញ្ញាខន្ធញ្ច ន

*បរិជានិស្សន្តិ វេទនាខន្ធញ្ច ន បរិជានន្តិ ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆា នេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់ៗ*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

## (ចប់ បច្ចុប្បន្នានាគតវារៈ បច្ចនីកៈ)

# អតីតានាគតវារៈ អនុលោម បុគ្គលវារៈ

## ក. រូបខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យោ រូបក្ខន្ធំ បរិជានិត្ថ, សោ វេទនាខន្ធំ បរិជានិស្សតីតិ? *បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនាៈ** នោ *មិនមែនទេៗ*

**បដិលោមបុច្ឆាៈ** យោ វា បន វេទនាខន្ធំ បរិជានិស្សតិ, សោ រូបក្ខន្ធំ បរិជានិត្ថាតិ? *ម្យ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ?*

**វិសជ្ជនាៈ** នោ *មិនមែនទេៗ*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

### ក្នុងអនុលោមបុច្ឆា

យោ រូបក្ខន្ធំ បរិជានិត្ថ *ជាសន្និដ្ឋានបទៗ*

សោ វេទនាខន្ធំ បរិជានិស្សតិ *ជាសំសយបទៗ*

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១។

៙ អន្តធម៌របស់សំសយបទ មិនមាន។

ដូច្នេះ ពាក្យសួរបទនេះ ជា**មោឃបញ្ហា** សួរថា បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធ បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា **នោ** ដែលជាពាក្យវិសជ្ជនាបដិសេធអន្តធម៌របស់សំសយបទ ព្រោះថា អរហត្តផលបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធ តែមិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ។

## ក្នុងបដិលោមបុច្ឆា

**យោ វា បន វេទនាក្ខន្ធំ បរិជានិស្សតិ** ជាសន្និដ្ឋានបទ។

**សោ រូបក្ខន្ធំ បរិជានិត្ថ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ ភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣។

៙ អន្តធម៌របស់សំសយបទ មិនមាន។

ដូច្នេះ ពាក្យសួរបទនេះ ជា**មោឃបញ្ហា** សួរថា ម្យ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា **នោ** ដែលជាពាក្យវិសជ្ជនាបដិសេធអន្តធម៌របស់សំសយបទ ព្រោះថា ភព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអន្តធម៌របស់សន្និដ្ឋានបទទាំងនោះ សូម្បីនឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ តែមិនធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធ។

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលះ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យោ វេទនាក្ខន្ធំ បរិជានាតិ, សោ សញ្ញាក្ខន្ធំ បរិជានិស្សតីតិ? *បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ?*

**វិសជ្ជនាៈ** នោ *មិនមែនទេ។*

**បដិលោមបុច្ឆាៈ** យោ វា បន សញ្ញាក្ខន្ធំ បរិជានិស្សតិ, សោ វេទនាក្ខន្ធំ បរិជានាតីតិ? *ម្យ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនាៈ** នោ *មិនមែនទេ។*

### ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

### ក្នុងអនុលោមបុច្ឆា

យោ វេទនាក្ខន្ធំ បរិជានាតិ *ជាសន្និដ្ឋានបទ។*

សោ សញ្ញាក្ខន្ធំ បរិជានិស្សតិ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១។*

*៙ អត្ថធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជា*មោឃបញ្ហា *សួរថា បុគ្គលណា ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា* នោ *ដែលជាពាក្យវិសជ្ជនា បដិសេធអត្ថធម៌របស់សំសយបទ ព្រោះថា អរហត្តផលបុគ្គល ១ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សុទ្ធតែធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ តែមិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ។*

## ក្នុងបដិលោមបុច្ឆា

យោ វា បន សញ្ញាខន្ធំ បរិជានិស្សតិ *ជាសន្និដ្ឋានបទ។*

សោ វេទនាខន្ធំ បរិជានិត្ថ *ជាសំសយបទ។*

*៙ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣។*

*៙ អត្ថធម៌របស់សំសយបទ មិនមាន។*

*ដូច្នេះ ពាក្យសួរបទនេះ ជាមោឃបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏ធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយបដិសេធវិសជ្ជនាថា* នោ *ដែលជាពាក្យវិសជ្ជនាបដិសេធ អត្ថធម៌របស់សំសយបទ ព្រោះថា កព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអត្ថធម៌របស់សន្និដ្ឋានបទទាំងនោះ សុម្បីនឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ តែមិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ។*

**(មូលី មូលៈដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ អតីតានាគតវារៈ អនុលោម)**

# អតីតានាគតវារៈ បច្ចនីកៈ បុគ្គលវារៈ

## ក. រូបក្ខន្ធមូលៈ

### ១. រូបក្ខន្ធមូលៈ វេទនាខន្ធមូលីយមកៈ

**អនុលោមបុច្ឆា:** យោ រូបក្ខន្ធំ ន បរិជានិត្ថ, សោ វេទនាខន្ធំ ន បរិជានិស្សតីតិ? *បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនាៈ** យេ មគ្គំ បដិលភិស្សន្តិ តេ រូបក្ខន្ធំ ន បរិជានិត្ថ នោ ច វេទនាក្ខន្ធំ ន បរិជានិស្សន្តិ, អគ្គមគ្គសមង្គី យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ រូបក្ខន្ធញ្ច ន បរិជានិត្ថ វេទនាក្ខន្ធញ្ច ន បរិជានិស្សន្តិ។ *ពួកបុគ្គលណា នឹងបានមគ្គ ពួកបុគ្គលនោះ មិនធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធ តែនឹងកំណត់ដឹងច្បាស់នូវវេទនាក្ខន្ធ, អរហត្តមគ្គបុគ្គលក្តី ពួកបុថុជ្ជនណា នឹងមិនបានមគ្គ ពួកបុថុជ្ជននោះក្តី មិនធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធផង និង មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាក្ខន្ធផង។*

**បដិលោមបុច្ឆាៈ** យោ វា បន វេទនាក្ខន្ធំ ន បរិជានិស្សតិ, សោ រូបក្ខន្ធំ ន បរិជានិត្ថាតិ? *ម្យ៉ាងទៀត បុគ្គលណា មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាក្ខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធឬ?*

**វិសជ្ជនាៈ** អរហា វេទនាក្ខន្ធំ ន បរិជានិស្សតិ នោ ច រូបក្ខន្ធំ ន បរិជានិត្ថ, អគ្គមគ្គសមង្គី យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ វេទនាក្ខន្ធញ្ច ន បរិជានិស្សន្តិ រូបក្ខន្ធញ្ច ន បរិជានិត្ថ។ *អរហត្តផលបុគ្គល មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាក្ខន្ធ តែធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធ, អរហត្តមគ្គបុគ្គលក្តី ពួកបុថុជ្ជនណា នឹងមិនបានមគ្គ ពួកបុថុជ្ជននោះក្តី មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាក្ខន្ធផង និង មិនធ្លាប់កំណត់ដឹងច្បាស់នូវ រូបក្ខន្ធផង។*

## ការសំដែងអត្ថធម៌ និង ការចែកកោដ្ឋាសៈ

## ក្នុងអនុលោមបុច្ឆា

យោ រូបក្ខន្ធំ ន បរិជានិត្ថ *ជាសន្និដ្ឋានបទ។*

សោ វេទនាក្ខន្ធំ ន បរិជានិស្សតិ *ជាសំសយបទ។*

*១ អត្ថធម៌របស់សន្និដ្ឋានបទ បានដល់ កត្តបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣,*

និង អរហត្តមគ្គបុគ្គល ១ អកព្វបុថុជ្ជន ១។

៙ អន្តធម៌របស់សំសយបទ បានដល់ អរហត្តមគ្គបុគ្គល ១ អកព្វបុថុជ្ជន ១ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវរូបក្ខន្ធ, បុគ្គលនោះ ក៏មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក កព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា **យេ មគ្គំ បដិលភិស្សន្តិ តេ រូបក្ខន្ធំ ន បរិជានិត្ថ នោ ច វេទនាខន្ធំ ន បរិជានិស្សន្តិ** ហើយទ្រង់លើកយក អរហត្តមគ្គបុគ្គល ១ អកព្វបុថុជ្ជន ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា **អគ្គមគ្គសមង្គី យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ រូបក្ខន្ធញ្ច ន បរិជានិត្ថ វេទនាខន្ធញ្ច ន បរិជានិស្សន្តិ** ពាក្យវិសជ្ជនាក្នុងអនុលោមបុច្ឆានេះ ជាសរូបទស្សនវិសជ្ជនា ដែលមានវិកប្បដោយត្រង់។

## ក្នុងបដិលោមបុច្ឆា

**យោ វា បន វេទនាខន្ធំ ន បរិជានិស្សតិ** ជាសន្និដ្ឋានបទ។

**សោ រូបក្ខន្ធំ ន បរិជានិត្ថ** ជាសំសយបទ។

៙ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ អរហត្តផលបុគ្គល ១,

និង អរហត្តមគ្គបុគ្គល ១ អកព្វបុថុជ្ជន ១។

៙ អន្តធម៌របស់សំសយបទ បានដល់ អរហត្តមគ្គបុគ្គល ១ អកព្វបុថុជ្ជន ១ ប៉ុណ្ណោះ។

ដូច្នេះ ពាក្យសួរបទនេះ ជាបរិបុណ្ណបញ្ហា សួរថា ម្យ៉ាងទៀត បុគ្គលណា មិនមែននឹងកំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវ

*រូបក្ខន្ធឬ? ទើបព្រះអង្គទ្រង់សំដែងដោយការលើកយក អរហត្តផលបុគ្គល ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទបានតែម្យ៉ាង ទុកក្នុងបុរិមកោដ្ឋាសៈ មានការបដិសេធសំសយបទ ដូចបានសំដែងថា* **អរហា វេទនាក្ខន្ធំ ន បរិជានិស្សតិ នោ ច រូបក្ខន្ធំ ន បរិជានិត្ថ** *ហើយទ្រង់លើកយក អរហត្តមគ្គបុគ្គល ១ អកព្វបុថុជ្ជន ១ ដែលជាអន្តធម៌របស់សន្និដ្ឋានបទ និង សំសយបទបានទាំង ២ ទុកក្នុងបច្ឆិមកោដ្ឋាសៈ មិនមានការបដិសេធសំសយបទ ដូចបានសំដែងថា* **អគ្គមគ្គសមង្គី យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ វេទនាក្ខន្ធញ្ច ន បរិជានិស្សន្តិ រូបក្ខន្ធញ្ច ន បរិជានិត្ថ** *ពាក្យវិសជ្ជនាក្នុងបដិលោមបុច្ឆានេះជា សរូបទស្សនវិសជ្ជនា ដែលមានវិកន្តដោយត្រង់ៗ*

**(មូលី ដែលនៅសល់ ក៏សំដែងរបៀបគ្នា)**

**(ចប់ រូបក្ខន្ធមូលៈ)**

# ខ. វេទនាខន្ធមូលៈ

## ១. វេទនាខន្ធមូលៈ សញ្ញាខន្ធមូលីយមកៈ

**អនុលោមបុច្ឆាៈ** យោ វេទនាក្ខន្ធំ ន បរិជានិត្ថ, សោ សញ្ញាក្ខន្ធំ ន បរិជានិស្សតីតិ? *បុគ្គលណា មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, បុគ្គលនោះក៏មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធឬ?*

**វិសជ្ជនាៈ** យេ មគ្គំ បដិលភិស្សន្តិ តេ វេទនាក្ខន្ធំ ន បរិជានិត្ថ នោ ច សញ្ញាក្ខន្ធំ ន បរិជានិស្សន្តិ, អគ្គមគ្គសមង្គី យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ វេទនាក្ខន្ធញ្ច ន បរិជានិត្ថ សញ្ញាក្ខន្ធញ្ច ន បរិជានិស្សន្តិ។ *ពួកបុគ្គលណា នឹងបានមគ្គ ពួកបុគ្គលនោះមិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ តែនឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, អរហត្តមគ្គ*

*បុគ្គលក្តី ពួកបុថុជ្ជនណា នឹងមិនបានមគ្គ ពួកបុថុជ្ជននោះក្តី មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធផង និង មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធផង។*

**បដិលោមបុច្ឆា:** យោ វា បន សញ្ញាក្ខន្ធំ ន បរិជានិស្សតិ, សោ វេទនាក្ខន្ធំ ន បរិជានិត្ថាតិ? *ម្យ៉ាងទៀត បុគ្គលណា មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ, បុគ្គលនោះ ក៏មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធឬ?*

**វិសជ្ជនា:** *អរហា* សញ្ញាក្ខន្ធំ ន បរិជានិស្សតិ នោ ច វេទនាក្ខន្ធំ ន បរិជានិត្ថ, អគ្គមគ្គសមង្គី យេ ច បុថុជ្ជនា មគ្គំ ន បដិលភិស្សន្តិ តេ សញ្ញាក្ខន្ធញ្ច ន បរិជានិស្សន្តិ វេទនាក្ខន្ធញ្ច ន បរិជានិត្ថ។ *អរហត្តផលបុគ្គល មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធ តែធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធ, អរហត្តមគ្គបុគ្គលក្តី ពួកបុថុជ្ជនណា នឹងមិនបានមគ្គ ពួកបុថុជ្ជននោះក្តី មិនមែននឹងកំណត់ដឹងច្បាស់នូវសញ្ញាខន្ធផង និង មិនធ្លាប់កំណត់ដឹងច្បាស់នូវវេទនាខន្ធផង។*

## ការសំដែងអន្តធម៌ និង ការចែកកោដ្ឋាសៈ ក្នុងអនុលោមបុច្ឆា

យោ វេទនាក្ខន្ធំ ន បរិជានិត្ថ *ជាសន្និដ្ឋានបទ។*

សោ សញ្ញាក្ខន្ធំ ន បរិជានិស្សតិ *ជាសំសយបទ។*

*◉ អន្តធម៌របស់សន្និដ្ឋានបទ បានដល់ កព្វបុថុជ្ជន ១ មគ្គបុគ្គលថ្នាក់ក្រោម ៣ ផលបុគ្គលថ្នាក់ក្រោម ៣,*

*និង អរហត្តមគ្គបុគ្គល ១ អកព្វបុថុជ្ជន ១។*

